គំរោងកម្មវិធីរៀបចំអភិវឌ្ឍន៍ម៉ូឌុលនេះ បានត្រូវផ្តល់ធនធានដោយទីភ្នាក់ងារអូស្ត្រាលី សំរាប់ការអភិវឌ្ឍន៍អន្តរជាតិ (AusAID) ដែលជាផ្នែកមួយនៃគំរោងកម្មវិធីលើកកំពស់សុខភាពកម្ពុជា និងការថែទាំសុខភាពបឋម(CHP and PHC Project )

ម៉ូឌុលនេះសរសេររៀបរៀងឡើង ដោយមានសហការប្រឹងប្រែងរួមៈ

**អ្នកសហការការងាររួមមាន ៈ**

- ប្រធានផ្នែកបណ្តុះបណ្តាលនៃ ម.ជ.ល.ស (NCHP) — វេជ្ជ. ឡេង គួយ
- គ្រូអប់រំសុខភាព — លោក ទុយ តាន់រដ្ឋី
- គ្រូជំនាញបណ្តុះបណ្តាល — លោកស្រី ឈឿ សុជាតិ

**ការប្រឹក្សាបានត្រូវផ្តល់មកពី ៈ**

- ទីប្រឹក្សា (NCHP-CHP & PHC Project - HE/IEC) — លោក ខេន សួន
- គ្រូជំនាញបណ្តុះបណ្តាល សាលាភូមិភាគកំពងចាម — លោកស្រី ហ៊ុត សុខលាង
- មូលនិធិសង្គ្រោះកុមារអូស្ត្រាលី — លោក ហាង វុទ្ធី
- គ្រូជំនាញបណ្តុះបណ្តាលនៃក្រសួងសុខាភិបាល — លោកស្រី វេជ្ជ. ចុង វណ្ណារ៉ា

អ្នកសំរបសំរួលការរៀបចំ និង ការបង្ហាញម៉ូឌុលនេះ ៈ

- ទីប្រឹក្សាការបណ្តុះបណ្តាល គ្លីនិកនៃគំរោង CHP/PHC — លោកស្រី យូលា ស្ទួត

សៀវភៅនេះ ត្រូវបានបោះពុម្ពលើកទី១ នៅខែធ្នូ ឆ្នាំ ១៩៩៩
កែសំរួលលើកទី ១ ខែវិច្ឆិកា ២០០៤

# តារាងមាតិកា


១. ផែនការណែនាំសំរាប់ MPA7 ស្ដីពី ការអប់រំសុខភាព និងការលើកកំពស់សុខភាព ........................ ៣-៥

២. សំភារៈបង្រៀន .............................................................................................៦- ៨

៣. ការតាមដាន វាយតំលៃ និងឯកសារសំអាង ............................................................ ៩

៤. កាលវិភាគគំរូ ...............................................................................................១០

៥. កម្មវិធីសិក្សា ...........................................................................................១១-១៥

៦. សមត្ថភាពដែលត្រូវអភិវឌ្ឍ ..........................................................................១៦- ១៨

៧. របៀបប្រើសៀវភៅណែនាំសំរាប់គ្រូ ..................................................................១៩-២០

៨. សេចក្ដីផ្ដើមនៃម៉ូឌុលទី៧ ..................................................................................២១-២២

៩. ផ្នែកទី១: សេចក្ដីត្រូវការនៃការអប់រំសុខភាព និងការលើកកំពស់សុខភាព ...................................២៣

- មេរៀនទី ១ ........................................................................................២៣- ២៩
- មេរៀនទី ២ ........................................................................................៣០-៣៥
- មេរៀនទី ៣ ........................................................................................៣៦-៤១
- មេរៀនទី ៤ ........................................................................................៤២-៤៦

១០. ផ្នែកទី២ : ដំណើរការនៃការអប់រំសុខភាព .........................................................................៤៧

- មេរៀនទី ១ : ជំហានទី ១ ..............................................................................៤៧-៥១
- មេរៀនទី ១ : ជំហានទី ២ ..............................................................................៥២-៥៣
- មេរៀនទី ១ : ជំហានទី ៣ ..............................................................................៥៤- ៥៧
- មេរៀនទី ១ : ជំហានទី ៤ ..............................................................................៥៧-៥៩
- មេរៀនទី ១ : ជំហានទី ៥ ..............................................................................៦០-៦២
- មេរៀនទី ១ : ជំហានទី ៦ ..............................................................................៦២-៦៤
- មេរៀនទី ១ : ជំហានទី ៧ ..............................................................................៦៥-៦៧
- មេរៀនទី ២ : ការប្រើប្រាស់សំភារៈសំរាប់អប់រំសុខភាព ..........................................៦៨-៨១

១០.ផ្នែកទី ៣ : ដំណើរការនៃការលើកកំពស់សុខភាព ....................................................៨២- ៩៦

១១.ផ្នែកទី ៤ : សេចក្ដីសន្និដ្ឋាន និងការរំឭកម៉ូឌុលឡើងវិញ .........................................៩៧-១០០

១២.សកម្មភាពបន្ថែម (រឿងនិទាន).......................................................................១០១-១០៣

១៣. វិធីសាស្ត្របង្រៀនតាមបែបចូលរួម ...............................................................១០៤-១០៦

១៤. សំណួរសាកល្បងមុននិងក្រោយពេលសិក្សា និងតារាងចម្លើយ.....................................១០៧-១១១

# ផែនការណែនាំ សំរាប់ MPA ម៉ូឌុលទី ៧
# ស្តីពី ការអប់រំសុខភាព និង ការលើកកំពស់សុខភាព

## ផែនការដាក់អោយអនុវត្តម៉ូឌុលនេះ

**សិក្ខាកាម:**

- បុគ្គលិកសុខាភិបាលដែលធ្វើការនៅតាមមណ្ឌលសុខភាព ។

**ទំហំថ្នាក់ :**

- សិក្ខាកាមមិនត្រូវលើស២០នាក់ ឬចំនួនគុណនៃសិក្ខាកាម៥នាក់ ។
- សំរាប់សកម្មភាពក្រុមតូចដែលល្អគឺចំនួន៥នាក់ ។

**គ្រូ :**

- មន្ត្រីសុខាភិបាលដែលមានបទពិសោធន៍នៅកន្លែងធ្វើការក្នុងការប្រើប្រាស់បច្ចេកទេសអប់រំសុខភាព ឬបច្ចេក ទេស លើកកំពស់សុខភាព ។
- អាទិភាពគួរបានដល់គ្រូណាដែលបានបង្រៀនឬចូលរួមរៀននៅក្នុងវគ្គបណ្តុះបណ្តាល ដែលបានសង្កត់លើ ការអប់ រំសុខភាព ឬលើកកំពស់សុខភាព ។
- មានបទពិសោធន៍ក្នុងការបង្រៀន ឬការបណ្តុះបណ្តាលបន្ត ដល់បុគ្គលិកសុខាភិបាល

**គ្រូជំនួយ :**

- មានបទពិសោធន៍ក្នុងការបង្រៀន ការបណ្តុះបណ្តាលបន្តដល់បុគ្គលិកសុខាភិបាល ។
- គ្រូជំនួយម្នាក់សំរាប់សិក្ខាកាម ១០ នាក់ ។

**គំរោងនៃម៉ូឌុល :**

ម៉ូឌុលនេះ បានសង្កត់ធ្ងន់ទៅលើការអនុវត្តន៍ ដូចជា :

- វិធីសាស្ត្របង្រៀនបែបចូលរួម ត្រូវបានយកមកប្រើ សិក្ខាកាមនឹងរៀនដោយការអនុវត្តន៍
- សំរាប់ម៉ូឌុលនេះ បានសង្កត់ធ្ងន់លើការអនុវត្តន៍ជំនាញរួមមាន :
- ល្បែងសំដែងតួ
- សិក្ខាកាមធ្វើការអនុវត្តន៍ ដោយប្រើករណីសិក្សា
- ធ្វើបង្ហាញ ត្រឡប់មកវិញ
- ការបង្ហាញរូបភាព
- នេះគឺជាសមត្ថភាពមូលដ្ឋានដែលសិក្ខាកាមនឹងអាចធ្វើការអប់រំសុខភាព និង

ធ្វើការលើកកំពស់សុខភាព នៅក្នុងស្ថានភាពពិសេសដោយឡែកណាមួយ ដូចជាក្នុងសហគមន៍ជាដើម ។

- ជំនាញនិមួយៗមានបញ្ជីត្រួតពិនិត្យ ។ បញ្ជីត្រួតពិនិត្យទាំងនោះត្រូវបានប្រើដើម្បី តាមដាន ត្រួតពិនិត្យ និង វាយតំលៃ ការអនុវត្តន៍របស់សិក្ខាកាម ។

## ការដាក់ឱ្យអនុវត្តផែនការ

### ១- នៅមុនពេលវគ្គសិក្សាចាប់ផ្តើម អ្នកដឹកនាំម៉ូឌុល ឬ អ្នកសំរបសំរួលវគ្គត្រូវ :

- ជ្រើសរើសទីកន្លែងបង្រៀនមួយ / ថ្នាក់រៀនដែល :
  - មានកៅអីគ្រប់គ្រាន់ និងទំហំថ្នាក់សំរាប់សិក្ខាកាម ២០ នាក់
  - មានទីកន្លែងល្មម សំរាប់ក្រុមតូច ប្រហែល៥នាក់ អាចនឹងអង្គុយធ្វើការជាមួយគ្នា
  - មានទីកន្លែងគ្រប់គ្រាន់សំរាប់បិទក្រដាសផ្ទាំងធំ
- ជួយដល់អ្នកគ្រប់គ្រងក្នុងការជ្រើសរើសសិក្ខាកាម អ្នកដែលបានរៀនចប់យ៉ាងតិចណាស់ក៏ ភាម៉ូឌុលទី១
- ជួយដល់អ្នកគ្រប់គ្រងក្នុងការជ្រើសរើសគ្រូជំនួយដែលសមស្របដោយត្រូវ:
  - ពិភាក្សាខ្លឹមសារនៃម៉ូឌុលជាមួយគ្រូ និងគ្រូជំនួយ
  - ផ្តល់ឱ្យគ្រូជំនួយនូវការណែនាំច្បាស់លាស់អំពីអ្វីដែលពួកគេត្រូវធ្វើពេលវគ្គកំពុងដំណើរការ
  - ពន្យល់ពីការប្រើប្រាស់បញ្ជីត្រួតពិនិត្យជំនាញ

### ២- នៅរៀងរាល់ព្រឹកនៃវគ្គសិក្សា គ្រូត្រូវ :

- ពិនិត្យឆែកមើលមេរៀនអ្វីខ្លះដែលនឹងត្រូវបង្រៀន
- ធ្វើការផ្លាស់ប្តូរកម្មវិធី ប្រសិនបើចាំបាច់
- សាកល្បង និងគិតទុកជាមុន នូវបញ្ហា ហើយគិតរកដំណោះស្រាយដែលអាចធ្វើបាន
- រៀបចំក្រដាសផ្ទាំងធំ និង/សំភារៈជំនួយបង្រៀន
- ប្រាកដថាគ្រូជំនួយយល់ពីភារកិច្ចប្រចាំថ្ងៃរបស់គេ

### ៣- មុនពេលចាប់ផ្តើមមេរៀនថ្មី រៀងរាល់ព្រឹកគ្រូគួរ :

- ណែនាំឱ្យសិក្ខាកាមទាំងអស់ឱ្យចំណាយពេលប្រហែល២០នាទី ក្នុងការឆ្លុះបញ្ចាំងដល់មេរៀនដែលបាន រៀនពីថ្ងៃមុន។ មានរបៀបជាច្រើនក្នុងការរំលឹកមេរៀន ។

- ណែនាំឱ្យសិក្ខាកាមជ្រើសរើសដៃគូម្នាក់ហើយនាំគ្នាដើរ និងពិភាក្សាពីការចាប់អារម្មណ៍របស់ពួកគេលើមេរៀនពីថ្ងៃមុន ។ នៅពេលត្រឡប់មកថ្នាក់រៀនវិញ គ្រូអាចស្វែងរកពតិមានត្រឡប់ពីសិក្ខាកាម អំពី ការវាយតំលៃរបស់ពួកគេ នៃមេរៀនដែលបានរៀនពីថ្ងៃមុន ។
- គ្រូអាចរំលឹកឡើងវិញខ្លីៗ នូវមេរៀន និងស្វែងរកការបកស្រាយពីសិក្ខាកាម ។
- វាមានភាពចំណេញច្រើន ក្នុងការឱ្យសិក្ខាកាមរំលឹកឡើងវិញនូវមេរៀនពីថ្ងៃមុន ។ ម៉្យាងទៀត វាជួយឱ្យសិក្ខាកាមផ្តោតអារម្មណ៍របស់ពួកគេលើមេរៀនដែលបានរៀនពីថ្ងៃមុន បន្ទាប់ពីសំរាក ១យប់មក។
- វាផ្តល់ពតិមានត្រឡប់មកឱ្យគ្រូវិញ ថាតើអ្វីខ្លះដែលសិក្ខាកាមនឹកឃើញពីមេរៀននៅថ្ងៃមុន និងតើបញ្ហាចំបងនៅក្នុងការបង្រៀននោះស្ថិតនៅត្រង់ណា បន្ទាប់មកអ្នកអាចនឹងប្តូរដើម្បីសំរបតាម។ នៅចុងបញ្ចប់នៃថ្ងៃនិមួយៗនៃវគ្គសិក្សា អ្នកដឹកនាំវគ្គ និងគ្រូជំនួយត្រូវ :
  - ពិភាក្សាពីកម្មវិធីថ្ងៃនេះ
  - ធ្វើការសំរេចចិត្ត ប្រសិនបើត្រូវការឱ្យមានការផ្លាស់ប្តូរកម្មវិធីសំរាប់ថ្ងៃបន្ទាប់

នៅចុងបញ្ចប់នៃវគ្គសិក្សាអ្នកដឹកនាំម៉ូឌុល ត្រូវពិភាក្សាអំពីការដាក់ឱ្យអនុវត្តម៉ូឌុលនេះជាមួយគ្រូបង្រៀនទាំងអស់ពី:

- រឿងរ៉ាវ ឬបញ្ហា ដែលបានដកស្រង់ និងថាតើត្រូវដោះស្រាយយ៉ាងដូចម្តេច?
- ការដកស្រង់សំណូមពរ
- ការជួបជាមួយអ្នកគ្រប់គ្រង ហើយពិភាក្សាពីសំណូមពរទាំងអស់នោះ ។

## សំភារះបង្រៀន

**សំភារះបង្រៀនក្នុងម៉ូឌុលទី៧ រួមមាន :**

- គំរោងមេរៀន
- កាលវិភាគគំរូ
- សៀវភៅណែនាំសំរាប់គ្រូ
- សៀវភៅការងារសំរាប់សិក្ខាកាម
- ផ្ទាំងរូបភាព
- ក្រដាសចម្លង នៃបញ្ជីត្រួតពិនិត្យសមត្ថភាព
- សំណួរសាកល្បង មុនពេលសិក្សា និង ក្រោយពេលសិក្សា

**សំភារៈបង្រៀនដែលនិងត្រូវប្រើជារៀងរាល់ថ្ងៃនៅក្នុងថ្នាក់រៀន :**

- ក្តារខៀន ប៊ិច ហ្វឺត និងដីស
- ក្រដាសផ្ទាំងធំ / ក្រដាសថ្លា ប៊ិច និង ហ្វឺត
- សៀវភៅណែនាំ សំរាប់មណ្ឌលសុខភាព " សំរាប់មើលសំអាង" ។

**សំភារៈសំរាប់មេរៀននិមួយៗ :**

## ផ្នែកទី ១ មេរៀនទី ១ :

- សំភារៈសំរាប់ពិភាក្សាក្រុមតូច : ក្រដាសផ្ទាំងធំ / ក្រដាសថ្លា ប៊ិច ហ្វឺត និងបង់ស្អិត
- សៀវភៅសន្លឹកផ្ទាត់
- ក្តារខៀន ប៊ិច ហ្វឺត ប្រដាប់លុបក្តារខៀន

## ផ្នែកទី ១ មេរៀនទី ២ :

- សំភារៈសំរាប់ពិភាក្សាក្រុមតូច : ក្រដាសផ្ទាំងធំ / ក្រដាសថ្លា ប៊ិច បង់ស្អិត
- ក្តារខៀន ប៊ិច ហ្វឺត ប្រដាប់លុបក្តារខៀន
- ស្រោមសំបុត្រដែលមាន : បំពង់ប៊ីត១បាច់ ម្ជុលបារាំង១ប្រអប់ បង់ស្អិត១ដុំ និងកូនកន្រ្តៃ១
- ក្រដាសផ្ទាំងធំ ដោយត្រូវចម្លងតារាងពិន្ទុ និង បញ្ជីទាំង២គឺ : អាកប្បកិរិយា និង កត្តារាំងស្ទះ

## ផ្នែកទី ១ មេរៀនទី ៣ :

- សំភារៈសំរាប់ពិភាក្សាក្រុមតូច : ក្រដាសផ្ទាំងធំ / ក្រដាសថ្លា ប៊ិច បង់ស្អិត
- សៀវភៅសន្លឹកផ្ទាត់
- ក្តារខៀន ប៊ិច ហ្វឺត ប្រដាប់លុបក្តារខៀន
- ក្រដាសផ្ទាំងធំ ដែលចម្លងការពន្យល់ពី គំរូវការសុខភាពផ្នែកអារម្មណ៍ និងតំរូវការសុខភាពពិតប្រាកដ

## ផ្នែកទី ១ មេរៀនទី ៤ :

- សំភារៈសំរាប់ពិភាក្សាក្រុមតូច : ក្រដាសផ្ទាំងធំ / ក្រដាសថ្លា ប៊ិច បង់ស្អិត
- ក្រដាសផ្ទាំងធំដែលចម្លងនូវនិយមន័យ ការអប់រំសុខភាព និងការលើកកំពស់សុខភាព
- ក្តារខៀន ប៊ិចហ្វឺត ប្រដាប់លុបក្តារខៀន

## ផ្នែកទី ២ មេរៀនទី ១ ជំហានទី ១ :

- ក្តារខៀន ប៊ិច ប្រដាប់លុបក្តារខៀន
- សៀវភៅណែនាំសំរាប់មណ្ឌលសុខភាព
- សៀវភៅសន្លឹកផ្ទាត់ MPA Module ២ (ផែនការព្យាបាល)

## ផ្នែកទី ២ មេរៀនទី ១ ជំហានទី ២ :

- ក្តារខៀន ប៊ិចហ្វឺត ប្រដាប់លុបក្តារខៀន
- សៀវភៅណែនាំសំរាប់មណ្ឌលសុខភាព
- សំភារៈសំរាប់ពិភាក្សាក្រុមតូច : ក្រដាសផ្ទាំងធំ ប៊ិច ហ្វឺត បង់ស្អិត

**ផ្នែកទី ២ មេរៀនទី ១ ជំហានទី ៣ :**

- ក្តារខៀន ប៊ិច ហ្វឺត ប្រដាប់លុបក្តារខៀន
- សៀវភៅណែនាំសំរាប់មណ្ឌលសុខភាព
- សំភារៈសំរាប់ពិភាក្សាក្រុមតូច : ក្រដាសផ្ទាំងធំ / ក្រដាសថ្លា ប៊ិច ហ្វឺត បង់ស្អិត

**ផ្នែកទី ២ មេរៀនទី ១ ជំហានទី ៤ :**

- ក្តារខៀន ប៊ិច ហ្វឺត ប្រដាប់លុបក្តារខៀន
- សំភារៈសំរាប់ពិភាក្សាក្រុមតូច : ក្រដាសផ្ទាំងធំ / ក្រដាសថ្លា ប៊ិច ហ្វឺត បង់ស្អិត

**ផ្នែកទី ២ មេរៀនទី ១ ជំហានទី ៥ :**

- ក្តារខៀន ប៊ិច ហ្វឺត ប្រដាប់លុបក្តារខៀន
- សំភារៈសំរាប់ពិភាក្សាក្រុមតូច : ក្រដាសផ្ទាំងធំ / ក្រដាសថ្លា ប៊ិច ហ្វឺត បង់ស្អិត
- សៀវភៅសន្លឹកផ្ទាត់
- រូបភាពសន្លឹកបត់ ( របៀបស្អំត្រជាក់)
- រូបភាពផ្ទាំងធំ ( របៀបស្អំត្រជាក់)
- សំភារៈសំរាប់សំអាតផ្ចិត
- សំភារៈសំរាប់ស្អំត្រជាក់
- រូបភាពផ្ទាំងធំ ( របៀបសំអាតផ្ចិត)

**ផ្នែកទី ២ មេរៀនទី ១ ជំហានទី ៦ :**

- ក្តារខៀន ប៊ិច ហ្វឺត ប្រដាប់លុបក្តារខៀន
- សំភារៈសំរាប់ពិភាក្សាក្រុមតូច : ក្រដាសផ្ទាំងធំ / ក្រដាសថ្លា ប៊ិច បង់ស្អិត

**ផ្នែកទី ២ មេរៀនទី ១ ជំហានទី ៧ :**

- ក្តារខៀន ប៊ិច ហ្វឺត ប្រដាប់លុបក្តារខៀន
- សំភារៈសំរាប់ពិភាក្សាក្រុមតូច : ក្រដាសផ្ទាំងធំ / ក្រដាសថ្លា ប៊ិចហ្វឺត បង់ស្អិត

**ផ្នែកទី ២ មេរៀនទី ២ :**

- ក្តារខៀន ប៊ិចហ្វឺត ប្រដាប់លុបក្តារខៀន
- សំភារៈសំរាប់ពិភាក្សាក្រុមតូច : ក្រដាសផ្ទាំងធំ /ក្រដាសថ្លា ប៊ិច ហ្វឺត បង់ស្អិត

- សៀវភៅសន្លឹកផ្ទាត់ ៤
- រូបភាពសន្លឹកបត់ ៤
- រូបភាពផ្ទាំងធំ ៤
- ផ្លាកក្រដាសសំរាប់សរសេរបញ្ជាក់ពី ( សៀវភៅសន្លឹកផ្ទាត់ រូបភាពសន្លឹកបត់ រូបភាពផ្ទាំងធំ)

**ផ្នែកទី ៣ មេរៀនទី ១ :**

- ក្តារខៀន ប៊ិច ហ្វឺត ប្រដាប់លុបក្តារខៀន
- សំភារៈសំរាប់ពិភាក្សាក្រុមតូច : ក្រដាសផ្ទាំងធំ / ក្រដាសថ្លា ប៊ិច ហ្វឺត បង់ស្អិត
- ក្រដាសផ្ទាំងធំ ដែលសរសេរនូវជំហានទាំង៦ នៃការធ្វើផែនការ

**ផ្នែកទី ៣ មេរៀនទី ២ :**

- ក្តារខៀន ប៊ិច ហ្វឺត ប្រដាប់លុបក្តារខៀន
- សំភារៈសំរាប់ពិភាក្សាក្រុមតូច : ក្រដាសផ្ទាំងធំ / ក្រដាសថ្លា ប៊ិច ហ្វឺត បង់ស្អិត
- ក្រដាសផ្ទាំងធំ ដែលសរសេរនូវជំហានទី១ ទី២ ទី៣ ទី៤ ទី៥ ទី៦ នៃការធ្វើផែនការ

**ផ្នែកទី ៤ :**

- ក្តារខៀន ប៊ិច ហ្វឺត ប្រដាប់លុបក្តារខៀន
- សៀវភៅណែនាំសំរាប់មណ្ឌលសុខភាព
- សំភារៈសំរាប់ពិភាក្សាក្រុមតូច : ក្រដាសផ្ទាំងធំ / ក្រដាសថ្លា ប៊ិច ហ្វឺត បង់ស្អិត ។
- សិក្ខាកាមត្រូវយកសៀវភៅការងារសំរាប់សិក្ខាកាម មករៀនជារៀងរាល់ពេល ។

## ការតាមដាន និង វាយតំលៃ :

- ត្រូវធ្វើសំណួរសាកល្បងមុនពេលសិក្សា ដើម្បីកំណត់ពីចំណេះដឹង ដែលមានមុនពេលសិក្សាវគ្គនេះ
- បុគ្គលិកសំរបសំរួលការបណ្ដុះបណ្ដាលបន្ត ១ជជែសច ត្រូវកត់ត្រា និងធ្វើរបាយការណ៍លទ្ធផលតេស្ត មុន និង ក្រោយពេលសិក្សា រួចផ្ញើមួយច្បាប់ទៅបុគ្គលិកសាលាភូមិភាគទទួលបន្ទុកបណ្ដុះបណ្ដាលបន្ត
- ការិយាល័យបច្ចេកទេសខេត្តត្រូវប្រើបញ្ជីត្រួតពិនិត្យជំនាញ៣ខែ ក្រោយពេលបញ្ចប់ការដាក់ឱ្យអនុវត្តនូវម៉ូឌុល ដើម្បី វាយតំលៃថា តើជំនាញត្រូវបានយកមកប្រើក្នុងមណ្ឌលសុខភាពឬទេ? បំណងនៃសកម្មភាពទាំងនេះ អាចត្រូវយកទៅប្រើនៅពេលសិក្ខាកាមត្រឡប់ទៅធ្វើការ ក្រោយពេលបញ្ចប់កម្មវិធីបណ្ដុះបណ្ដាល ។

## ឯកសារសំអាងដែលបានប្រើក្នុងការសរសេរម៉ូឌុលនេះ :


- Johnstone, P&Ranken,J. (១៩៩៤). ការគ្រប់គ្រងទ្រទ្រង់សំរាប់ការថែទាំសុខភាពបឋម ។ សៀវភៅណែនាំងាយស្រួលប្រើ មួយសំរាប់មណ្ឌលសុខភាព និងគំរោងកម្មវិធីក្នុងស្រុក ។ ទំនាក់ទំនង FSG Cambridge: UK ។
- Lankester, T. (១៩៩៤). ការបង្កើតឡើងនៃកម្មវិធីសុខភាពសហគមន៍ សៀវភៅងាយស្រួលប្រើមួយ សំរាប់ប្រើនៅក្នុង ប្រទេសកំពុងអភិវឌ្ឍន៍ ។ Macmillan សារពតិមានទីក្រុងឡុងដុង ។
- Werner, D. and Bower, B (១៩៩៥) ការជួយបុគ្គលិកសុខាភិបាល ឱ្យរៀនមូលនិធិ Hesperian Foundation: Palo Alt
- សៀវភៅបែបបទធ្វើផែនការសំរាប់មណ្ឌលសុខភាព របស់នាយកដ្ឋានផែនការ និងពិតមានសុខាភិបាលឆ្នាំ ២០០៣។
- សៀវភៅផែនការ វ៉ុលូម១ របស់ក្រសួងសុខាភិបាល ឆ្នាំ ២០០៣។
- សៀវភៅណែនាំសំរាប់មណ្ឌលសុខភាព។
- សៀវភៅ MPA ម៉ូឌុលទី២។

# កាលវិភាគគំរូ

| | ច័ន្ទ | អង្គារ | ពុធ | ព្រហស្បត្តិ៍ | សុក្រ |
|---|---|---|---|---|---|
| **ព្រឹក** | • ការចុះឈ្មោះ<br>• ពិធីបើកវគ្គ<br>• ណែនាំខ្លួនឱ្យស្គាល់គ្នា<br>• ការបែងចែកក្រុម តួនាទី ភារកិច្ច<br>• សេចក្តីសង្ឃឹមចំពោះវគ្គ<br>• បង្ហាញពីវត្ថុបំណងម៉ូឌុល<br>• ការសាកល្បងមុនការសិក្សា | • រំឭកមេរៀនពីម្សិល :<br>• **ផ្នែកទី ១** :<br>- មេរៀនទី៣<br>- មេរៀនទី៤ | • រំឭកមេរៀនពីម្សិល<br>• **ផ្នែកទី ២ :**<br>- មេរៀនទី១:<br>- ជំហានទី៣<br>- ជំហានទី៤<br>- ជំហានទី៥ | • រំឭកមេរៀនពីម្សិល:<br>• **ផ្នែកទី ២ :**<br>- មេរៀនទី២:<br>- វត្ថុបំណង៣<br>- វត្ថុបំណង៤ | • រំឭកមេរៀនពីម្សិល :<br>• **ផ្នែកទី ៣** :<br>- មេរៀនទី២(បន្ត)<br>• **ផ្នែកទី ៤** :<br>- រំឭកម៉ូឌុលឡើងវិញ |
| **ល្ងាច** | • **ផ្នែកទី ១ :**<br>- មេរៀនទី១<br>- មេរៀនទី២ | • **ផ្នែកទី ២ :**<br>- មេរៀនទី១ :<br>- ជំហានទី១<br>- ជំហានទី២ | • **ផ្នែកទី២ :**<br>- មេរៀនទី១:<br>- ជំហានទី៦<br>- ជំហានទី៧<br>- មេរៀនទី២:<br>- វត្ថុបំណង១<br>- វត្ថុបំណង២ | • **ផ្នែកទី៣ :**<br>- មេរៀនទី១<br>- មេរៀនទី២ | • ការសាកល្បងក្រោយការសិក្សា<br>• ការវាយតំលៃម៉ូឌុល<br>• ពិធីបិទវគ្គ |

# កម្មវិធីសិក្សា

## សេចក្តីផ្តើមនៃម៉ូឌុលទី៧ :

| វត្ថុបំណង | ខ្លឹមសារ | រយៈពេល | វិធីសាស្រ្ត | សំភារៈ | ការវាយតំលៃ |
|---|---|---|---|---|---|
| ផ្តល់នូវទិដ្ឋភាពទូទៅនៃម៉ូឌុល | រំលឹកនូវគំរោងម៉ូឌុល និងវត្ថុបំណងនៃមេរៀន | ៣០ នាទី | ដឹកនាំការពិភាក្សា | សៀវភៅសិក្សា | សំណួរ-ចម្លើយ |

## ផ្នែកទី១ : សេចក្តីត្រួតការនៃការអប់រំសុខភាព និងការលើកកំពស់សុខភាព

## មេរៀនទី ១ : ប្រព័ន្ធផ្តល់ការថែទាំសុខភាព

| វត្ថុបំណង | ខ្លឹមសារ | រយៈពេល | វិធីសាស្រ្ត | សំភារៈ | ការវាយតំលៃ |
|---|---|---|---|---|---|
| ១. រៀបរាប់ពីភាពខុសគ្នារវាងប្រព័ន្ធផ្តល់ការថែទាំសុខភាពដែលដឹកនាំដោយសហគមន៍ ( ប្រព័ន្ធបង្ការ និង ប្រព័ន្ធព្យាបាល) មុនពេលកំណែទំរង់ ប្រព័ន្ធសុខាភិបាល ថ្មីត្រូវបានដាក់បញ្ចូល<br>២. ពន្យល់ពីសារៈសំខាន់នៃប្រព័ន្ធផ្តល់ការថែទាំសុខភាព ដែលដឹកនាំដោយសហគមន៍( ប្រព័ន្ធបង្ការ)<br>៣. ពន្យល់ពីចំណងទាក់ទងនៃការអប់រំសុខភាពដើម្បីធ្វើឱ្យសុខភាពសហគមន៍ប្រសើរឡើង។ | • តើប្រព័ន្ធផ្តល់ការថែទាំសុខភាពដែលដឹកនាំដោយសហគមន៍ មុនពេលកំណែទំរង់ប្រព័ន្ធសុខាភិបាលថ្មីត្រូវបានដាក់បញ្ចូល មានលក្ខណៈយ៉ាងដូចម្តេច?<br>• ប្រៀបធៀបប្រព័ន្ធថែទាំសុខភាពបែបចាស់ និងប្រព័ន្ធថែទាំ សុខភាពបែបថ្មី ខុសគ្នាដូចម្តេច?<br>• តើការបែងចែកមូលដ្ឋានសុខាភិបាលឱ្យស្មើគ្នាមានន័យយ៉ាងដូចម្តេច?<br>• តើបញ្ហាអ្វីខ្លះដែលអាចកើតមាន ពេលអនុវត្តកំណែទំរង់ប្រព័ន្ធសុខាភិបាលថ្មី?<br>• ប្រភេទនៃការថែទាំសុខភាពបែបបុរាណ<br>• ប្រភេទនៃការថែទាំសុខភាពបែបវិទ្យាសាស្រ្ត<br>• ប្រភេទនៃការថែទាំសុខភាពតាមសហគមន៍ | ៥០ នាទី | • ពិភាក្សាតាមចិត្ត<br>• ពិភាក្សាក្រុមតូច<br>• បង្ហាញប្រព័ន្ធសុខាភិបាលថ្មី<br>• ពិភាក្សាក្រុមធំ<br>• បង្ហាញរូបភាព | • សៀវភៅណែនាំសំរាប់ម.ស<br>• ផ្ទាំងក្រដាសធំ<br>• ហ្វឺត<br>• ប្រដាប់បញ្ចាំង<br>• ក្រដាសថ្លា<br>• រូបភាពទាំង៣ ប្រព័ន្ធសុខាភិបាលថ្មី | • ពតិមានត្រឡប់របស់សិក្ខាកាម |

# មេរៀនទី ២ : ការចូលរួមរបស់សហគមន៍

| វត្ថុបំណង | ខ្លឹមសារ | រយៈពេល | វិធីសាស្ត្រ | សំភារៈ | ការវាយតំលៃ |
|---|---|---|---|---|---|
| ១. រៀបរាប់ពីអត្ថប្រយោជន៍នៃការចូលរួមរបស់សហគមន៍ | • ជំរុញលើកទឹកចិត្តសិក្ខាកាមឱ្យគិតអំពីការចូលរួមរបស់សហគមន៍<br>• ការយកចិត្តទុដាក់ពីកំរិតខុសគ្នានៃការចូលរួមរបស់សហគមន៍ | ៤០ នាទី<br>៤០ នាទី | • ល្បែងសង់ប៉ម<br>• ពិភាក្សាក្រុមតូច | បំពង់បឺត ម្ជុលបារាំង កន្ត្រៃ ស្កុត ក្រដាសថត ចម្លងកិច្ចការ | លទ្ធផលនៃការសង់ប៉មដោយសិក្ខាកាម |
| ២. រៀបរាប់មធ្យោបាយ ដើម្បីជំរុញឱ្យសហគមន៍ចូលរួម និងកត្តារាំងស្ទះដល់ការចូលរួមរបស់សហគមន៍ | • ឥទ្ធិពលនៃដៃគូការងារទៅលើសុខភាពសហគមន៍<br>• តើបុគ្គលិកមណ្ឌលសុខភាពត្រូវមានអាកប្បកិរិយាយ៉ាងដូចម្តេចដើម្បីជំរុញ លើកទឹកចិត្តឱ្យសហគមន៍ចូលរួមក្នុងការសំរេចចិត្តអំពីការថែទាំសុខភាព | ៤០ នាទី | • ពិភាក្សាក្រុមតូច | • រូបភាព M7 P.01, P.02, P.03, P.04<br>• ក្រដាសផ្ទាំងធំ ហ្វឺត ប្រដាប់បញ្ចាំង ក្រដាសថ្លា | • ពតិមានត្រឡប់របស់សិក្ខាកាម |

## មេរៀនទី ៣ : គំរូចការសុខភាព

| វត្ថុបំណង | ខ្លឹមសារ | រយៈពេល | វិធីសាស្ត្រ | សំភារៈ | ការវាយតំលៃ |
|---|---|---|---|---|---|
| ១. ផ្តល់ឧទាហរណ៍នៃគំរូវការសុខភាពផ្អែកអារម្មណ៍ និងគំរូវការសុខភាពពិតប្រាកដ<br><br><br><br><br><br>២. បំពេញក្នុងតារាងនូវគំរូវការសុខភាពផ្អែកអារម្មណ៍ និងគំរូវការសុខភាពពិតប្រាកដ | • កំណត់និយមន័យនៃគំរូវការសុខភាពផ្អែកអារម្មណ៍ និងគំរូវការសុខភាពពិតប្រាកដ<br>• តើអ្វីខ្លះដែលជាគំរូវការសុខភាពផ្អែកអារម្មណ៍របស់សហគមន៍នៅនឹងកន្លែងរបស់អ្នក<br>• សារៈសំខាន់នៃគំរូវការសុខភាពផ្អែកអារម្មណ៍ និងគំរូវការសុខភាពពិតប្រាកដរបស់សហគមន៍<br>• គំរូវការសុខភាពពិតប្រាកដនៅកម្ពុជាទាក់ទងនឹងកុមារខ្វះចំណីអាហារ សញ្ញាគ្រោះថ្នាក់ពេលមានផ្ទៃពោះ ខ្វះខាតបង្គន់ | ២០ នាទី<br><br>១៥ នាទី<br><br>៥ នាទី<br>៥ នាទី<br>៤៥ នាទី | • បំផុសគំនិត<br>• ពិភាក្សាតាមចិត្ត<br>• ការងារផ្ទាល់ខ្លួន<br>• ពិភាក្សាតាមចិត្ត<br>• ពិភាក្សាក្រុមតូច | • ក្រដាសផ្ទាំងធំ<br>• ហ្វឺត រូបភាព<br>• សៀវភៅណែនាំ<br>• ប្រដាប់បញ្ចាំង<br>• ក្រដាសថ្លា | • ពតិមានត្រឡប់របស់សិក្ខាកាម<br>• ពតិមានត្រឡប់របស់សិក្ខាកាម<br><br>• ពតិមានត្រឡប់របស់សិក្ខាកាម |

## មេរៀនទី ៤ : ការអប់រំសុខភាព និង ការលើកកំពស់សុខភាព

| វត្ថុបំណង | ខ្លឹមសារ | រយៈពេល | វិធីសាស្ត្រ | សំភារៈ | ការវាយតំលៃ |
|---|---|---|---|---|---|
| ១. កំណត់ន័យនៃពាក្យ :<br>○ ការអប់រំសុខភាព<br>○ ការលើកកំពស់សុខភាព<br>២. ពន្យល់ពីតួនាទីនៃបុគ្គលិកមណ្ឌលសុខភាព ក្នុងការអប់រំសុខភាព និងការលើកកំពស់សុខភាព ។ | • និយមន័យនៃពាក្យ :<br>○ ការអប់រំសុខភាព<br>○ ការលើកកំពស់សុខភាព<br>• មធ្យោបាយដើម្បីសិក្សាស្វែងយល់ពីសហគមន៍ | <br>១០នាទី<br>១០ នាទី<br>៥៥ នាទី | • បំផុសគំនិត<br>• ពិភាក្សាក្រុមធំ<br>• ការងារផ្ទាល់ខ្លួន | • ក្រដាសផ្ទាំងធំ<br>• ហ្វឺត<br>• ប្រដាប់បញ្ចាំង<br>• ក្រដាសថ្លា | • ពតិមានត្រឡប់របស់សិក្ខាកាម<br><br>• ពតិមានត្រឡប់របស់សិក្ខាកាម |

# ផ្នែកទី ២ : ដំណើរការនៃការអប់រំសុខភាព

## មេរៀនទី ១ : ការអប់រំអតិថិជនក្នុងអំឡុងពេលព្យាបាល ឬបន្ទាប់ពីព្យាបាលរួច

| វត្ថុបំណង | ខ្លឹមសារ | រយៈពេល | វិធីសាស្ត្រ | សំភារៈ | ការវាយតំលៃ |
|---|---|---|---|---|---|
| ១. បង្ហាញនូវទំរង់បង្រៀនមាន៧ជំហាន របស់ដំណើរការនៃការអប់រំសុខភាព ។<br>២. ប្រើប្រាស់ទំរង់ដែលមាន៧ជំហានសំរាប់អប់រំអតិថិជនក្នុងពេលកំពុងផ្តល់សេវានៅមណ្ឌលសុខភាព | • **ជំហានទី១:** កំណត់បញ្ហា<br>• **ជំហានទី២:** ជ្រើសរើសខ្លឹមសារគ្លីនិកត្រឹមត្រូវ<br>• **ជំហានទី៣:**ជ្រើសរើសខ្លឹមសារបង្រៀនសមស្រប<br>• **ជំហានទី៤:** ជ្រើសរើសវិធីសាស្ត្របង្រៀន<br>• **ជំហានទី៥:**ជ្រើសរើសសំភារៈជំនួយ<br>• **ជំហានទី៦:** ពិតមានត្រឡប់ និង វាយតំលៃការអប់រំ<br>• **ជំហានទី៧:** កំណត់គ្រោសកម្មភាព និងលទ្ធផល | ៧៥ នាទី<br>៧៥ នាទី<br>៨៥ នាទី<br>៥០ នាទី<br>៤០ នាទី<br>៤៥ នាទី<br>៣៥ នាទី | • ពិភាក្សាតាមចិត្ត<br>• និទានរឿង<br>• ការងារផ្ទាល់ខ្លួន<br>• ល្បែងសំដែងតួ<br>• ពិភាក្សាតាមចិត្ត<br>• ពិភាក្សាក្រុមតូច<br>• ពិភាក្សាក្រុមតូច | • សៀវភៅ MPA Modul 2<br>• សៀវភៅណែនាំសំរាប់ម.ស<br>• ក្រដាសផ្ទាំងធំ<br>• ហ្វឺត | • ពតិមានត្រឡប់របស់សិក្ខាកាម |

## មេរៀនទី ២ : ការប្រើប្រាស់សំភារៈសំរាប់ការអប់រំសុខភាព

| វត្ថុបំណង | ខ្លឹមសារ | រយៈពេល | វិធីសាស្ត្រ | សំភារៈ | ការវាយតំលៃ |
|---|---|---|---|---|---|
| ១. កំណត់លក្ខណៈចំបង នៃរូបភាពផ្ទាំងធំ រូបភាពសន្លឹកបត់ និងសៀវភៅសន្លឹកផ្ទាត។<br>២. ជ្រើសរើសសំភារៈអប់រំសុខភាព សមស្រប សំរាប់ការអប់រំសុខភាព និងការលើកកំពស់សុខភាព | និយមន័យនៃពាក្យ:<br>○ រូបភាពផ្ទាំងធំ<br>○ រូបភាពសន្លឹកបត់<br>○ សៀវភៅសន្លឹកផ្ទាត់ | ៥០ នាទី | • ពិភាក្សាក្រុមធំ<br>• ពិភាក្សាក្រុមតូច<br>• ពិភាក្សាក្រុមធំ<br>• បំផុសគំនិត<br>• អនុវត្តជាក់ស្តែង | • ក្រដាសផ្ទាំងធំ<br>• ហ្វឺត<br>• រូបភាពផ្ទាំងធំ<br>• រូបភាពសន្លឹកបត់<br>• ស.ភ សន្លឹកផ្ទាត់ | • ពតិមានត្រឡប់របស់សិក្ខាកាម |
| ៣. កំណត់របៀបប្រើប្រាស់រូបភាពផ្ទាំងធំ រូបភាពសន្លឹកបត់ សៀវភៅសន្លឹកផ្ទាត់ | ជ្រើសរើសសំភារៈអប់រំសុខភាពសមស្រប សំរាប់ការអប់រំសុខភាព និងការលើកកំពស់សុខភាព | ៣០ នាទី | | | |
| ៤. អនុវត្ត ការប្រើប្រាស់បានត្រឹមត្រូវនូវសំភារៈអប់រំសុខភាព | របៀបប្រើប្រាស់សំភារៈអប់រំសុខភាព<br>អនុវត្តជាក់ស្តែងនូវការប្រើប្រាស់សំភារៈអប់រំសុខភាព | ៥០ នាទី<br>៧៥ នាទី | | | |

## ផ្នែកទី៣ : ដំណើរការនៃការលើកកំពស់សុខភាព

| វត្ថុបំណង | ខ្លឹមសារ | រយៈពេល | វិធីសាស្ត្រ | សំភារៈ | ការវាយតំលៃ |
|---|---|---|---|---|---|
| ១. វដ្ត និងបែបទនៃការធ្វើផែនការ<br><br>២. ពិភាក្សា និងអនុវត្តបែបបទនៃការធ្វើផែនការ | - បង្ហាញវដ្ត និងបែបបទនៃការធ្វើផែនការ<br><br>- ពិភាក្សា និងអនុវត្ត ជំហានទាំង៦នៃបែបបទធ្វើផែនការ | ១ម៉ោង<br><br>៣ម៉ោង | គ្រូដឹកនាំការពិភាក្សា<br>ពិភាក្សាក្រុមតូច | OHT /<br>ប្រដាប់បញ្ចាំង<br>ក្រដាសថ្លា<br>ក្រដាសផ្ទាំងធំ | • ពតិមានត្រឡប់របស់សិក្ខាកាម<br>• វាយតំលៃជំនាញសិក្ខាកាម |

## ផ្នែកទី ៤ : សេចក្តីសន្និដ្ឋាន និង ការរំឭកម៉ូឌុលឡើងវិញ

| វត្ថុបំណង | ខ្លឹមសារ | រយៈពេល | វិធីសាស្ត្រ | សំភារៈ | ការវាយតំលៃ |
|---|---|---|---|---|---|
| ១. រៀបរាប់មធ្យោបាយដែលលោកអ្នកនឹងធ្វើដើម្បីជំរុញលើកទឹកចិត្តឱ្យមានការចូលរួមរបស់សហគមន៍<br>២. រំឭកឡើងវិញនូវជំហានទាំង ៧ នៃការអប់រំសុខភាព<br>៣. ពន្យល់ពីតួនាទីនៃបុគ្គលិកមណ្ឌលសុខភាព ក្នុងការលើកកំពស់សុខភាព<br>៤. ធ្វើបញ្ជីប្រភពធនធាន ដែលមានស្រាប់ របស់បុគ្គលិកមណ្ឌលសុខភាព សំរាប់ធ្វើសកម្មភាពអប់រំសុខភាព និងលើកកំពស់សុខភាព | - រំឭកពីអាកប្បកិរិយាដែលជួយសំរួលដល់ការចូលរួមរបស់សហគមន៍<br><br>- រំឭកពីជំហានទាំង៧នៃការអប់រំអតិថិជន<br><br>- ពន្យល់ពីតួនាទីមណ្ឌលសុខភាព ក្នុងការអប់រំសុខភាព និងការលើកកំពស់សុខភាព។<br>- ប្រភពធនធានសំរាប់ការអប់រំសុខភាព និងការលើកកំពស់សុខភាព | ១ម៉ោង<br>និង<br>៣០នាទី | ពិភាក្សា ក្រុមតូច<br>គ្រូដឹកនាំការពិភាក្សា | - ក្រដាសផ្ទាំងធំ<br>- រំឭកពីសំភារៈដែលប្រើក្នុងមេរៀនមុន ។ | • ពតិមានត្រឡប់របស់សិក្ខាកាម<br>• វាយតំលៃជំនាញសិក្ខាកាម |

**សមត្ថភាពដែលត្រូវអភិវឌ្ឍ នៅក្នុងម៉ូឌុលនៃការអប់រំសុខភាព និងការលើកកំពស់សុខភាព**

បុគ្គលិកសុខាភិបាលម្នាក់ៗ អាចធ្វើការបង្ហាញយ៉ាងតិចបំផុត ចំនួនបីនៃការអនុវត្តន៍ការអប់រំសុខភាព

**១. ការធ្វើផែនការបង្រៀនជាបុគ្គល ឬក្រុម**

**២. ការអប់រំអតិថិជនក្នុងកំឡុងពេលព្យាបាល ឬបន្ទាប់ពីព្យាបាលរួច**

**៣. ការប្រើសំភារៈអប់រំសុខភាព សំរាប់ការអប់រំសុខភាព និងលើកកំពស់សុខភាព នៅក្នុងមណ្ឌលសុខភាព តាមផ្ទះ និងនៅក្នុងភូមិ** (រូបភាពផ្ទាំងធំ រូបភាពសន្លឹកបត់ សៀវភៅសន្លឹកផ្ទាត់) បុគ្គលិកសុខាភិបាលម្នាក់ៗ អាចធ្វើបង្ហាញយ៉ាងតិចបំផុតនូវការអនុវត្តន៍ចំនួន២ នៃការលើកកំពស់សុខភាព ដូចជា :

- លទ្ធភាពដើម្បីចូលរួមក្នុងការដាក់ឱ្យអនុវត្តគំនិតផ្តើមនៃការលើកកំពស់សុខភាពថ្នាក់ជាតិ
- លទ្ធភាពដើម្បីឆ្លើយតបទៅនឹង រោគរាតត្បាតនៅក្នុងស្រុក ឬការផ្ទុះឡើងនូវរោគរាតត្បាត ដោយឆ្លៀត ឱកាសធ្វើការលើកកំពស់សុខភាព (ឧ. យុទ្ធនាការផ្សព្វផ្សាយ) ។

# ការអប់រំសុខភាព

## ១- ការធ្វើផែនការបង្រៀន ជាបុគ្គល ឬ ជាក្រុម

បញ្ជីនៃប្រធានបទ (Topic) ដែលបុគ្គលិកសុខាភិបាលអាចនឹងត្រូវធ្វើការបង្ហាញនូវជំនាញនៃការអប់រំសុខភាព សមស្រប (ទំនាក់ទំនងទៅនឹងការបង្រៀន) មានដូចជា:

- បង្រៀនការថែទាំទងផ្ចិតទារកដល់ម្តាយម្នាក់ដែលមិនធ្លាប់ទទួលការអប់រំបន្ទាប់ពីប្រសូត្រកូនហើយ
- ផ្តល់នូវការណែនាំដល់អតិថិជនដែលបានធ្វើរោគវិនិច្ឆ័យថាមានជម្ងឺកាមរោគ អំពីការប្រព្រឹត្តផ្លូវភេទ
- បង្រៀនអតិថិជន ថាតើធ្វើដូចម្តេច ដើម្បីលាយល្បាយអូរ៉ាលីត្រ
- បង្រៀនអតិថិជន ដែលបានត្រូវធ្វើរោគវិនិច្ឆ័យថា កើតជម្ងឺរបេង អំពីការខាកស្តោះ ។

## ២ -ការអប់រំអតិថិជនក្នុងកំឡុងពេលព្យាបាល ឬបន្ទាប់ពីព្យាបាលរួច

បញ្ជីនៃប្រធានបទ ដែលបុគ្គលិកសុខាភិបាលអាចនឹងត្រូវធ្វើការបង្ហាញនូវជំនាញអប់រំសុខភាពសមស្រប មានដូចជា:

- ការធ្វើប៉ង់សឺម៉ង់ដំបៅ
- ការផ្តល់ឱសថសំរាប់គ្រុនក្តៅ
- ការថែទាំកុមារបន្ទាប់ពីចាក់ថ្នាំបង្ការ
- ការថែទាំកុមារដែលបានធ្វើរោគវិនិច្ឆ័យថាមានជម្ងឺផ្លូវដង្ហើម

បញ្ជីត្រួតពិនិត្យសមត្ថភាព ដើម្បីវាយតំលៃលទ្ធភាពរបស់បុគ្គលិកសុខាភិបាល ក្នុងការបង្ហាញជំនាញអប់រំសុខភាពសមស្រប មានដូចខាងក្រោម:

**បញ្ជីត្រួតពិនិត្យសមត្ថភាព : ការអប់រំអតិថិជន**

- **កំណត់បញ្ហា**
- **ជ្រើសរើសខ្លឹមសារគ្លីនិកត្រឹមត្រូវ**
- **ជ្រើសរើសខ្លឹមសារបង្រៀនសមស្រប**
- **ជ្រើសរើសវិធីសាស្រ្តបង្រៀន**
- **ជ្រើសរើសសំភារៈជំនួយ**
- **ស្វែងរកពត៌មានត្រឡប់ និង វាយតំលៃការអប់រំ**
- **កត់ត្រាសកម្មភាពអប់រំ និង លទ្ធផល**

## ៣- ការប្រើសំភារៈអប់រំសុខភាពសំរាប់ការអប់រំសុខភាព និង លើកកំពស់សុខភាព

បុគ្គលិកមណ្ឌលសុខភាព អាចនឹងធ្វើបង្ហាញនូវការអប់រំសុខភាពសមស្រប ដោយត្រូវមាន :

- **ការប្រើសៀវភៅសន្លឹកផ្ទាត់** ជាមធ្យោបាយមួយសំរាប់អប់រំដល់បុគ្គល (នៅមណ្ឌលសុខភាព ឬ ផ្ទះ) ឬសំរាប់ (ក្រុម ឬ ការប្រជុំសាធារណៈ)
- **ការប្រើរូបភាពផ្ទាំងធំ** ជាមធ្យោបាយមួយសំរាប់អប់រំបុគ្គល (នៅមណ្ឌលសុខភាព ឬ ផ្ទះ ) ឬសំរាប់ (ក្រុម ឬ ការប្រជុំសាធារណៈ)
- **ការប្រើរូបភាពសន្លឹកបត់** ជាមធ្យោបាយមួយសំរាប់អប់រំបុគ្គល (នៅមណ្ឌលសុខភាព ឬផ្ទះ ) ឬសំរាប់ (ក្រុម ឬការប្រជុំសាធារណៈ)

**បញ្ជីត្រួតពិនិត្យសមត្ថភាព : ការជ្រើសរើស និង ការប្រើប្រាស់សំភារៈសំរាប់អប់រំសុខភាព**

- កំណត់ថា តើសំភារៈមួយណា ឬ ការរួមបញ្ចូលសំភារៈមួយណា ដើម្បីប្រើប្រាស់ឱ្យសមស្របទៅនឹងស្ថានភាព
- លទ្ធភាពដើម្បីរៀបចំដាក់តាំងនូវសំភារៈបានត្រឹមត្រូវ ( ទីកន្លែង - របៀបដាក់បង្ហាញ )
- វាយតំលៃកំរិតនៃការយល់ដឹងអំពីចំណុចអប់រំសុខភាពដល់អតិថិជន
- លទ្ធភាពដើម្បីពន្យល់អោយបានច្បាស់លាស់ អំពីខ្លឹមសារនៃសំភារៈទាំងនោះ
- ជំរុញលើកទឹកចិត្តអតិថិជនឱ្យចូលរួមក្នុងការប្រើប្រាស់សំភារៈទាំងនោះ
- វាយតំលៃការយល់ដឹងរបស់អតិថិជន
- ធ្វើស្ទួន១ឡើងវិញនូវចំណុចសំខាន់១នៃការរៀនសូត្រ

# ការលើកកំពស់សុខភាព

**១ -លទ្ធភាពដើម្បីចូលរួមការដាក់ឱ្យអនុវត្តគំនិតផ្តើមនៃការលើកកំពស់សុខភាពថ្នាក់ជាតិ**

បញ្ជីនៃប្រធានបទ ដែលបុគ្គលិកមណ្ឌលសុខភាពអាចនឹងធ្វើបង្ហាញនូវជំនាញលើកកំពស់សុខភាពសមស្រប មាន ដូចជា :

- កម្មវិធីផ្តល់ថ្នាំបង្ការ
- ទិវាពិភពលោកនៃជម្ងឺអេដស៍

**២ -លទ្ធភាពដើម្បីឆ្លើយតបទៅនឹងរោគរាតត្បាតនៅក្នុងស្រុក ឬ ការផ្ទុះឡើងនូវរោគរាតត្បាត ដោយឆ្លៀតឱកាសធ្វើការលើកកំពស់សុខភាព ( ឧ. យុទ្ធនាការផ្សព្វផ្សាយ)**

បញ្ជីនៃប្រធានបទ ដែលបុគ្គលិកមណ្ឌលសុខភាពអាចនឹងធ្វើបង្ហាញនូវជំនាញលើកកំពស់សុខភាពសមស្រប មាន ដូចជា :

- ការឆ្លើយតបទៅនឹងបញ្ហាសុខភាពដែលកើតមាននៅនឹងទីកន្លែង (ឧទាហរណ៍ ជំរុញលើកទឹកចិត្តប្រជាជន ឱ្យដាំទឹកផឹក អនុវត្តការរក្សាទឹកទុកប្រកបដោយសុវត្ថិភាព ការប្រើប្រាស់មុង) ។
- គ្រប់គ្រង និង ការធ្វើផែនការលើកកំពស់សុខភាពសមស្រប

**បញ្ជីត្រួតពិនិត្យសមត្ថភាព : ការលើកកំពស់សុខភាព**

- លទ្ធភាពដើម្បីកំណត់នូវប្រភពធនធានដែលមានស្រាប់នៅនឹងទីកន្លែង ( មនុស្ស - សំភារៈ )
- លទ្ធភាពដើម្បីរៀបចំផែនការសកម្មភាព ដោយផ្អែកលើធនធានរបស់មណ្ឌលសុខភាព និង ប្រភពធនធានដែលមានស្រាប់នៅនឹងកន្លែង ។
- លទ្ធភាពដើម្បីដាក់ឱ្យអនុវត្ត និង គ្រប់គ្រងសកម្មភាពតាមផែនការ
- លទ្ធភាពដើម្បីវាយតំលៃលទ្ធផលជាក់ស្តែងនៃការអន្តរាគមន៍ ដល់ការលើកកំពស់សុខភាព
- លទ្ធភាពដើម្បីធ្វើរបាយការណ៍បានត្រឹមត្រូវជូនដល់អ្នកពាក់ព័ន្ធ ឬ រដ្ឋអំណាច ។

# របៀបប្រើសៀវភៅណែនាំសំរាប់គ្រូ

សៀវភៅនេះ ចែកចេញជាផ្នែកៗ ដែលផ្នែកនិមួយៗ ចែកចេញជាច្រើនមេរៀនទៀត ។ មេរៀនថ្មីនិមួយៗ ចាប់ផ្តើមនៅលើទំព័រថ្មី ។ នៅទំព័រទី១នៃមេរៀននិមួយៗ បង្ហាញនូវចំណងជើង វត្ថុបំណងនៃមេរៀន អ្វីដែលគ្រូត្រូវរៀបចំមុនពេលបង្រៀន និងអ្វីដែលគ្រូជំនួយត្រូវធ្វើសំរាប់មេរៀននេះ ។

**ឧទាហរណ៍:**

**មេរៀនទី២ : ការចូលរួមរបស់សហគមន៍**

**ចំណងជើងមេរៀន**

**១. រយៈពេល :** ២ម៉ោង

**២. វត្ថុបំណង :** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមម្នាក់ៗនឹងអាច :

**វត្ថុបំណង**

១. រៀបរាប់ពីអត្ថប្រយោជន៍នៃការចូលរួមរបស់សហគមន៍
២. រៀបរាប់នូវមធ្យោបាយ យ៉ាងតិច៣ ដើម្បីជំរុញឱ្យសហគមន៍ចូលរួម
៣. ឱ្យឧទាហរណ៍ ៣ យ៉ាងតិច នៃកត្តារាំងស្ទះដល់ការចូលរួមរបស់សហគមន៍

**តើមេរៀននេះជាប់ទាក់ទងយ៉ាងដូចម្តេច ទៅនឹងការងាររបស់បុគ្គលិកមណ្ឌលសុខភាព?**

**តើមេរៀននេះជាប់ទាក់ទងយ៉ាងដូចម្តេច**

ជំហាននេះពន្យល់ពីសារៈសំខាន់នៃការចូលរួមរបស់សហគមន៍នៅក្នុងការសំរេចអំពីសុខភាព និងផ្តល់ឱ្យសិក្ខាកាមនូវមធ្យោបាយខ្លះៗ ដើម្បីជួយឱ្យមានការចូលរួមរបស់សហគមន៍ ។

**៣. សំភារៈ និងការរៀបចំទុកជាមុនៈ**

**អ្នកនឹងត្រូវការ**

**សំភារៈដែលត្រូវការ**

- ផ្ទាំងក្រដាសធំ ប៊ិច បង់ស្អិត ក្តារខៀន ហ្វឺត ប្រដាប់លុប
- ស្រោមសំបុត្រធំ ដែលក្នុងស្រោមសំបុត្រនោះមាន បំពង់បឺត១បាច់ ម្ជុលបារាំង ១ប្រអប់ បង់ស្អិត១ដុំ កូនកន្ត្រៃ១ និងក្រដាសថតចំលងភារកិច្ច ១ច្បាប់ ។
- ផ្ទាំងរូបភាព

**ការរៀបចំមេរៀនជាមុន**

**ការរៀបចំមេរៀនជាមុន**

**គ្រូ :** មានខ្លឹមសារមេរៀននេះ ព្រមទាំងសេចក្តីណែនាំសំរាប់លេងល្បែង

**គ្រូជំនួយ :** ចំលងលើក្រដាសផ្ទាំងធំ នូវតារាងពិន្ទុ និងបញ្ជីទាំង ២ ស្តីពីអត្ថចរិតដែលជួយសំរួលដល់ការចូលរួមរបស់សហគមន៍ និងកត្តារាំងស្ទះ ដល់ការចូលរួមរបស់សហគមន៍ ដែលស្ថិតនៅផ្នែកខាងចុងនៃមេរៀនទី២ នៃសៀវភៅណែនាំគ្រូ ។

**ការរៀបចំរបស់គ្រូ**

**រៀបចំសំភារៈសំរាប់លេងល្បែង :**

**ការរៀបចំរបស់គ្រូជំនួយ**

ត្រូវរៀបចំស្រោមសំបុត្រធំ៧៣ ដែលក្នុងស្រោមសំបុត្រនិមួយមាន បំពង់បឺតទឹកផឹកមួយ បាច់ ម្ជុលបារាំង១ប្រអប់ កូនកន្ត្រៃ១ បង់ស្អិត១ដុំ និង ក្រដាសថតចំលងភារកិច្ច១ច្បាប់ ។

**ភារកិច្ច :**

"អ្នកត្រូវសង់ប៉មមួយធ្វើអំពីបំពង់បឺតទឹកផឹកនិងសំភារៈផ្សេងៗទៀតដែលមានក្នុងស្រោមសំបុត្រ ធ្វើយ៉ាងណាឱ្យបានខ្ពស់ជាងគេ ល្អជាងគេ មាំជាងគេ និងទាន់ពេលវេលា "

## សញ្ញាផ្សេងៗដែលត្រូវបានប្រើនៅក្នុងមេរៀននិមួយៗ :

ប្រអប់ដែលហ៊ុំព័ទ្ធដោយបន្ទាត់២ជាន់ មានន័យថា នេះជាសន្លឹកមួយនៃសៀវភៅ ។ សន្លឹកផ្សេងៗនៃសៀវភៅ ជានិច្ចជាកាល ត្រូវបានគូរនៅក្នុងសៀវភៅណែនាំសំរាប់គ្រូបែបនេះ :

> ✍ ជោគជ័យនៃប្រព័ន្ធថែទាំសុខភាពដែលដឹកនាំដោយសហគមន៍ គឺពឹងផ្អែកទៅលើការចូលរួមយ៉ាងសកម្មនៃសហគមន៍ទាំងមូល: គណៈកម្មាការគ្រប់គ្រងមណ្ឌលសុខភាព ក្រុមទ្រទ្រង់សុខភាពភូមិ អាជ្ញាធរដែនដី និងសមាជិកទាំងអស់នៃសហគមន៍។

មេរៀននិមួយៗ មានលេខសំគាល់សំរាប់សកម្មភាពផ្សេងៗ ដែលមានគំរូជាឧទាហរណ៍ដូចខាងក្រោមនេះ ។

ប្រអប់ដែលបង្ហាញពីសកម្មភាព ជានិច្ចជាកាលត្រូវហ៊ុំព័ទ្ធដោយចំណុចដាច់ៗបែបនេះ

**លេខសំរាប់សំគាល់ សកម្មភាពមួយ**

**សកម្មភាព ៤.២.២** **ពិភាក្សាក្រុមតូច**

**ប្រភេទសកម្មភាព**

បំណងនៃសកម្មភាពនេះ គឺសំរាប់ឱ្យសិក្ខាកាមរំពឹងគិតពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់ពួកគេ និងពិភាក្សាថា តើអ្វីខ្លះដែលជាវិធី សំរាប់ជំរុញឱ្យសហគមន៍ចូលរួម ។

**គោលបំណងនៃសកម្មភាព**

**រយៈពេល : ១៥ នាទី**

**រយៈពេលអនុវត្តសក**

**ការណែនាំ :** ក្រុមនិមួយៗត្រូវពិភាក្សា បន្ទាប់មកសរសេរលើក្រដាសផ្ទាំងធំ :

១. តើបុគ្គលិកមណ្ឌលសុខភាពត្រូវមានអាកប្បកិរិយាយ៉ាងដូចម្តេច ដើម្បីជំរុញលើកទឹកចិត្តសហគមន៍ឱ្យចូលរួមក្នុងការសំរេចចិត្ត អំពីការថែទាំសុខភាព ?

២. តើកត្តាអ្វីខ្លះ ដែលរាំងស្ទះដល់ការចូលរួមរបស់សហគមន៍ នៅក្នុងការថែទាំសុខភាព ?

**សេចក្តីណែនាំសំរាប់សិស្ស អនុវត្តសកម្មភាពនេះ**

☞ : សញ្ញានេះ ណែនាំឱ្យធ្វើតាម

☝ : សញ្ញានេះ គឺជាចម្លើយចូលរួមរបស់គ្រូ ផ្តល់ឱ្យសិក្ខាកាមបន្ទាប់ពីបញ្ចប់សកម្មភាពនិមួយៗ

✍: សញ្ញានេះគឺជាសេចក្តីសង្ខេបរបស់គ្រូ

☺ : សញ្ញានេះគឺជាកិច្ចការដែលគ្រូជំនួយត្រូវធ្វើ ។

# សេចក្តីផ្តើមនៃម៉ូឌុលទី៧ សំរាប់
# ការអប់រំសុខភាព ~ ការលើកកំពស់សុខភាព

**រយៈពេល :** ៣០ នាទី

**វត្ថុបំណងនៃការសិក្សា :** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមទាំងអស់នឹងអាច :

១- ពន្យល់ពីខ្លឹមសារ និងការវាយតំលៃនៃម៉ូឌុលទី៧ សំរាប់សិក្ខាកាមទាំងអស់

២- វាយតំលៃពីចំណេះដឹងរបស់សិក្ខាកាមមុនសិក្សា អំពីការអប់រំសុខភាព និងលើកកំពស់សុខភាព ។

**អ្នកនឹងត្រូវការ :**

- សៀវភៅណែនាំសំរាប់គ្រូ
- សៀវភៅការងារសំរាប់សិក្ខាកាមម្នាក់ៗ
- ក្រដាសតេស្តមុនសិក្សា សំរាប់សិក្ខាកាមម្នាក់ៗ

ធ្វើការណែនាំបង្ហាញម៉ូឌុលទាំងមូលចំពោះសិក្ខាកាម ។ សុំឱ្យសិក្ខាកាមមើលសៀវភៅការងាររបស់ពួកគេត្រង់សេចក្តីផ្តើម ដើម្បីមើលពីភារកិច្ច និងវត្ថុបំណងសិក្សានៃម៉ូឌុលនេះ ។

## សៀវភៅការងារសំរាប់សិក្ខាកាមៈ សេចក្តីផ្តើម

## វត្ថុបំណងនៃម៉ូឌុល

### ១- *វត្ថុបំណងទូទៅ* :

ដើម្បីលើកកំពស់ការផ្តល់សេវារបស់មន្ត្រីសុខាភិបាលនៅថ្នាក់មណ្ឌលសុខភាព និងបង្កើនការប្រើប្រាស់សេវាសុខាភិបាល របស់ប្រជាជននៅសហគមន៍ប្រកបដោយប្រសិទ្ធភាព និងគុណភាពតាមរយៈសកម្មភាពអប់រំសុខភាព/ លើកកំពស់សុខភាព។

### ២- *វត្ថុបំណងជាក់លាក់* :

នៅចុងបញ្ចប់នៃម៉ូឌុលនេះ សិក្ខាកាមម្នាក់ៗនឹងអាច :

- ពន្យល់ថាហេតុអ្វី ប្រព័ន្ធផ្តល់ការថែទាំសុខភាពដែលដឹកនាំដោយសហគមន៍ (ប្រព័ន្ធបង្ការ) បានត្រូវយកចិត្តទុកដាក់ជាងប្រព័ន្ធព្យាបាល ។

- ពន្យល់ពីសារៈសំខាន់នៃការចូលរួមរបស់សហគមន៍ និងតំរូវការផ្នែកសុខភាពរបស់សហគមន៍ នៅក្នុងសកម្មភាពរបស់មណ្ឌលសុខភាព
- ពន្យល់ពីសារៈសំខាន់នៃការអប់រំសុខភាព និងលើកកំពស់សុខភាព ដើម្បីគាំទ្រការកែទំរង់សុខភាព នៅ កម្ពុជា ។
- ពន្យល់ពីចំណងទាក់ទងនៃការផ្សព្វផ្សាយសុខភាព ទៅនឹងការធ្វើឱ្យប្រសើរឡើងនូវសុខភាព នៅក្នុងសហគមន៍
- ពន្យល់ពីតួនាទីរបស់បុគ្គលិកមណ្ឌលសុខភាពចំពោះការផ្តត់ផ្គង់ការអប់រំសុខភាព និងការលើកកំពស់សុខភាព
- កំណត់ពីទំរង់បង្រៀនទាំង៧ជំហានក្នុងការអប់រំសុខភាព និងប្រើប្រាស់ទំរង់បង្រៀនទាំងនេះសំរាប់អប់រំ អតិថិជន នៅក្នុងកំឡុងពេលព្យាបាល ឬបន្ទាប់ពីព្យាបាលរួច
- ប្រើប្រាស់សំភារៈសំរាប់អប់រំសុខភាពប្រកបដោយប្រសិទ្ធិភាព (រូបភាពផ្ទាំងធំ សៀវភៅសន្លឹកផ្ទាត់ រូបភាពសន្លឹកបត់) ជាសំភារៈជំនួយបង្រៀន សំរាប់ការអប់រំសុខភាព
- បង្កើតទំរង់ធ្វើផែនការមួយ និងពិភាក្សាពីយន្តការនៃការធ្វើការជាមួយសហគមន៍ បុគ្គលិកសុខាភិបាលស្រុកប្រតិបត្តិ ថ្នាក់ខេត្ត និងថ្នាក់ជាតិ ដើម្បីផ្តល់នូវការលើកកំពស់សុខភាព។
- រំឭកម៉ូឌុលឡើងវិញនូវជំហានទាំង៧របស់ដំណើរការនៃការអប់រំសុខភាព តួនាទីនៃបុគ្គលិកមណ្ឌលសុខភាពនៅក្នុងការលើកកំពស់សុខភាព និងធ្វើបញ្ជីប្រភពធនធានដែលអាចរកបាន សំរាប់បុគ្គលិកមណ្ឌលសុខភាពធ្វើការ អប់រំសុខភាព និងសកម្មភាពលើកកំពស់សុខភាព។

# ផ្នែក១ : សេចក្តីត្រូវការនៃការអប់រំសុខភាព និង ការលើកកំពស់សុខភាព

## មេរៀនទី១ : ប្រព័ន្ធផ្តល់ការថែទាំសុខភាព

**១- រយៈពេល :** ៥០ នាទី

**២- វត្ថុបំណងនៃការសិក្សា :** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមទាំងអស់នឹងអាច :

១. រៀបរាប់ពីភាពខុសគ្នារវាងប្រព័ន្ធផ្តល់ការថែទាំសុខភាពដែលដឹកនាំដោយសហគមន៍ (ប្រព័ន្ធបង្ការ និង ប្រព័ន្ធព្យាបាល) មុនពេលកំណែទំរង់ប្រព័ន្ធសុខាភិបាលថ្មីត្រូវបានដាក់បញ្ចូល

២. ពន្យល់ពីសារៈប្រយោជន៍នៃប្រព័ន្ធផ្តល់ការថែទាំសុខភាពដែលដឹកនាំដោយសហគមន៍ (ប្រព័ន្ធបង្ការ)។

៣. ពន្យល់ពីចំណងទាក់ទងនៃការអប់រំសុខភាព ដើម្បីធ្វើឱ្យសុខភាពសហគមន៍ប្រសើរឡើង។

**តើមេរៀននេះជាប់ទាក់ទងយ៉ាងដូចម្តេចទៅនឹងការងាររបស់បុគ្គលិកមណ្ឌលសុខភាព ?**

មេរៀននេះនឹងជួយដល់បុគ្គលិកមណ្ឌលសុខភាព ដើម្បីឱ្យបានយល់ថាតើការអប់រំសុខភាព និងលើកកំពស់សុខភាព វាសមស្របយ៉ាងដូចម្តេចទៅនឹងរចនាសម្ព័ន្ធនៃការកែទំរង់ប្រព័ន្ធសុខាភិបាលនៅកម្ពុជា ។

**៣- សំភារៈសិក្សា និងការរៀបចំទុកជាមុន :**

**អ្នកនឹងត្រូវការ:**

- សៀវភៅណែនាំសំរាប់មណ្ឌលសុខភាព
- សំភារៈពិភាក្សាក្រុមតូច : ក្រដាសផ្ទាំងធំ / ក្រដាសប្លា ប៊ិច បង់ស្អិត
- សៀវភៅសន្លឹកផ្ទាត់

**ការរៀបចំមេរៀនជាមុនសំរាប់គ្រូ :**

១. ប្រើសៀវភៅណែនាំសំរាប់មណ្ឌលសុខភាព " ត្រង់សេចក្តីផ្តើម " ។

២. រំឮកវិធីសាស្ត្របង្រៀនតាមបែបចូលរួមឡើងវិញ **ពិភាក្សាតាមចិត្ត** និង **ពិភាក្សាក្រុមតូច** ដែលមាននៅផ្នែកខាងក្រោយ នៃសៀវភៅនេះ ។

៣. ត្រៀមរៀបចំធ្វើសេចក្តីសង្ខេប ដែលមានក្នុងសៀវភៅណែនាំសំរាប់គ្រូនៅចុងបញ្ចប់នៃមេរៀន ។

**គ្រូជំនួយ :**

១. ត្រៀមជាស្រេចនូវក្រដាសផ្ទាំងធំ/ក្រដាសប្លា ប៊ិច និងហ្វឺតសសេរក្រដាសប្លាសំរាប់ពិភាក្សាក្រុមតូច។

២. ត្រៀមជាស្រេចនូវបង់ស្អិត ដើម្បីបិទក្រដាសផ្ទាំងធំ ឬ (OHP) សំរាប់បង្ហាញ។

## ៤- សកម្មភាព :

### វត្ថុបំណងទី១: រៀបរាប់ពីភាពខុសគ្នារវាងប្រព័ន្ធផ្តល់ការថែទាំសុខភាពដែលដឹកនាំដោយសហគមន៍ (ប្រព័ន្ធបង្ការ និង ប្រព័ន្ធព្យាបាល) មុនពេលកំណែទំរង់ប្រព័ន្ធសុខាភិបាលថ្មីត្រូវបានដាក់បញ្ចូល

☞ គ្រូត្រូវដកស្រង់ខ្លឹមសារចេញពីសៀវភៅណែនាំសំរាប់មណ្ឌលសុខភាព ស្តីពីកំណែទំរង់ប្រព័ន្ធសុខាភិបាលថ្មី ត្រង់ទំព័រទី៤ ។ វត្ថុបំណងនៃកំណែទំរង់នេះ គឺដើម្បីចែករំលែកមូលដ្ឋានសុខាភិបាលឱ្យស្មើគ្នា នៅក្នុងការផ្តល់សេវាសុខភាពដែលមានគុណភាពទៅដល់ប្រជាជនទូទាំងប្រទេស " ។

☞ រៀបចំសិក្ខាកាមសំរាប់ធ្វើការពិភាក្សាតាមចិត្ត ។ សេចក្តីណែនាំនេះត្រូវបានរកឃើញផងដែរ នៅក្នុងសៀវភៅការងារសំរាប់សិក្ខាកាមត្រង់ទំព័រទី៥ ។ សិក្ខាកាមប្រហែលអាចនឹងមិនយល់ពី " **ការពិភាក្សាតាមចិត្ត** " ។ គ្រូត្រូវពន្យល់ថាអ្វីខ្លះ ដែលពួកគេត្រូវធ្វើ ដោយប្រើឯកសារសំអាងនៅខាងចុងនៃសៀវភៅនេះត្រង់ទំព័រទី ១០៨ ដាក់ថា **វិធីសាស្ត្របង្រៀន តាមបែបចូលរួម** ។

*សេចក្តីណែនាំនេះ មានស្ទួននៅក្នុងសៀវភៅការងារសំរាប់សិក្ខាកាម*

**សកម្មភាព ៤-១-១ ពិភាក្សាតាមចិត្ត**

បំណងនៃសកម្មភាពនេះគឺណែនាំឱ្យសិក្ខាកាមគិតថា តើអ្វីខ្លះដែលពួកគេបានដឹងរួចហើយ អំពីប្រព័ន្ធថែទាំសុខភាពនៅកម្ពុជា ។

**រយៈពេល** : ៣ នាទី

**ការណែនាំ** : សិក្ខាកាមត្រូវរៀបរាប់ប្រព័ន្ធនៃការផ្តល់ការថែទាំសុខភាព ( សេវាថែទាំសុខភាពបែបវិទ្យាសាស្ត្រ ) មុនពេលកំណែទំរង់ប្រព័ន្ធសុខាភិបាលថ្មីត្រូវបានដាក់បញ្ចូល ។

**សំណួរ** : តើប្រព័ន្ធផ្តល់ការថែទាំសុខភាព មុនពេលកំណែទំរង់ប្រព័ន្ធសុខាភិបាលថ្មីត្រូវបានដាក់បញ្ចូល មានលក្ខណៈយ៉ាងដូចម្តេច?

☞ រៀបចំសិក្ខាកាមសំរាប់ពិភាក្សាក្រុមតូច ដោយប្រើឯកសារសំអាងនៅខាងចុងនៃសៀវភៅនេះត្រង់ទំព័រ១០៨ ដាក់ថា " **វិធីសាស្ត្របង្រៀនតាមបែបចូលរួម** " ។ ចែកសិក្ខាកាមជា៣ក្រុម បើមានច្រើនក្រុមអាចពិភាក្សាសំណួរដូចគ្នា ។ គ្រូជំនួយត្រូវចែកក្រដាសផ្ទាំងធំ / ក្រដាសថ្លា និងហ្វឺត ទៅឱ្យក្រុមនិមួយ ៗ ។

☞ គ្រូត្រូវរៀបចំសិក្ខាកាម សំរាប់សកម្មភាពពិភាក្សាក្រុមតូច

*សេចក្តីណែនាំនេះមានស្ទួននៅក្នុងសៀវភៅការងារសំរាប់សិក្ខាកាម*

**សកម្មភាព ៤-១-២ ពិភាក្សាក្រុមតូច**

បំណងនៃសកម្មភាពនេះ គឺណែនាំសិក្ខាកាមឱ្យចែករំលែកការយល់ដឹងរបស់ពួកគេ អំពីកំណែទំរង់ប្រព័ន្ធសុខាភិបាលថ្មី។

**រយៈពេល :** ១០ នាទី

**ការណែនាំ :**

- **ក្រុម១ :** ប្រៀបធៀបប្រពន្ធ័ថែទាំសុខភាពបែបចាស់និងប្រព័ន្ធថែទាំសុខភាពបែបថ្មីខុសគ្នាយ៉ាងដូចម្តេច?
- **ក្រុម២ :** តើការបែងចែកមូលដ្ឋានសុខាភិបាលឱ្យស្មើគ្នា ក្នុងការផ្តល់សេវាសុខភាពដែលមានគុណភាព ទៅដល់ប្រជាជនទូទាំងប្រទេសមានន័យយ៉ាងដូចម្តេច ?
- **ក្រុម៣ :** តើបញ្ហាអ្វីខ្លះដែលអាចកើតមាននៅពេលអនុវត្តកំណែទំរង់ប្រពន្ធ័សុខាភិបាលថ្មី ?

**បង្ហាញលទ្ធផល និង ពិភាក្សា :**

- តំណាងក្រុមនិមួយៗឡើងបង្ហាញលទ្ធផល ( ៥នាទីក្នុង១ក្រុម )
- ទុកពេលអោយសិក្ខាកាមឯទៀតសួរ ឬផ្តល់យោបល់ និងតំណាងក្រុមបកស្រាយ
- ផ្តល់ចម្លើយចូលរួមរបស់គ្រូ

☝ **ចម្លើយចូលរួម :**

**ការប្រៀបធៀបប្រពន្ធ័ថែទាំសុខភាពចាស់ និង ថ្មី :**

| **ប្រពន្ធ័ថែទាំសុខភាពចាស់ ៖** | **ប្រពន្ធ័ថែទាំសុខភាពថ្មី ៖** |
|---|---|
| • ខេត្តមួយមានមន្ទីរពេទ្យខេត្តមួយ | • ខេត្តមួយមានមន្ទីរពេទ្យបង្អែក |
| • ស្រុកមួយមានមន្ទីរពេទ្យស្រុកមួយ | • ប្រជាជន ៨០០០០-១២០០០០នាក់=ស្រុកប្រតិបត្តិ១ |
| • ឃុំមួយមានគិលានដ្ឋានឃុំមួយ | • ប្រជាជន ១០០០០នាក់=មណ្ឌលសុខភាព១ |

**ការបែងចែកមូលដ្ឋានសុខាភិបាលឱ្យស្មើគ្នា:**

- ប្រជាជនមានជាមធ្យមពី ៨០០០ ទៅ ១២០០០ នាក់
- មានកញ្ចប់ MPA

- បុគ្គលិកមានជំនាញ MPA ពី ៦ ទៅ ៩ នាក់
- សេវា MPA មានគ្រប់មណ្ឌលសុខភាព

**បញ្ហាដែលអាចកើតមាននៅពេលអនុវត្តគំណែទំរង់ប្រព័ន្ធសុខាភិបាលថ្មី :**

- ភូមិសាស្ត្រដាច់ស្រយាល ដែលមិនអាចមកប្រើសេវាបាន / លំបាកមកប្រើ
- សាងសង់មិនចំ ចំណុចកណ្តាល
- សង់មណ្ឌលសុខភាពយឺតយ៉ាវ
- ផ្លូវពិបាក
- គ្មានពេទ្យប្រចាំការ ខ្វះបុគ្គលិក/បុគ្គលិកមិនគ្រប់គ្រាន់ចំពោះតំបន់ដាច់ស្រយាល
- មន្ទីរពេទ្យស្រុកចាស់ ក្លាយជាមណ្ឌលសុខភាព បុគ្គលិកកកកុញ ។

## វត្ថុបំណងទី២: ពន្យល់ពីសារៈប្រយោជន៍នៃប្រព័ន្ធផ្តល់ការថែទាំសុខភាពដែលដឹកនាំដោយសហគមន៍

*សេចក្តីណែនាំនេះមាននៅក្នុងសៀវភៅការងារសំរាប់សិក្ខាកាម*

**សកម្មភាព ៤-២-១** **ពិភាក្សាក្រុមធំ**

បំណងនៃសកម្មភាពនេះ គឺណែនាំឱ្យសិក្ខាកាមពិនិត្យលើរូបភាព រួចពិភាក្សា ពីសារៈប្រយោជន៍នៃការផ្តល់ការថែទាំសុខភាពដែលដឹកនាំដោយសហគមន៍ ។

**រយៈពេល :** ១០នាទី

**ការណែនាំ :** - បង្ហាញរូបភាពទាំង៣ទៅសិក្ខាកាមទាំងមូល រួចពិភាក្សារូបភាពម្តងមួយៗ

- សំណួរសំរាប់រូបនិមួយៗ : តើរូបភាពនេះ មានន័យដូចម្តេច? (បង្ហាញរូបភាពម្តងមួយៗ)

**ប្រមូលពត៌មានត្រឡប់ និង ពិភាក្សា** (រយៈពេល ៥នាទី)

☞ គ្រូសួរទៅសិក្ខាកាមដើម្បីទទួលបាននូវពត៌មានត្រឡប់ ។

☞ គ្រូជំនួយកត់ត្រាចម្លើយសិក្ខាកាមលើក្តារខៀន

☞ គ្រូធ្វើការសំរបសំរួលចម្លើយចូលរួមរបស់សិក្ខាកាម រួមធ្វើសេចក្តីសន្និដ្ឋាន ពីសារៈប្រយោជន៍នៃការផ្តល់ការថែទាំសុខភាពដែលដឹកនាំដោយសហគមន៍ (ប្រព័ន្ធបង្ការ) ។



ប្រភេទនៃការថែរក្សាសុខភាព - បែបបូរាណ



ប្រភេទនៃការថែរក្សាសុខភាព - បែបវិទ្យាសាស្ត្រ



ប្រភេទនៃការថែរក្សាសុខភាព - តាមសហគមន៍

**វត្ថុបំណងទី៣: ពន្យល់ពីចំណងទាក់ទងនៃការអប់រំសុខភាព ដើម្បីធ្វើឱ្យសុខភាពសហគមន៍ប្រសើរឡើង**

*សេចក្តីណែនាំនេះមានស្ទួននៅក្នុងសៀវភៅការងារសំរាប់សិក្ខាកាម*

**សកម្មភាព ៤-៣-១** **ពិភាក្សាក្រុមធំ**

បំណងនៃសកម្មភាពនេះគឺណែនាំសិក្ខាកាមឱ្យពិភាក្សាពីចំណងទាក់ទងនៃការអប់រំសុខភាព ដើម្បីធ្វើឱ្យសុខភាពសហគមន៍ប្រសើរឡើង។

**រយៈពេល :** ១០នាទី

**ការណែនាំ :**

- ផ្អែកតាមលទ្ធផលពិភាក្សាខាងលើ ឱ្យសិក្ខាកាមពន្យល់ថា តើត្រូវធ្វើការអប់រំសុខភាព ដល់សហគមន៍ យ៉ាងដូចម្តេច ដើម្បីឱ្យសុខភាពសហគមន៍ប្រសើរឡើង?

**ប្រមូលពត៌មានត្រឡប់ និង ពិភាក្សា** (រយៈពេល ៥នាទី)

☞ គ្រូសួរទៅសិក្ខាកាមដើម្បីទទួលបាននូវពត៌មានត្រឡប់។

☞ គ្រូជំនួយកត់ត្រាចម្លើយចូលរួមរបស់សិក្ខាកាម

☞ គ្រូធ្វើការសំរបសំរួលចម្លើយចូលរួមរបស់សិក្ខាកាម រួមធ្វើសេចក្តីសន្និដ្ឋាន

✍ **សេចក្តីសន្និដ្ឋាន :** គ្រូត្រូវអានសេចក្តីសន្និដ្ឋាននេះ

*សេចក្តីណែនាំនេះ មានស្ទួននៅក្នុងសៀវភៅការងារសំរាប់សិក្ខាកាម*

✍ ជោគជ័យនៃប្រព័ន្ធថែទាំសុខភាព ដែលដឹកនាំដោយសហគមន៍ គឺពឹងផ្អែកទៅលើការចូលរួមយ៉ាងសកម្មរបស់សហគមន៍ទាំងមូលៈ គណៈកម្មការគ្រប់គ្រងមណ្ឌលសុខភាព ក្រុមទ្រទ្រង់សុខភាពភូមិ អាជ្ញាធរដែនដី.... និងសមាជិកទាំងអស់នៃសហគមន៍ ។

# មេរៀនទី២ : ការចូលរួមរបស់សហគមន៍

**១- រយៈពេល :** ២ ម៉ោង

**២- វត្ថុបំណងនៃការសិក្សា :** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមទាំងអស់ នឹងអាច :

១. រៀបរាប់ពីអត្ថប្រយោជន៍នៃការចូលរួមរបស់សហគមន៍

២. រៀបរាប់នូវមធ្យោបាយ ដើម្បីជំរុញឱ្យសហគមន៍ចូលរួមនិងកត្តារាំងស្ទះដល់ការចូលរួមរបស់សហគមន៍។

**តើមេរៀននេះជាប់ទាក់ទងយ៉ាងដូចម្តេចទៅនឹងការងាររបស់បុគ្គលិកមណ្ឌលសុខភាព ?**

ជំហាននេះពន្យល់ពីសារៈសំខាន់នៃការចូលរួមរបស់សហគមន៍នៅក្នុងការសំរេចចិត្តអំពីការថែទាំសុខភាព និងផ្តល់ឱ្យសិក្ខាកាមនូវមធ្យោបាយខ្លះៗ ដើម្បីជួយឱ្យមានការចូលរួមរបស់សហគមន៍ ។

**៣- សំភារៈ និង ការរៀបចំទុកជាមុន :**

**អ្នកនឹងត្រូវការ**

- ផ្ទាំងក្រដាសផ្ទាំងធំ ប៊ិច បង់ស្អិត ក្តារខៀន ហ្វឺត ប្រដាប់លុប
- ស្រោមសំបុត្រធំ ដែលនៅក្នុងស្រោមសំបុត្រនិមួយៗមាន បំពង់បឺត១បាច់ ម្ជុលបារាំង១ប្រអប់ បង់ស្អិត១ដុំ កូនកន្ត្រៃ១ និងក្រដាសចតចំលងភារៈកិច្ច១ច្បាប់ ។
- រូបភាពផ្ទាំងធំ M7.P.01, M7.P.02, M7.P.03, M7.P.04

**ការរៀបចំមេរៀនជាមុន**

**គ្រូ :** អានខ្លឹមសារមេរៀននេះ ព្រមទាំងសេចក្តីណែនាំសំរាប់លេងល្បែង

**គ្រូជំនួយ :** ចំលងលើក្រដាសសរសេរផ្ទាំងធំនូវតារាងពិន្ទុ (ទំព័រទី៣៣) និងបញ្ជីទាំងពីរស្តីពី **អាកប្បកិរិយាដែលជួយសំរួលដល់ការចូលរួមរបស់សហគមន៍** និង**កត្តារាំងស្ទះដល់ការចូលរួមរបស់សហគមន៍** (ទំព័រទី៣៦)។

**រៀបចំសំភារៈសំរាប់លេងល្បែង:**

ត្រូវរៀបចំស្រោមសំបុត្រធំៗ៣ ដែលក្នុងស្រោមសំបុត្រនិមួយមាន បំពង់បឺតមួយបាច់ ម្ជុលបារាំង១ប្រអប់ កូនកន្ត្រៃ ១ បង់ស្អិត១ដុំ និងក្រដាសចតចំលងភារកិច្ច១ច្បាប់ ។

**ភារកិច្ច:**

"អ្នកត្រូវសង់ប៉មមួយធ្វើអំពីបំពង់បឺតទឹកផឹក និងសំភារៈផ្សេងៗទៀតដែលមានក្នុងស្រោមសំបុត្រ ធ្វើយ៉ាងណាឱ្យបាន **ខ្ពស់ជាងគេ ល្អជាងគេ មាំជាងគេ លឿនជាងគេ និងទាន់ពេលវេលា** "។

## វត្ថុបំណងទី១ : រៀបរាប់ពីអត្ថប្រយោជន៍នៃការចូលរួមរបស់សហគមន៍

☞ គ្រូធ្វើការណែនាំពីការលេងល្បែងមួយដោយលើកបង្ហាញថាល្បែងនេះ មានគោលបំណងលើកទឹកចិត្តសិក្ខាកាម ឱ្យគិតអំពីការចូលរួមរបស់សហគមន៍ ។

*សេចក្តីណែនាំនេះមានស្ទួននៅក្នុងសៀវភៅការងាររបស់សិក្ខាកាម :*

**សកម្មភាព ៤-១-១ ល្បែង : ការចូលរួម**

បំណងនៃល្បែងនេះ គឺដើម្បីបានជាបទពិសោធន៍នៃរឿងរ៉ាវដែលទាក់ទងដល់ការចូលរួមរបស់សហគមន៍ ។

**ការណែនាំ :**

- គ្រូត្រូវបែងចែកសិក្ខាកាមជា៣ក្រុម ក្រុមនិមួយៗត្រូវជ្រើសរើសអ្នកសំរបសំរួលម្នាក់ អ្នកសង្កេតម្នាក់ ។
- គ្រូជំនួយត្រូវផ្តល់ឱ្យក្រុមនិមួយៗនូវស្រោមសំបុត្រធំមួយ ដែលនៅក្នុងនោះមាន បំពង់បឺត១បាច់ ម្ជុលបារាំង ១ប្រអប់ បង់ស្អិត១ដុំ កូនកន្ត្រៃ១ និងក្រដាសថតចំលងភារកិច្ច១ច្បាប់ ។

**រយៈពេល : ៣០ នាទី**

គ្រូពន្យល់បន្ថែមពីភារកិច្ចដែលក្រុមនិមួយៗត្រូវធ្វើ :

- អ្នកសង្កេត មានតួនាទីសង្កេត និងកត់សំគាល់ទៅលើសកម្មភាពផ្សេងៗ ដែលសមាជិកក្នុងក្រុមរបស់ខ្លួន បានធ្វើ ដោយសំអាងលើចំណុចទាំង៥ ( ១.មានអ្នកដឹកនាំដែរឬទេ? ២.មានអ្នកគួរបង្គាប់ដែរឬទេ? ៣.មានអ្នកសកម្មឬទេ? ៤.ប្រើប្រាស់សំភារៈអស់ឬទេ? ៥.សល់ពេលវេលាឬទេ?) នៅលើទំព័រ៣៣ (សៀវភៅណែនាំសំរាប់គ្រូ)
- សមាជិកដទៃទៀតត្រូវសង់ប៉មមួយ ដោយប្រើប្រាស់បំពង់បឺត រួមផ្សំនឹងសំភារៈផ្សេងៗទៀត ដែលមានក្នុងស្រោមសំបុត្រ ធ្វើយ៉ាងណាឱ្យ ខ្ពស់ជាងគេ ល្អជាងគេ មាំជាងគេ និងលឿនជាងគេ ។

**បង្ហាញប៉មដែលសាងសង់រួចរបស់ក្រុមទាំង៣ :**

- តំណាងក្រុមនិមួយៗ ត្រូវយកប៉មដែលសាងសង់រួចមកដាក់តំរៀបគ្នាដើម្បីដាក់ពិន្ទុ :
    - ល្អជាងគេ : ៣ ពិន្ទុ
    - មធ្យម : ២ ពិន្ទុ
    - អន់ជាងគេ : ១ ពិន្ទុ

**តារាងពិន្ទុ**

| | ក្រុម ១ | ក្រុម ២ | ក្រុម ៣ |
|---|---|---|---|
| | ល្អ : ៣ , មធ្យម: ២ , អន់ :១ | ល្អ : ៣ , មធ្យម: ២ , អន់ :១ | ល្អ : ៣ , មធ្យម: ២ , អន់ :១ |
| កំពស់ | | | |
| សោភ័ណភាព | | | |
| មាំជាងគេ | | | |
| ពេលវេលា | | | |
| **ពិន្ទុសរុប** | | | |

គ្រូត្រូវសួរទៅសិក្ខាកាមដែលសង្កេតតាមក្រុមនិមួយៗថា :

- តើមានភាពខុសគ្នាអ្វីខ្លះរវាងអាកប្បកិរិយានៃក្រុមនិមួយៗ នៅពេលដែលពួកគេកំពុងធ្វើការងារ តាមភារកិច្ចរបស់ពួកគេ?
- តើមានអ្វីខ្លះ ដែលធ្វើឱ្យបរាជ័យកើតឡើងដោយសារសមាជិកក្រុម និង
- តើពួកគេដោះស្រាយយ៉ាងដូចម្តេច ?

គ្រូត្រូវសួរទៅសមាជិកក្រុមនិមួយៗថា :

- តើពួកគេទទួលអារម្មណ៍ដូចម្តេចនៅពេលដែលពួកគេកំពុងបំពេញភារកិច្ចនោះ?

គ្រូឱ្យអ្នកសង្កេតការណ៍ឡើងរាយការណ៍ ដោយស្មោះត្រង់ ដោយផ្តោតទៅលើក្រុមនិមួយៗមាន:

- មានអ្នកដឹកនាំដែរឬទេ?
- មានអ្នកគួរប្លង់ដែរឬទេ?
- មានអ្នកសកម្មឬទេ?
- ប្រើប្រាស់សំភារៈអស់ឬទេ?
- សល់ពេលវេលាឬទេ?

គ្រូត្រូវទាញរកលទ្ធផលរបស់ក្រុមទាំង៣ដែលបានពីអ្នកសង្កេត ដើម្បីបង្ហាញពីផលប្រយោជន៍ នៃសកម្មភាពចូលរួម ។

## វត្ថុបំណងទី ២ : រៀបរាប់នូវមធ្យោបាយដើម្បីជំរុញឱ្យសហគមន៍ចូលរួម និងកត្តារាំងស្ទះដល់ការចូលរួមរបស់សហគមន៍

**ការដាក់តាំងរូបភាព** (Illustration) **និង ការបង្ហាញរូបភាព** M7.P.01, M7.P.02, M7.P.03, M7.P.04

☞ គ្រូដាក់តាំងរូបភាពធំៗបន្តបន្ទាប់ នៃបុគ្គលិកមណ្ឌលសុខភាពម្នាក់ :

- ចេញទៅក្នុងភូមិកំពុងឈរនិយាយជាមួយប្រជាជន ។
- ចេញទៅក្នុងភូមិ កំពុងអង្គុយនៅលើកំរាលឥដ្ឋនៃផ្ទះមួយ ធ្វើការថែទាំទារកម្នាក់ ក្នុងពេលបញ្ចុកចំណីអាហារ ដោយឱ្យវាផឹកទឹកនឹងស្លាបព្រា ។
- កំពុងឈរនៅក្នុងមណ្ឌលសុខភាព ហើយចង្អុលទៅលើផ្ទាំងរូបភាពមួយ ដោយមានប្រជាជនមួយក្រុមអង្គុយសម្លឹងមើល ។
- អង្គុយនៅលើកំរាលឥដ្ឋនៅក្នុងផ្ទះមួយ ដោយមានម្តាយព្រមជាមួយទារក និងកុមារអង្គុយព័ទ្ធជុំវិញម្តាយម្នាក់កំពុងធ្វើបង្ហាញថា តើគាត់បញ្ចុកចំណីអាហារកូនរបស់គាត់យ៉ាងដូចម្តេច ។

*សេចក្តីណែនាំនេះមានស្ទួននៅក្នុងសៀវភៅការងារសំរាប់សិក្ខាកាម*

**សកម្មភាព ៤-២-១ ពិភាក្សាក្រុមតូច**

បំណងនៃសកម្មភាពនេះ គឺណែនាំសិក្ខាកាមឱ្យប្រើរូបភាពដែលដាក់តាំង ដើម្បីផ្តល់ការយកចិត្តទុកដាក់ពីកំរិតខុសគ្នានៃការចូលរួមរបស់សហគមន៍ ។

**រយៈពេល** : ២០ នាទី

**ការណែនាំ** : ផ្តល់រូបភាពទាំង៤ផ្ទាំងទៅក្រុម ។ ក្រុមនិមួយៗត្រូវ :

- មើលរូបភាពផ្ទាំងធំ
- តំរៀបវាតាមកំរិតនៃការចូលរួម
- ត្រៀមរៀបចំដើម្បីពន្យល់ទៅសិក្ខាកាមនៅក្រុមដទៃទៀតថា ហេតុអ្វីបានជាធ្វើការសំរេចចិត្តរៀបរូបភាពតាមលំដាប់លំដោយយ៉ាងនេះ?

**បង្ហាញលទ្ធផល និង ពិភាក្សា :**

- តំណាងក្រុមនិមួយៗឡើងបង្ហាញលទ្ធផល ( ៥នាទីក្នុងមួយក្រុម )
- ទុកពេលអោយសិក្ខាកាមឯទៀតៗសួរ ឬផ្តល់យោបល់ បន្ទាប់មកតំណាងក្រុមបកស្រាយ (ឧ. ឱ្យសមាជិកម្នាក់ៗនៃក្រុមតូចនិមួយៗ មកផ្នែកម្ខាងនៃថ្នាក់រៀន ហើយតំរៀបរូបភាព ដោយសំអាងលើការពិភាក្សារបស់ក្រុមពួកគេ ។ គ្រូសួរទៅសមាជិកនៃក្រុមនេះ ឱ្យពន្យល់ពីមូលហេតុនៃការពិភាក្សា ដែលត្រូវសំរេចចិត្តតំរៀបរូបភាពតាមលំដាប់លំដោយយ៉ាងនេះ។ សមាជិកនៅក្នុងក្រុមរបស់ខ្លួន អាចពន្យល់ទៅក្រុមធំ ពីការសំរេចចិត្តត្រង់ណាដែលសមាជិកនៅក្នុងក្រុមតូចរបស់ខ្លួនបានឯកភាពគ្នា ហើយត្រង់ណាដែលសមាជិកក្នុង ក្រុមតូចមិនបានឯកភាពគ្នា។ )

☝ **ចំលើយចូលរួម** : លំដាប់នៃការចូលរួមរបស់សហគមន៍ គឺរូបភាព P01, P02, P03, P04 ។

☞ គ្រូត្រូវអានសេចក្តីសង្ខេបត្រង់**ឥទ្ធិពលនៃដៃគូការងារទៅលើសុខភាពសហគមន៍** ដើម្បីបង្ហាញឱ្យឃើញនូវមធ្យោបាយដើម្បីជំរុញឱ្យសហគមន៍ចូលរួម ។

✍ **សង្ខេប:** *សេចក្តីណែនាំនេះមានស្នូននៅក្នុងសៀវភៅការងាររបស់សិក្ខាកាម*

**ឥទ្ធិពលនៃដៃគូការងារទៅលើសុខភាពសហគមន៍**

- ប្រសិនបើមនុស្សនៅក្នុងសហគមន៍បានចូលរួមយ៉ាងសកម្មក្នុងការសំរេចអំពីបញ្ហាសុខភាព នោះលទ្ធផលប្រហែលបានច្រើនជាងការផ្សព្វផ្សាយអំពីសារៈសំខាន់នៃសុខភាពនៅក្នុងសហគមន៍ ។
- ប្រសិនបើប្រជាជនរៀនដោយខ្លួនឯង អំពីការផ្លាស់ប្តូរការប្រព្រឹត្ត ដែលធ្វើឱ្យប៉ះពាល់ដល់សុខភាព ដោយមានការជួយពន្យល់ពីបុគ្គលិកសុខាភិបាល នោះការផ្លាស់ប្តូរការប្រព្រឹត្តដែលបានធ្វើ ប្រហែលជាស្ថិតនៅជា អចិន្ត្រៃយ៍ ទោះជាមាន ឬគ្មានការឧបត្ថម្ភជាមូលនិធិក៏ដោយ ។
- សហគមន៍បានត្រូវការពារពីការកេងប្រវ័ញ្ចពីមនុស្សទាំងឡាយណា ដែលបានទទួលផលលើសលុបពីការលក់សេវាសុខភាពទៅឱ្យអ្នកជម្ងឺ ឧ. ដោយក្រុមហ៊ុន ក្រុមហ៊ុនផលិតឱសថ អ្នកលក់ អ្នកចែកចាយ អ្នកអនុវត្តន៍ ធ្វើពេទ្យ
- ផ្តល់មោទនភាពទៅអ្នកក្រ ដែលពួកគេជាញឹកញាប់ មិនអាចទទួលបានការថែទាំសុខភាព ដែលផ្តល់ដោយប្រព័ន្ធព្យាបាលតាមបែបវិទ្យាសាស្ត្រ ។
- សហគមន៍ក្លាយជាអ្នកគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព នូវការថែទាំសុខភាពផ្ទាល់ខ្លួនរបស់ពួកគេ ។
- ជោគជ័យមួយបង្កើតឱ្យមានជោគជ័យមួយទៀត ពីព្រោះប្រជាជនមើលឃើញ ការចំណេញនៃការចូលរួម ដូច្នេះពួកគេនឹងត្រៀមដើម្បីចូលរួមកាន់តែច្រើនឡើង ហើយ មធ្យោបាយនានា សំភារៈ នឹងត្រូវបានថែរក្សា និងថែទាំ ដូចជា អណ្តូងទឹក មណ្ឌលសុខភាព ។ល។

☞ គ្រូត្រូវរៀបចំសិក្ខាកាមសំរាប់ពិភាក្សាក្រុមតូច ។

*សេចក្តីណែនាំនេះមានស្នូននៅក្នុងសៀវភៅការងារសំរាប់សិក្ខាកាម*

**សកម្មភាព ៤-២-២ ពិភាក្សាក្រុមតូច**

បំណងនៃសកម្មភាពនេះ គឺសំរាប់ឱ្យសិក្ខាកាមរំពឹងគិតពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់ពួកគេ និងពិភាក្សាថា តើអ្វីខ្លះ ដែលជាមធ្យោបាយ ដើម្បីជំរុញឱ្យសហគមន៍ចូលរួម ។

**រយៈពេល: ១៥ នាទី**

**ការណែនាំ:** ក្រុមនិមួយៗត្រូវពិភាក្សា បន្ទាប់មកសរសេរលើក្រដាសផ្ទាំងធំ

១. តើបុគ្គលិកមណ្ឌលសុខភាព ត្រូវមានអាកប្បកិរិយាយ៉ាងដូចម្តេច ដើម្បីជំរុញលើកទឹកចិត្តឱ្យសហគមន៍ ឱ្យចូលរួមក្នុងការសំរេចចិត្តអំពីការថែទាំសុខភាព ?

២. តើកត្តាអ្វីខ្លះ ដែលរាំងស្ទះដល់ការចូលរួមរបស់សហគមន៍ នៅក្នុងការថែទាំសុខភាព ?

**បង្ហាញលទ្ធផល និង ពិភាក្សា :**

- តំណាងក្រុមនិមួយៗឡើងបង្ហាញលទ្ធផល ( ៥នាទីក្នុង១ក្រុម )
- ទុកពេលអោយសិក្ខាកាមឯទៀតៗសួរ ឬផ្តល់យោបល់ និងតំណាងក្រុមបកស្រាយ
- ផ្តល់ចំឡើយចូលរួមរបស់គ្រូ
    - ☞ **ចំលើយចូលរួម :**

**អាកប្បកិរិយាដែលជួយសំរួលដល់ការចូលរួមរបស់សហគមន៏**

- ចែករំលែកចំណេះដឹង និងជំនាញ
- ចេះបត់បែន អនុគ្រោះចំពោះកំហុសដែលបានធ្វើរួច
- ទៀងត្រង់ចំពោះអ្នកដទៃ
- ផ្តល់នូវការគោរព
- យកយោបល់ក្រុមជាធំ

**កត្តាដែលរាំងស្ទះដល់ការចូលរួមរបស់សហគមន៏**

- **រាំងស្ទះនៅក្នុងសហគមន៏ :** ការរំពឹងគិតរបស់សហគមន៏ថា អ្នកដទៃទៀតនឹងផ្តល់នូវប្រភពធនធាន និងដោះស្រាយបញ្ហាជំនួសពួកគេ ។
- **រាំងស្ទះបណ្តាលមកពីវិជ្ជាជីវៈ :** ចំណូលរកបានពីចំណេះដឹងនិងជំនាញឯកទេស ប្រសិនបើយើងចែករំលែកចំណេះដឹង ជំនាញនេះ ចំណូលរកបានរបស់យើងនឹងត្រូវបានកាត់បន្ថយ ឬថយចុះ ។
- **រាំងស្ទះបណ្តាលមកពីរដ្ឋាភិបាលៈ** ក្នុងគោលបំណងដើម្បីដាក់ឱ្យអនុវត្តនូវការផ្លាស់ប្តូរបានឆាប់រហ័សមួយជួនកាល រដ្ឋាភិបាលដាក់វិធានការឱ្យផ្លាស់ប្តូអាកប្បកិរិយា និងត្រួតពិនិត្យលើការប្រើប្រាស់ប្រភពធនធានឆាប់រហ័សពេក
- **រាំងស្ទះនៅក្នុងខ្លួនយើងផ្ទាល់ :** ការធ្វើអ្វីៗដោយខ្លួនឯងជាជាង ធ្វើអ្វីដែលនាំសំដៅទៅរកការសហការជាមួយអ្នកឯទៀត ។

✍ **សង្ខេបៈ**

- ចូររៀបរាប់ពីអត្ថប្រយោជន៏នៃការចូលរួមនៅក្នុងសហគមន៏?
- តើបុគ្គលិកមណ្ឌលសុខភាពត្រូវមានអាកប្បកិរិយាដូចម្តេច ដើម្បីលើកទឹកចិត្តអោយសហគមន៏ចូលរួម?

# មេរៀនទី៣ : គំរូនៃការសុខភាព

**១- រយៈពេល :** ១ ម៉ោង ៣០ នាទី

**២- វត្ថុបំណងនៃការសិក្សា :** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមទាំងអស់ នឹងអាច :

១. ផ្តល់ឧទាហរណ៍នៃគំរូវការសុខភាពផ្នែកអារម្មណ៍ និងគំរូវការសុខភាពពិតប្រាកដ។

២. បំពេញនៅក្នុងតារាងនូវគំរូវការសុខភាពផ្នែកអារម្មណ៍ និងគំរូវការសុខភាពពិតប្រាកដ ។

**តើមេរៀននេះទាក់ទងយ៉ាងដូចម្តេចទៅនឹងការងាររបស់បុគ្គលិកមណ្ឌលសុខភាព?**

ពន្យល់ថា តើត្រូវស្គាល់គំរូវការសុខភាពផ្នែកអារម្មណ៍នៃសហគមន៍ យ៉ាងដូចម្តេច?

**៣- សំភារៈ និង ការរៀបចំជាមុន**

**អ្នកនឹងត្រូវការ**

- ក្រដាសផ្ទាំងធំ / ក្រដាសផ្ទា ប៊ិច
- សៀវភៅសន្លឹកផ្ទាត់
- រូបភាព (ស្តីពី : ១- គំរូវការសុខភាពផ្នែកអារម្មណ៍ ២- គំរូវការសុខភាពពិតប្រាកដ ៣-ការអប់រំសុខភាពនៅសហគមន៍)

**ការរៀបចំមេរៀនជាមុន**

**គ្រូ :** មើលខ្លឹមសារមេរៀននេះ ជាពិសេសនិយមន័យនៃគំរូវការសុខភាពផ្នែកអារម្មណ៍ និងនិយមន័យគំរូវការសុខភាពពិតប្រាកដ ។ គ្រូត្រូវប្រើរូបភាព ដើម្បីពន្យល់ពីនិយមន័យ ។

**គ្រូជំនួយ :**

១. ចម្លងនៅលើក្រដាសផ្ទាំងធំ ដើម្បីទុកពន្យល់ពី **គំរូវការសុខភាពផ្នែកអារម្មណ៍ និង គំរូវការសុខភាពពិតប្រាកដ** ដែលមាននៅក្នុងសៀវភៅណែនាំគ្រូត្រង់ទំព័រ៣៧ និង៣៨។

២. គូរតារាងមួយជាឧទាហរណ៍ នៅលើក្រដាសផ្ទាំងធំ ដែលមាននៅក្នុងសៀវភៅណែនាំសំរាប់គ្រូត្រង់ទំព័រ៣៩ ។

**៤-សកម្មភាព**

## វត្ថុបំណងទី១: ផ្តល់ឧទាហរណ៍នៃគំរូវការសុខភាពផ្នែកអារម្មណ៍ និងគំរូវការសុខភាពពិតប្រាកដ

☞ គ្រូត្រូវអានការពន្យល់អំពី គំរូវការសុខភាពផ្នែកអារម្មណ៍ និងគំរូវការសុខភាពពិតប្រាកដនៅលើក្រដាស់ផ្ទាំងធំ :

**តំរូវការសុខភាពផ្អែកអារម្មណ៍ :** គឺជាបញ្ហាសុខភាពនៃមនុស្សម្នាក់ ដែលបានដឹងដោយខ្លួនឯងថាមានជំងឺ ហើយស្វែងរកការព្យាបាល ។ ឧទាហរណ៍ : រាគរូស គ្រុនក្តៅ ។




១ - ការព្យាបាលត្រូវចាប់ផ្តើមដោយការធ្វើតាមអ្វីដែលអ្នកជំងឺចង់បាន
(Felt Needs)

**តំរូវការសុខភាពពិតប្រាកដ :** គឺជាបញ្ហាសុខភាព ដែលបានដឹងដោយបុគ្គលិកសុខាភិបាលថា ជាឫសគល់នៃមូលហេតុពិតប្រាកដនៃជម្ងឺ ។ ឧទាហរណ៍ : កុមារខ្វះចំណីអាហារ មូលហេតុនៃជំងឺគ្រុនចាញ់ ។




២ - បន្ទាប់មកត្រូវប្រើសម្ភារៈអប់រំសុខភាពដើម្បីពន្យល់អោយ
អ្នកជំងឺយល់អំពីហេតុផលដែលធ្វើអោយមានជំងឺ ។
(Real Need)




## វត្ថុបំណងទី២: បំពេញនៅក្នុងតារាងនូវ គំរូវការសុខភាពផ្អែកអារម្មណ៍ និងតំរូវការសុខភាពពិតប្រាកដ

☞ គ្រូត្រូវរៀបចំសិក្ខាកាមសំរាប់ការពិភាក្សាតាមចិត្ត

*សេចក្តីណែនាំនេះមានផ្តួននៅក្នុងសៀវភៅការងារសំរាប់សិក្ខាកាម*

**សកម្មភាព ៤-២-១ ពិភាក្សាតាមចិត្ត**

សកម្មភាពនេះមានគោលបំណងឱ្យសិក្ខាកាមពិភាក្សាតាមចិត្តកាន់តែលំអិតឡើងនូវតំរូវការសុខភាពផ្អែកអារម្មណ៍នៃសហគមន៍របស់ពួកគេ ។

**រយៈពេល :** ៣ នាទី

**ភារកិច្ច:** សិក្ខាកាមត្រូវរកដៃគូ រួចពិភាក្សារកចម្លើយ អំពី តំរូវការសុខភាពផ្អែកអារម្មណ៍នៃសហគមន៍ នៅនឹងកន្លែងយ៉ាងតិចបំផុតឱ្យបាន៣ ។

*សេចក្តីណែនាំនេះមានស្ទួននៅក្នុងសៀវភៅការងារសំរាប់សិក្ខាកាម*

**សកម្មភាព ៤-២-២ ការងារផ្ទាល់ខ្លួន**

សកម្មភាពនេះមានគោលបំណងឱ្យសិក្ខាកាមគិតថា តើអ្វីខ្លះដែលពួកគេបានដឹងរួចហើយអំពីគំរូវិការសុខភាពនៃសហគមន៍របស់ពួកគេ ។

**រយៈពេល :** ២ នាទី

**ភារៈកិច្ច :** សិក្ខាកាមម្នាក់ៗឆ្លើយសំណួរខាងក្រោមនេះដោយខ្លួនពួកគេផ្ទាល់

តើអ្វីខ្លះដែលជាគំរូវិការសុខភាពផ្នែកអារម្មណ៍នៃសហគមន៍ នៅនឹងកន្លែងរបស់អ្នក?

សិក្ខាកាមម្នាក់ៗ ត្រូវសរសេរយ៉ាងតិចបំផុតនូវគំរូវិការសុខភាពផ្នែកអារម្មណ៍នៃសហគមន៍របស់ពួកគេចំនួន៣ ។

សិក្ខាកាមត្រូវបំពេញតារាងនេះនៅក្នុងសៀវភៅការងាររបស់ពួកគេ ។

*សេចក្តីណែនាំនេះមានស្ទួននៅក្នុងសៀវភៅការងារសិក្ខាកាម*

| **ឈ្មោះនៃគំរូវិការ សុខភាពផ្នែកអារម្មណ៍** | **នរណាមានគំរូវិការនេះ ច្រើនជាងគេ** | **តើគំរូវិការសុខភាពផ្នែកអារម្មណ៍ កើតមាន នៅកន្លែងណាច្រើនជាងគេ** (ភូមិដែលមណ្ឌលសុខភាពគ្របដណ្តប់) | **ហេតុអ្វីក៏បញ្ហា នេះកើតមាន?** |
|---|---|---|---|
| ១ | | | |
| ២ | | | |
| ៣ | | | |
| ៤ | | | |
| ៥ | | | |

☞ គ្រូត្រូវសួរទៅសិក្ខាកាម៥នាក់ផ្សេងៗគ្នា ដើម្បីចែករំលែកចំណេះដឹងជាមួយសិក្ខាកាមទាំងអស់ ពីលទ្ធផលនៃការពិភាក្សារបស់ពួកគេ ។

បំណងគឺសាកល្បង និងកំណត់វង្វង់មួយ (Range) នៃគំរូវិការសុខភាពផ្នែកអារម្មណ៍ដែលបានពិភាក្សា។ ប្រសិនបើ សិក្ខាកាមរើសយកគំរូវិការផ្នែកអារម្មណ៍ដូចគ្នា សូមបន្តហៅទៅសិក្ខាកាមម្នាក់ទៀត ។

✍ **កំណត់សំគាល់ :** គ្រូត្រូវអានពត៌មានបន្ថែមខាងក្រោមនេះ :

**សារៈសំខាន់នៃតំរូវការសុខភាពផ្នែកអារម្មណ៍ :**

- ប្រជាជននឹងទៅមណ្ឌលសុខភាព ដើម្បីព្យាបាលតំរូវការសុខភាពផ្នែកអារម្មណ៍របស់ពួកគេ ។
- វាមានសារៈសំខាន់ណាស់សំរាប់បុគ្គលិកសុខាភិបាល ក្នុងការទទួលស្គាល់តំរូវការសុខភាពផ្នែកអារម្មណ៍ ។
- ប្រជាជននឹងពេញចិត្ត ត្រឡប់ទៅមណ្ឌលសុខភាពវិញ ប្រសិនបើតំរូវការសុខភាពផ្នែកអារម្មណ៍របស់ពួកគេបានត្រូវផ្តល់ជាអាទិភាពចំបង។
- ក្រោយពីតំរូវការសុខភាពផ្នែកអារម្មណ៍ត្រូវបានព្យាបាល ជាធម្មតាបុគ្គលិកសុខាភិបាលត្រូវភ្ជាប់ជាមួយការអប់រំសុខភាពដល់អ្នកជម្ងឺ ។

**សារៈសំខាន់នៃតំរូវការសុខភាពពិតប្រាកដ :**

ការរកឃើញពីតំរូវការសុខភាពពិតប្រាកដ ដែលជាបញ្ហានៃជម្ងឺ ឬកង្វះខាតនៃសុខភាពដែលបានប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សុខភាពអ្នកជម្ងឺ ក្រុមគ្រួសារ ឬសហគមន៍ក្នុងរយៈពេលវែង អាចអនុញ្ញាតឱ្យបុគ្គលិកសុខាភិបាលបានដឹងជាទូទៅអំពី ឬសគល់នៃមូលហេតុពិតប្រាកដនិមួយៗ និងធ្វើការដោះស្រាយបញ្ហាសុខភាពនេះជូនប្រជាជន។

☞ គ្រូត្រូវរៀបចំសិក្ខាកាមសំរាប់ការពិភាក្សាតាមចិត្ត ។

*សេចក្តីណែនាំនេះមានស្ទួននៅក្នុងសៀវភៅការងារសំរាប់សិក្ខាកាម*

**សកម្មភាព ៤-២-៣ ពិភាក្សាតាមចិត្ត**

សកម្មភាពនេះមានគោលបំណងឱ្យសិក្ខាកាមពិភាក្សាតាមចិត្តកាន់តែលំអិតឡើងនូវតំរូវការសុខភាពពិតប្រាកដនៃសហគមន៍របស់ពួកគេ ។

**រយៈពេល :** ៣ នាទី

**ភារកិច្ច :** សំណួរ: តើអ្វីខ្លះ ជាតំរូវការសុខភាពពិតប្រាកដនៃសហគមន៍ ?

សិក្ខាកាមម្នាក់ៗ គ្រាន់តែស្វែងរកចម្លើយពីតំរូវការពិតប្រាកដនៃសហគមន៍របស់ពួកគេ យ៉ាងហោចណាស់ឱ្យបានមួយ ។

*សេចក្តីណែនាំនេះ មានផ្ទួននៅក្នុងសៀវភៅការងារសិក្ខាកាម*

**សកម្មភាព ៤-២-៤ ពិភាក្សាក្រុមតូច**

បំណងនៃសកម្មភាពនេះ គឺជំរុញលើកទឹកចិត្តសិក្ខាកាមឱ្យចែករំលែកចំណេះដឹងរបស់ពួកគេ អំពី **តំរូវការសុខភាពពិតប្រាកដនៅកម្ពុជា ។**

**រយៈពេល :** ១៥ នាទី

**ការណែនាំ :** ចែកសិក្ខាកាមជា៣ក្រុម ក្រុមនិមួយៗត្រូវពិភាក្សា :

- ក្រុមទី១ : កុមារខ្វះចំណីអាហារ
- ក្រុមទី២ : សញ្ញាគ្រោះថ្នាក់ពេលមានផ្ទៃពោះ
- ក្រុមទី៣ : ខ្វះខាតបង្គន់

ទាំង៣ក្រុមត្រូវបំពេញតារាងនៅក្នុងសៀវភៅការងាររបស់សិក្ខាកាម និងនៅលើក្រដាសផ្ទាំងធំ ។

**បង្ហាញលទ្ធផល និង ពិភាក្សា :**

- តំណាងក្រុមនិមួយៗឡើងបង្ហាញលទ្ធផល (៥នាទីក្នុង១ក្រុម)
- ទុកពេលអោយសិក្ខាកាមឯទៀតៗសួរ ឬផ្តល់យោបល់ និងតំណាងក្រុមបកស្រាយ
- គ្រូធ្វើការសំរបសំរួល និងសំយោគចម្លើយសិក្ខាកាម

☞ គ្រូត្រូវឱ្យសិស្សបំពេញក្នុងតារាងខាងក្រោមនេះ ដែលនៅក្នុងសៀវភៅការងាររបស់សិក្ខាកាម

| **ឈ្មោះនៃតំរូវការសុខភាពពិតប្រាកដ** | **តើបញ្ហាធំជាងគេកើតនៅទីកន្លែងណា?**<br>(ភូមិដែលមណ្ឌលសុខភាពគ្របដណ្តប់) | **ហេតុអ្វីក៏តំរូវការនេះ កើតមាន ?** |
|---|---|---|
| | | |

✍ **សង្ខេប:** គ្រូធ្វើការសង្ខេបដោយសួរសំណួរដូចខាងក្រោម:

១. ដូចម្តេចដែលហៅថា តំរូវការសុខភាពផ្នែកអារម្មណ៍ ? - ឱ្យឧទាហរណ៍

២. ដូចម្តេចដែលហៅថា តំរូវការសុខភាពពិតប្រាកដ ? - ឱ្យឧទាហរណ៍

៣. តើបុគ្គលិកមណ្ឌលសុខភាពត្រូវធ្វើអ្វីខ្លះ ដើម្បីឆ្លើយតបនឹងតំរូវការសុខភាពផ្នែកអារម្មណ៍របស់សហគមន៍ ?

☞ គ្រូពន្យល់បន្ថែមពីចំណងទាក់ទង រវាងតំរូវការទាំង២ ទៅនឹងសារៈប្រយោជន៍នៃការធ្វើផែនការ នៅផ្នែកទី៣ នៃម៉ូឌុលនេះ។

# មេរៀនទី៤ : ការអប់រំសុខភាព និង ការលើកកំពស់សុខភាព

**១- រយៈពេល** : ១ ម៉ោង ១៥ នាទី

**២- វត្ថុបំណងនៃការសិក្សា** : នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមទាំងអស់ នឹងអាច :

- កំណត់ន័យនៃពាក្យ ការអប់រំសុខភាព និង ការលើកកំពស់សុខភាព
- ពន្យល់ពីតួនាទីរបស់បុគ្គលិកមណ្ឌលសុខភាពក្នុងការអប់រំសុខភាព និងការលើកកំពស់សុខភាព ។

**តើមេរៀននេះ ជាប់ទាក់ទងយ៉ាងដូចម្តេចទៅនឹងការងាររបស់បុគ្គលិកមណ្ឌលសុខភាព ?**

បង្ហាញឱ្យឃើញពីតួនាទីនៃបុគ្គលិកមណ្ឌលសុខភាពដើម្បីអនុវត្តការងារអប់រំសុខភាព និងលើកកំពស់សុខភាព ។

**៣- សំភារៈ និង ការរៀបចំជាមុន**

**អ្នក នឹងត្រូវការ :**

ក្រដាសផ្ទាំងធំ/ក្រដាសថ្លា ដែលបានសរសេរទុករួចស្រេចនូវចំណុចសង្ខេបនៅក្នុងសៀវភៅណែនាំសំរាប់គ្រូ ស្តីពី ការអប់រំ សុខភាព និងការលើកកំពស់សុខភាព ។

**ការរៀបចំមេរៀនជាមុន :**

**គ្រូ** : មើលខ្លឹមសារមេរៀន ជាពិសេសការបកស្រាយនិយមន័យនៃការអប់រំសុខភាព ការលើកកំពស់សុខភាព និង ចំណុចសង្ខេប ដែលអ្នកនឹងប្រើវានៅខាងចុងបញ្ចប់នៃមេរៀននេះ ។

**គ្រូជំនួយ** : ចំលងនៅលើក្រដាសផ្ទាំងធំនូវខ្លឹមសារ ស្តីពី និយមន័យ នៃការអប់រំសុខភាព និងលើកកំពស់សុខភាព ចេញពីសេចក្តីសង្ខេប ដែលមាននៅក្នុងសៀវភៅណែនាំសំរាប់គ្រូផ្នែកទី ២ : **ដំណើរការនៃការអប់រំសុខភាព** ។

**៤- សកម្មភាព:**

## វត្ថុបំណងទី១: កំណត់ន័យនៃពាក្យ ការអប់រំសុខភាព និងការលើកកំពស់សុខភាព

☞ គ្រូត្រូវសួរសំណួរបំផុសគំនិតនៃពាក្យ ការអប់រំសុខភាព និងការលើកកំពស់សុខភាព ដូចខាងក្រោម ។

- តើការអប់រំសុខភាព មានន័យដូចម្តេច?
- តើការលើកកំពស់សុខភាពមានន័យដូចម្តេច?

☞ គ្រូជំនួយកត់ត្រាចម្លើយចូលរួមរបស់សិក្ខាកាម

☞ បង្ហាញចម្លើយចូលរួមរបស់គ្រូសំរបសំរួល :

**និយមន័យ :**

**ការអប់រំសុខភាព :** គឺជាការផ្សព្វផ្សាយពតិមានទាំងឡាយ ដែលទាក់ទងនឹងវិធានការបង្ការជំងឺ ហើយធ្វើឱ្យប្រជាជនព្រមទទួលនូវទំលាប់ថ្មី ឬអំពើប្រព្រឹត្តិថ្មីដែលនាំមកនូវសុខភាព ។

**ការលើកកំពស់សុខភាព :** គឺជាការរួមបញ្ចូលគ្នា នូវការអប់រំសុខភាព សកម្មភាពទាំងផ្នែកនយោបាយ ផ្នែកសេដ្ឋកិច្ច ផ្នែកអង្គការចាត់តាំង ក្នុងគោលបំណងសំរួលដល់ការធ្វើឱ្យមានបរិស្ថាន និងការប្រព្រឹត្តិដែលបង្កើន ឬការពារសុខភាព។

☞ គ្រូគួរផ្តល់ឧទាហរណ៍មួយចំនួនទាក់ទងនឹង ការអប់រំសុខភាព និងលើកកំពស់សុខភាពដល់សិក្ខាកាម ។

- ឧទាហរណ៍មួយនៃការអប់រំសុខភាព គឺ បង្រៀនម្តាយពីសារៈសំខាន់នៃការបន្តបំបៅដោះកូន នៅពេលវាមានជម្ងឺរាក ។
- ឧទាហរណ៍មួយនៃការលើកកំពស់សុខភាព គឺ ការអប់រំពីសារៈសំខាន់នៃការប្រើមុង ដើម្បីបង្ការជម្ងឺឆ្លងដោយមូសដូចជា គ្រុនឈាម និងគ្រុនចាញ់ ។

## វត្ថុបំណងទី២: ពន្យល់ពីតួនាទីរបស់បុគ្គលិកមណ្ឌលសុខភាពក្នុងការអប់រំសុខភាព និង លើកកំពស់សុខភាព

☞ **គ្រូត្រូវអានអត្ថបទនេះ :**

តួនាទីចំបងរបស់បុគ្គលិកមណ្ឌលសុខភាពនៅក្នុងការអប់រំសុខភាព និងលើកកំពស់សុខភាព គឺត្រូវស្គាល់ពីសហគមន៍ និង ក្រុមគោលដៅរបស់ពួកគេជាមុនសិន ។

*សេចក្តីណែនាំនេះ មានស្ទួននៅក្នុងសៀវភៅការងារសំរាប់សិក្ខាកាម*

**សកម្មភាព ៤-២-១ ពិភាក្សាក្រុមធំ**

បំណងនៃសកម្មភាពនេះគឺណែនាំឱ្យសិក្ខាកាមឱ្យរំពឹងគិតថា តើពួកគេនឹងត្រូវធ្វើដូចម្តេចដើម្បីបានយល់ដឹងពីសហគមន៍របស់គេ ។

**រយៈពេល :** ១៥ នាទី

**ការណែនាំ :** គ្រូស្នើសុំឱ្យសិក្ខាកាមពិភាក្សាលើសំណួរខាងក្រោមនេះ ដើម្បីចែករំលែកវិធីធ្វើឱ្យស្គាល់សហគមន៍ ។

សំណួរ : តើមានមធ្យោបាយអ្វីខ្លះ ដើម្បីសិក្សាស្វែងយល់ពីសហគមន៍របស់អ្នក?

☞ គ្រូជំនួយត្រូវសរសេរគំនិតទាំងនេះ នៅលើក្រដាសផ្ទាំងធំ/ក្រដាសថ្លា ឬក្តារខៀន

**ប្រមូលពត៌មានត្រឡប់ និង ពិភាក្សា :** ( រយៈពេល : ៥ នាទី)

☞ គ្រូសំរបសំរួលត្រូវបំបែកពតិមានត្រឡប់ដែលទទួលបានទាំងនេះឱ្យទៅជាប្រភេទសកម្មភាពមនុស្សម្នាក់ទៅមនុស្សម្នាក់ និង ប្រភេទសកម្មភាពនៃការប្រមូលពតិមាន ដោយឡែក១ពីគ្នា ឧ. ដូចជា ការធ្វើអង្កេត ។

☞ គ្រូធ្វើការសំយោគដោយផ្អែកលើគំនិតក្នុងពេលពិភាក្សា រួចបង្ហាញចម្លើយដូចបានរៀបរាប់ក្នុងប្រអប់ខាងក្រោមនេះ ។

☝ **ចំលើយចូលរួម**

**មធ្យោបាយដើម្បីសិក្សាស្វែងយល់ពីសហគមន៍ :**

**ប្រភេទសកម្មភាពពីមនុស្សម្នាក់ទៅមនុស្សម្នាក់ :**

- ការចូលរួមក្រៅផ្លូវការជាមួយសហគមន៍ ( នៅតាមទីប្រជុំជន - នៅតាមផ្លូវ )
- ការរៀបចំប្រជុំផ្សេង១ ដូចជាប្រជុំជាមួយអ្នកដឹកនាំសហគមន៍ គណៈកម្មការគ្រប់គ្រងម.ស គ្រូនៅសាលារៀន
- ការពិភាក្សាជាមួយឆ្មបបូរាណ ឬក្រុមទ្រទ្រង់សុខភាពភូមិ អំពីការអប់រំសុខភាព ។

**ប្រភេទសកម្មភាពនៃការប្រមូលពតិមាន :**

- ការធ្វើអង្កេតសហគមន៍ ( ឧទាហរណ៍ : ការធ្វើអង្កេត ដើម្បីស្រាវជ្រាវរកជម្ងឺរាគត្បាត ជម្ងឺរុំរ៉ៃ)
- ការធ្វើយុទ្ធនាការនានា ឧទាហរណ៍ ការផ្តល់ថ្នាំបង្ការ
- ការស្រាវជ្រាវរកជម្ងឺរុំរ៉ៃ និងសកម្មភាពតាមដាន
- ការស្វែងរកតំរូវការរបស់សហគមន៍

☞ នៅក្នុងសៀវភៅការងារសំរាប់សិក្ខាកាម សកម្មភាពនៃការអប់រំសុខភាព និងការលើកកំពស់សុខភាព បានត្រូវរៀបជាតារាងមួយ ។

*សេចក្តីណែនាំនេះមាន ស្ទួននៅក្នុងសៀវភៅការងារសំរាប់សិក្ខាកាម*

**សកម្មភាព ៤-២-២** **ការងារផ្ទាល់ខ្លួន**

បំណងនៃសកម្មភាពនេះ គឺណែនាំសិក្ខាកាមគិតពីតួនាទីបុគ្គលិកសុខាភិបាល នៅក្នុងការអប់រំសុខភាព និងលើកកំពស់សុខភាព

**ភារកិច្ចទី ១ :** សិក្ខាកាមម្នាក់១ត្រូវសាកល្បងបំពេញតារាង ដែលបានបង្ហាញនៅក្នុងសៀវភៅការងាររបស់ពួកគេ

**រយៈពេល :** ១០ នាទី

**ភារកិច្ចទី ២ :** សិក្ខាកាមត្រូវធ្វើការជាមួយគ្នា២១នាក់ ហើយប្រៀបធៀបចម្លើយជាមួយគ្នា និងពិភាក្សា

**រយៈពេល :** ១០ នាទី

**ភារកិច្ច៣ :** សិក្ខាកាមត្រូវធ្វើការជាមួយគ្នា៤១នាក់ ហើយពិភាក្សាចម្លើយជាមួយគ្នា ។

**រយៈពេល :** ៥ នាទី

*សេចក្តីណែនាំនេះមានស្ទួននៅក្នុងសៀវភៅការងារសំរាប់សិក្ខាកាម*

**ភារកិច្ច :** បំពេញតារាងនេះដោយគិតទៅលើទំហំការងារ ក៏រិតបច្ចេកទេស ជំនាញ ការទទួលខុសត្រូវជាបំបង របស់បុគ្គលិកសុខាភិបាល ។

*( សំគាល់: ចម្លើយចូលរួមខាងក្រោមនេះ បានមកពីការឯកភាពគ្នារបស់សិក្ខាកាមទាំងអស់ នៅក្នុង វគ្គបណ្តុះបណ្តាល ស្តីពី សេចក្តីណែនាំក្នុងការប្រើប្រាស់សៀវភៅម៉ូឌុល៧ នៅទីស្នាក់ការអង្គការ RACHA ភ្នំពេញ ថ្ងៃទី ១៩ ដល់ ២៣ ខែកញ្ញា ឆ្នាំ២០០៥ )*

| សកម្មភាព | តួនាទីបុគ្គលិក មណ្ឌលសុខភាព | មិនមែនជាតួនាទីរបស់ បុគ្គលិកមណ្ឌលសុខភាព |
|---|---|---|
| តើត្រូវប្រើស្រោមលិង្គដូចម្តេច ? | ✓ | |
| ពិភាក្សាជាមួយ គណៈកម្មាការអភិវឌ្ឍន៍ អំពីកំណើននៃការស្លាប់របស់ កុមារដោយសារជម្ងឺគ្រុនឈាម | ✓ | |
| ពិភាក្សាជាមួយម្តាយៗ ដើម្បីឱ្យគាត់យកកូនទៅមន្ទីរពេទ្យ នៅពេលដែលកូនរបស់ពួកគាត់មានជម្ងឺ | | ✓ |
| បង្រៀនអំពីការពន្យារកំណើត ដល់ស្ត្រីនៅក្នុងភូមិ | ✓ | |
| ពន្យល់ទៅក្រុមទ្រទ្រង់សុខភាពភូមិនូវមូលហេតុនៃជម្ងឺរបេង ដែលកើតនៅលើស្ត្រីភាគច្រើន តែមិនទាន់អាចស្រាវជ្រាវរកឃើញអស់នៅឡើយ ហើយនោះគឺជាប្រភពចំលង នៅក្នុងគ្រួសារ និងនៅក្នុងភូមិ（BK Negative） | ✓ | |
| បង្រៀនកុមារថា តើធ្វើដូចម្តេច ដើម្បីបង្ការជម្ងឺរាក | | ✓ |
| ចំរៀងនៅក្នុងវិទ្យុ ស្តីពី មូស និងជម្ងឺគ្រុនចាញ់ | | ✓ |
| ធ្វើបង្ហាញពីវិធីដែលធ្វើឱ្យប្រសើរឡើងនូវអាហារូបត្ថម្ភចំពោះកុមារដែលស្គម | ✓ | |
| បង្ហាញមនុស្សម្នាក់ឱ្យស្គាល់ថា ដូចម្តេចដែលហៅថា ដំបៅក្លាយ | ✓ | |
| ជំរុញលើកទឹកចិត្តប្រជាជនឱ្យប្រើប្រាស់មណ្ឌលសុខភាព នៅពេលដែលយើងដឹងថា មណ្ឌលសុខភាពផ្តល់ឱ្យនូវសេវាបំរើពិសេស ឧទាហរណ៍ការសំរាលកូន | ✓ | |
| ក្រុមហ៊ុនមួយដែលលក់ស្រោមលិង្គ ផ្តល់នូវការកំសាន្តសប្បាយដល់សហគមន៍មួយ និងរួមបញ្ចូលការផ្តល់ពត៌មាន អំពីស្រោមលិង្គ | | ✓ |
| បង្រៀនទៅម្តាយ ថា តើគាត់ត្រូវព្យាបាលកូនគាត់យ៉ាងដូចម្តេច នៅពេលដែលកូនគាត់ រាកក៏រិតមធ្យម | ✓ | |
| យុទ្ធនាការផ្តល់ថ្នាំបង្ការ | ✓ | |
| បង្រៀនដល់ឆ្មបបូរាណ អំពី ការកំណត់ស្ត្រីមានផ្ទៃពោះ ថាតើនរណាដែលប្រហែលជាមានការលំបាកក្នុងការសំរាលកូន ។ | ✓ | |

**ប្រមូលពត៌មានត្រឡប់ និង ពិភាក្សា :** ( រយៈពេល : ១៥ នាទី)

☞ គ្រូត្រូវឱ្យសមាជិកមកពីក្រុមផ្សេងៗគ្នា ចែករំលែកការពិភាក្សារបស់ពួកគេជាមួយក្រុមធំ ។

☞ តាមរយៈការបង្ហាញចម្លើយចូលរួមខាងលើ គ្រូត្រូវពន្យល់ថា :

- តើការអប់រំសុខភាព និងការលើកកំពស់សុខភាព មានភាពខុសពីគ្នាយ៉ាងដូចម្តេច? និង
- តើនៅពេលណាវាសមស្របជាមួយការអប់រំសុខភាព និងនៅពេលណាដែលវាមានសារៈសំខាន់ចំពោះការលើកកំពស់សុខភាព?

✍ **សេចក្តីសន្និដ្ឋាន :**

**ពត៌មានស្តីពីសុខភាព :**

- នរណា ក៏អាចផ្សាយពត៌មានថ្មីៗ ស្តីពី សុខភាពបានដែរ ។
- វានៅតែកត្តាគ្រោះថ្នាក់ ប្រសិនបើមានមនុស្សជាច្រើន នៅតែអាចរកលុយបានច្រើន ពីភាពមានជម្ងឺ ដោយសារការលក់ផលិតផលសំរាប់សុខភាព និងសំរាប់ថែទាំសុខភាព ។
- សហគមន៍ ជួនកាលមិនអាចមានលទ្ធភាពនឹងវិនិច្ឆ័យបាន ទោះបីជាពត៌មានទាំងនោះត្រឹមត្រូវក៏ដោយ ។
- បុគ្គលិកមណ្ឌលសុខភាពមានតួនាទីចំបងណាស់ ក្នុងការផ្សព្វផ្សាយសារសុខភាពឱ្យបានត្រឹមត្រូវ និងសមស្រប ។

✍ **សង្ខេប និង វាយតំលៃ:**

គ្រូធ្វើការសង្ខេប និងវាយតំលៃលើចំណេះដឹងរបស់សិក្ខាកាមបន្ទាប់ពីបានរៀនរួច ដោយសួរសំណួរដូចខាងក្រោម :

១- ដូចម្តេចដែលហៅថា ការអប់រំសុខភាព និងការលើកកំពស់សុខភាព?

២- តើតួនាទីរបស់បុគ្គលិកសុខាភិបាល ក្នុងការអប់រំសុខភាព និងការលើកកំពស់សុខភាពមានអ្វីខ្លះ?

# ផ្នែកទី២ : ដំណើរការនៃការអប់រំសុខភាព

## មេរៀនទី១ : ការអប់រំអតិថិជនក្នុងកំឡុងពេលព្យាបាល ឬ បន្ទាប់ពីព្យាបាលរួច

**១- រយៈពេល :** ១០ម៉ោង ១០នាទី

**២- វត្ថុបំណងនៃការសិក្សា :** នៅចុងបញ្ចប់ នៃមេរៀនសិក្ខាកាមទាំងអស់ នឹងអាចៈ

១. បង្ហាញនូវទំរង់ដែលមាន៧ជំហានរបស់ដំណើរការនៃការអប់រំសុខភាព ។

២. ប្រើទំរង់ដែលមាន៧ជំហាន សំរាប់អប់រំអតិថិជន ក្នុងពេលកំពុងផ្តល់សេវានៅមណ្ឌលសុខភាព។

**តើផ្នែកនេះជាប់ទាក់ទងយ៉ាងដូចម្តេច ទៅនឹងការងាររបស់បុគ្គលិកមណ្ឌលសុខភាព ?**

ផ្នែកនេះនឹងរៀបចំបុគ្គលិកមណ្ឌលសុខភាពឱ្យមានលទ្ធភាពបង្រៀនអ្នកជម្ងឺ និងសហគមន៍ ដោយប្រើវិធីបង្រៀន ដែលបានកំណត់រួចហើយ និងសំភារៈសំរាប់អប់រំសុខភាព ។

**៣- សំភារៈ និង ការរៀបចំជាមុន**

**អ្នកនឹងត្រូវការ :**

ក្រដាសផ្ទាំងធំ/ក្រដាសថ្លា ដែលបានសរសេរទុករួចស្រេចនូវ ទំរង់ដែលមាន៧ជំហានរបស់ដំណើរការនៃការអប់រំសុខភាព។

**ការរៀបចំមេរៀនជាមុន :**

**គ្រូ :** មើលខ្លឹមសារមេរៀនស្តីពី ទំរង់ដែលមាន៧ជំហានរបស់ដំណើរការនៃការអប់រំសុខភាព ដែលមាននៅត្រង់ទំព័រទី៤៨។

**គ្រូជំនួយ :** ចំលងនៅលើក្រដាសផ្ទាំងធំនូវខ្លឹមសារ ស្តីពី **ទំរង់ដែលមាន៧ជំហានរបស់ដំណើរការនៃ ការអប់រំសុខភាព** ដែលមាននៅក្នុងសៀវភៅណែនាំសំរាប់គ្រូ ត្រង់ទំព័រទី៤៨។

**៤- សកម្មភាព:**

**វត្ថុបំណងទី១: បង្ហាញនូវទំរង់ដែលមាន៧ជំហានរបស់ដំណើរការនៃការអប់រំសុខភាព**

☞ គ្រូសំរបសំរួលត្រូវ បង្ហាញ និងពន្យល់សិក្ខាកាមនូវ ទំរង់ដែលមាន៧ជំហានរបស់ដំណើរការនៃការអប់រំសុខភាព ដូច មានក្នុងប្រអប់នៃបញ្ជីត្រួតពិនិត្យសមត្ថភាព ខាងក្រោមនេះ។

**បញ្ជីត្រួតពិនិត្យសមត្ថភាព**

- **ជំហានទី១ : កំណត់បញ្ហា**
- **ជំហានទី២ : ជ្រើសរើសខ្លឹមសារគ្លីនិកត្រឹមត្រូវ**
- **ជំហានទី៣ : ជ្រើសរើសខ្លឹមសារបង្រៀនសមស្រប**
- **ជំហានទី៤ : ជ្រើសរើសវិធីសាស្ត្របង្រៀន**
- **ជំហានទី៥ : ជ្រើសរើសសំភារៈជំនួយ**
- **ជំហានទី៦ : ស្វែងរកពត៌មានត្រឡប់ និងវាយតំលៃការអប់រំ**
- **ជំហានទី៧ : កត់ត្រាសកម្មភាព និងលទ្ធផល**

## វត្ថុបំណងទី២: ប្រើទំរង់ដែលមាន៧ជំហានសំរាប់អប់រំអតិថិជន ក្នុងពេលកំពុងផ្តល់សេវានៅមណ្ឌលសុខភាព

## ជំហានទី១ : កំណត់បញ្ហា

**១- រយៈពេល :** ១ ម៉ោង ១៥ នាទី

**២- សំភារៈ និង ការរៀបចំជាមុន**

**អ្នកនឹងត្រូវការ :**

- សៀវភៅណែនាំសំរាប់មណ្ឌលសុខភាព
- សន្លឹកថតចម្លងនៃក្រដាសផ្ទាំ ៥.២.១ សៀវភៅសន្លឹកផ្ទាត់នៃ MPA ម៉ូឌុល ២

**ការរៀបចំមេរៀនជាមុន**

**គ្រូ :** - អានខ្លឹមសារមេរៀន ដោយឡែកផ្នែកដំបូងនៃមេរៀននេះ ដែលគ្រូត្រូវដឹកនាំ

- រំលឹកម៉ូឌុល ២ ឡើងវិញត្រង់មេរៀន " ផែនការព្យាបាល "
- រំលឹកបច្ចេកទេសបង្រៀនឡើងវិញ ( នៅផ្នែកខាងក្រោយនៃសៀវភៅ ) ស្តីពី ថាតើត្រូវដំណើរការល្បែង សំដែងតួយ៉ាងដូចម្តេច ?

**គ្រូជំនួយ :** រៀបចំក្រដាសផ្ទាំងធំ ដើម្បីទទួលយកពត៌មានត្រឡប់របស់សិក្ខាកាមទាំងអស់ ពីការសំដែងរឿង នូវ ជំនឿ អាកប្បកិរិយា និងការរំពឹងទុក របស់នាងធីតា។

## ៣- សកម្មភាព :

☞ គ្រូពន្យល់ថា មេរៀននេះ នឹងប្រើសំភារៈដែលបានបង្រៀននៅក្នុង MPA ម៉ូឌុល ២ " **ផែនការព្យាបាល** " ។

☞ សកម្មភាព ដំបូង គឺឱ្យសិក្ខាកាមរំលឹកឡើងវិញនូវមេរៀននោះ ។

☞ គ្រូត្រូវរៀបចំសិក្ខាកាម សំរាប់ការពិភាក្សាតាមចិត្ត

*សេចក្តីណែនាំនេះមានស្ទួននៅក្នុងសៀវភៅការងារសំរាប់សិក្ខាកាម*

**សកម្មភាព ៣-១-១ ពិភាក្សាតាមចិត្ត**

បំណងនៃសកម្មភាពនេះគឺ ណែនាំឱ្យសិក្ខាកាមគិតអំពីអ្វីខ្លះ ដែលពួកគេនៅចាំបានពីខ្លឹមសារនៃ MPA ម៉ូឌុលទី ២ ត្រង់ " **ផែនការព្យាបាល** " ។

**រយៈពេល :** ៣ នាទី

**ការណែនាំ :** ពិភាក្សាពីជំហានទាំង ៤ (នៅក្នុងផែនការព្យាបាលដែលបានបង្រៀនរួចហើយនៅម៉ូឌុល ២)

☞ គ្រូត្រូវរំលឹកពីទំរង់បែបបទនៃការវាយតំលៃ ដែលបានបង្រៀនរួចហើយ នៅក្នុងម៉ូឌុល ២ ឡើងវិញ ។ មើលសំអាងនៅលើ ក្រដាសថ្លា ឬសៀវភៅសន្លឹកផ្ទាត់ ៥.២.១ ( MPA ម៉ូឌុល ២ )

☞ គ្រូត្រូវអានអត្ថបទនេះ ឱ្យសិក្ខាកាមស្តាប់ :

១. ភារកិច្ចដំបូងគេ នៅក្នុងការអប់រំអតិថិជន គឺកំណត់ឱ្យបានត្រឹមត្រូវនូវបញ្ហា សំរាប់ការអប់រំសុខភាព ។ ពត៌មាននេះ ជាញឹកញាប់ទទួលបាននៅពេលធ្វើការសំភាសន៍ជាដំបូងជាមួយអតិថិជន នៅពេលដែលអ្នករៀបចំបង្កើតទំនាក់ទំនង មុននឹងឈានទៅដល់ការប្រើប្រាស់ផែនការព្យាបាល ( មើលសំអាងនៅ MPA ម៉ូឌុល ២) ។

២. ប្រសិទ្ធិភាពនៃលទ្ធភាពរបស់អ្នក ដើម្បីផ្តល់នូវ ការថែទាំ ឱសថ ការអប់រំ ការតាមដាននូវ ការវិលត្រឡប់មកវិញនៃអតិថិជនបានត្រឹមត្រូវ ត្រូវពឹងពាក់ទាំងស្រុងនៅលើជំនាញប្រាស្រ័យទាក់ទង ប្រកបដោយប្រសិទ្ធិភាព ។

☞ **គ្រូត្រូវរំឮក :** ផែនការព្យាបាលដែលមាននៅក្នុងប្រអប់ខាងក្រោម :

**ផែនការព្យាបាលរួមមាន :**

- ការថែទាំត្រឹមត្រូវ
- ការផ្តល់ឱសថត្រឹមត្រូវ
- ការអប់រំត្រឹមត្រូវ
- ការតាមដាននូវការវិលត្រឡប់មកវិញនៃអ្នកជម្ងឺបានត្រឹមត្រូវ ។

ប្រសិទ្ធិភាពនៃលទ្ធភាពរបស់អ្នក ដើម្បីផ្តល់នូវ ការថែទាំ ឱសថ ការអប់រំ និងតាមដាននូវការវិលត្រឡប់មកវិញនៃអតិថិជនបានត្រឹមត្រូវ គឺត្រូវពឹងពាក់ទាំងស្រុងទៅលើប្រសិទ្ធិភាពនៃជំនាញប្រាស្រ័យទាក់ទង ។

☞ គ្រូត្រូវអានរឿងនិទាននេះខ្លាំងៗឱ្យសិក្ខាកាមស្តាប់

**រឿងនិទាន :** នាងធីតាសំរាលបានកូនប្រុសម្នាក់ដែលមានសុខភាពល្អណាស់ ។ ធីតានាងងូតទឹកឱ្យទារក១ថ្ងៃ១ដង រៀងរាល់ថ្ងៃ ។ ថ្ងៃមួយអ្នកជិតខាងម្នាក់ បានមកសាកសួរសុខទុក្ខនាង ហើយបានប្រាប់ធីតាថាត្រូវរោយកំទេចធូលីទៅលើទងផ្ចិតរបស់ទារក ដើម្បីធ្វើឱ្យវាឆាប់ជ្រុះ នាងធីតាក៏បានអនុវត្តតាមដំបូន្មានអ្នកជិតខាង ។២ ថ្ងៃក្រោយមក កូនរបស់នាងធីតាមានគ្រុនក្តៅបន្តិច និងស្រែកយំយ៉ាងខ្លាំង ។នាងពរកូននាងទៅមណ្ឌលសុខភាព ។

**ដាក់តាំងបង្ហាញរូបភាព** M.P.05 **ស្តីពី នាងធីតា និងការជជែករបស់នាងជាមួយអ្នកជិតខាង ។**

☞ គ្រូត្រូវអានអត្ថបទនេះ ឱ្យសិក្ខាកាមស្តាប់។

*សេចក្តីណែនាំនេះមានស្ទួននៅក្នុងសៀវភៅការងារសំរាប់សិក្ខាកាម*

ដោយសំអាងទៅលើរឿងនិទានរបស់នាងធីតា និងរោគសញ្ញាកូនរបស់នាងធីតា មានការបង្ករោគនៅទងផ្ចិត ។ បុគ្គលិកមណ្ឌលសុខភាពព្យាបាលផ្ចិតនោះ ។

- បញ្ហាដែលទាមទារការអប់រំអតិថិជន គឺត្រូវបង្រៀននាងធីតា ពីការថែទាំទងផ្ចិតរបស់កូននាងបន្តទៅទៀត ។
- ប្រជាជនគ្រប់គ្នាតែងមានគំនិត ការគិត ជំនឿ និងអាកប្បកិរិយា ប៉ុន្តែពេលខ្លះគំនិតទាំងនោះប្រហែលជាមិនល្អ ជានិច្ចសំរាប់សុខភាពនោះទេ ។
- ប្រសិទ្ធិភាពនៃទំនាក់ទំនងនៅក្នុងការអប់រំសុខភាព គឺត្រូវស្វែងរកពតិមានត្រឡប់ពីអ្នកជម្ងឺអំពីគំនិតរបស់ពួកគេ : ការគិត ជំនឿ និង អាកប្បកិរិយារបស់ពួកគេ ហើយសំរេចថាមួយណាដែលមិនល្អសំរាប់សុខភាព ។

*សេចក្តីណែនាំនេះមានស្ទួននៅក្នុងសៀវភៅការងារសំរាប់សិក្ខាកាម*

**សកម្មភាព ៣-១-២ ការងារផ្ទាល់ខ្លួន**

បំណងនៃសកម្មភាពនេះ គឺណែនាំឱ្យសិក្ខាកាមធ្វើការកំណត់អត្ថន័យ នៅក្នុងរឿងនិទាន និងឱ្យបង្ហាញថា តើត្រង់ណាដែលបញ្ជាក់ពី គំនិត ការគិត ជំនឿ និងអាកប្បកិរិយា របស់នាងធីតា ។

**រយៈពេល :** ១៥ នាទី

**ការណែនាំ :** ស្នើសិក្ខាកាមបង្ហាញចំណុចទាំងនោះចេញពីរឿងនិទានរបស់នាងធីតា អំពី :

- តើមានអ្វីខ្លះ ដែលនាងធីតា ប្រហែលជាជឿថា ជាមូលហេតុបណ្តាលឱ្យកូននាងយំ?
- តើអ្វីខ្លះដែលមានឥទ្ធិពលទៅលើសកម្មភាពរបស់នាងធីតា?
- ប្រសិនបើអ្នកជាបុគ្គលិកសុខាភិបាល ដែលកំពុងនិយាយជាមួយនាងធីតា តើអ្វីខ្លះដែលអ្នកគិតថាគួរត្រូវបង្រៀននាង ?

*សេចក្ដីណែនាំនេះមានសួននៅក្នុងសៀវភៅការងារសំរាប់សិក្ខាកាម*

**សកម្មភាព ៣-១-៣ ល្បែងសំដែងតួ**

បំណងនៃសកម្មភាពនេះ គឺណែនាំឱ្យសិក្ខាកាមឱ្យពិនិត្យមើលពី ជំនឿ អាកប្បកិរិយា និងការរំពឹងទុករបស់នាងធីតា ។

**រយះពេល :** ១០ នាទី

**ការណែនាំ :**

- សុំឱ្យអ្នកស្ម័គ្រចិត្តពីរនាក់ ក្នុងចំណោមសិក្ខាកាមទាំងអស់ ដើម្បីលេងល្បែងសំដែងតួ ។
    - សិក្ខាកាមទី ១ សំដែងតួជានាងធីតា
    - សិក្ខាកាមទី ២ សំដែងតួជាស្ត្រីអ្នកភូមិម្នាក់ទៀត
- គ្រូបញ្ជាក់សាច់រឿងទៅឱ្យសិក្ខាកាមនិងអ្នកស្ម័គ្រចិត្តដើរតួ :

" នាងធីតាកំពុងនិយាយជាមួយស្ត្រីអ្នកភូមិម្នាក់ អំពី ថាតើនាងថែទាំកូននាងយ៉ាងដូចម្ដេច ។ វាមានសារៈសំខាន់ណាស់ នៅក្នុងការពិភាក្សានេះ ដែលបង្ហាញឱ្យឃើញនូវ ជំនឿ អាកប្បកិរិយា និងការរំពឹងទុក របស់នាងធីតាអំពី ការថែទាំទងផ្ចិត និងអ្វីខ្លះដែលធ្វើឱ្យកូននាងយំ ។ "

- គ្រូស្នើសុំអ្នកសំដែងតួទាំងពីរនាក់នោះ ចេញទៅក្រៅដើម្បីរៀបចំខ្លួននិងទទួលការណែនាំ ថាតើអ្វីខ្លះ ដែលពួកគេ នឹងត្រូវធ្វើនៅពីមុខសិក្ខាកាមទាំងអស់ ។
- គ្រូសុំឱ្យសិក្ខាកាមទាំងអស់ដែលនៅនឹងកន្លែង សង្កេត និងកត់ត្រារាល់ចំណុចសំខាន់ៗដែលបង្ហាញពី ជំនឿ អាកប្បកិរិយា និងការរំពឹងទុក របស់នាងធីតា ។

☞ គ្រូសួរទៅអ្នកសំដែងតួជាស្ត្រីអ្នកភូមិ : តើអ្នកយល់អ្វីខ្លះ អំពីពាក្យសំដីដែលនាងធីតាបាននិយាយ ?

☞ គ្រូសួរទៅសិក្ខាកាមទាំងអស់ថា តើអ្វីខ្លះដែលពួកគេបានដឹងអំពី ជំនឿ អាកប្បកិរិយា និងការរំពឹងទុក របស់នាងធីតា

☺ គ្រូជំនួយត្រូវសរសេរ : **ជំនឿ អាកប្បកិរិយា** និង **ការរំពឹងទុក** នៅលើក្រដាសផ្ទាំងធំ ឬ លើក្ដារខៀន របស់នាងធីតា បន្ទាប់មកកត់ត្រារាល់ពត៌មាន ដែល ជាប់ទាក់ទងទៅនឹង ជំនឿ អាកប្បកិរិយា និងការរំពឹងទុក ដែលបានផ្ដល់ចម្លើយ ដោយសិក្ខាកាមទាំងអស់ ។

☞ គ្រូសំរបសំរួលត្រូវបកស្រាយបំភ្លឺខ្លីៗចំពោះ ការសំដែងតួ និងពិភាក្សាថា តើអ្វីខ្លះទៀតដែលបានបង្ហាញឱ្យឃើញនៅ ក្នុងល្បែងសំដែងតួនេះ ។

**កំណត់សំគាល់ :** ពត៌មានដែលទទួលបានពីការពិភាក្សាទាំងនេះ ត្រូវរក្សាទុកសំរាប់ប្រើប្រាស់ជាមួយភារកិច្ចបន្ទាប់មក ទៀត ក្នុងការវិនិច្ឆ័យបង្កើត **ខ្លឹមសារបង្រៀនសមស្រប** សំរាប់នាងធីតា ។

## ជំហានទី២: ជ្រើសរើសខ្លឹមសារគន្លឹះនិកត្រឹមត្រូវ

**១- រយៈពេល** : ១ ម៉ោង

**២- សំភារៈ និងការរៀបចំជាមុន**

**អ្នកនឹងត្រូវការ :**

សៀវភៅណែនាំសំរាប់មណ្ឌលសុខភាព ក្រដាសផ្ទាំងធំ /ក្រដាសថ្លា ប៊ិច សំរាប់សកម្មភាពក្រុមតូច ។

**ការរៀបចំមេរៀនជាមុន**

**គ្រូ** : អានខ្លឹមសារមេរៀននេះឡើងវិញ ដោយឡែកការព្យាបាលផ្ចិតដែលចម្លងរោគ នៅក្នុងសៀវភៅណែនាំ សំរាប់មណ្ឌលសុខភាព ទំព័រ ២៣៣

**គ្រូជំនួយ** : ត្រូវសរសេរ **ការព្យាបាលផ្ចិតដែលចម្លងរោគ** លើក្រដាសផ្ទាំងធំ និងត្រៀមសំភារៈសំរាប់ពិភាក្សាក្រុម

**៣- សកម្មភាព :**

☞ គ្រូត្រូវរៀបចំសិក្ខាកាម សំរាប់ការពិភាក្សាតាមចិត្ត

*សេចក្តីណែនាំនេះមាន ផ្ទួននៅក្នុងសៀវភៅការងារសំរាប់សិក្ខាកាម*

**សកម្មភាព ៣-២-១ ពិភាក្សាតាមចិត្ត**

បំណងនៃសកម្មភាពនេះ គឺណែនាំឱ្យសិក្ខាកាមឱ្យគិតពីបញ្ហាផ្ចិតរបស់កូននាងធីតា

**រយៈពេល** : ៣ នាទី

**ការណែនាំ** : តើទងផ្ចិតកូននាងធីតា មានបញ្ហាអ្វី ?

☞ គ្រូត្រូវផ្តល់នូវចម្លើយត្រឹមត្រូវ : គឺកូននាងធីតាមានការចម្លងរោគ (Infection) នៅទងផ្ចិត ។

☞ គ្រូត្រូវរៀបចំសិក្ខាកាម សំរាប់ពិភាក្សាក្រុមតូច ។

*សេចក្តីណែនាំនេះមាន ស្ទួននៅក្នុងសៀវភៅការងារសំរាប់សិក្ខាកាម*

**សកម្មភាព ៣-២-២ ពិភាក្សាក្រុមតូច**

បំណងនៃសកម្មភាពនេះ គឺណែនាំឱ្យសិក្ខាកាមឱ្យប្រើសៀវភៅណែនាំសំរាប់មណ្ឌលសុខភាព ដើម្បីរកចំលើយមួយពីរោគសញ្ញាគ្លីនិកដែលបានកើតឡើងលើកូននាងធីតា ។

**រយៈពេល** : ១៥ នាទី

**ការណែនាំ** : ក្រុមនិមួយៗ ត្រូវប្រើឯកសារសំអាងសៀវភៅណែនាំសំរាប់មណ្ឌលសុខភាព ដើម្បីសំរេចថា តើត្រូវថែទាំយ៉ាងដូចម្តេច ចំពោះទងផ្ចិតដែលមានការចម្លងរោគ (Infection) ។

**បង្ហាញលទ្ធផល និង ពិភាក្សា**

- តំណាងក្រុមនិមួយៗឡើងបង្ហាញលទ្ធផល ( ៥ នាទីក្នុងមួយក្រុម )
- ទុកពេលអោយសិក្ខាកាមឯទៀតៗសួរ ឬផ្តល់យោបល់ និងតំណាងក្រុមបកស្រាយ
- គ្រូធ្វើការសំយោគចម្លើយសិក្ខាកាម

☞ គ្រូត្រូវអានអត្ថបទខាងក្រោមនេះ ដែលបានដកស្រង់ចេញពីសៀវភៅណែនាំសំរាប់មណ្ឌលសុខភាព ឱ្យសិក្ខាកាមស្តាប់ ដើម្បីបង្ហាញពីផ្លូវ ឬរបៀបនៃការសំរេចចិត្តមួយក្នុង**ការជ្រើសរើសឱសថសារគ្គីនិកត្រឹមត្រូវ** ដូចមាននៅក្នុងប្រអប់ខាងក្រោម ដែលបានជាប់ទាក់ទងទៅនឹងការព្យាបាលត្រឹមត្រូវសំរាប់កូននាងធីតា។

**ការព្យាបាលផ្ចិតដែលចម្លងរោគ**

**គ្រុនក្តៅ :** មានឯកសារសំអាងសៀវភៅណែនាំសំរាប់មណ្ឌលសុខភាពទំព័រ ៨១

១. ស្រាវជ្រាវរកមូលហេតុ : ការបង្ករោគនៅទងផ្ចិតរបស់កូននាងធីតា

២. ឱ្យថ្នាំបន្ថយកំដៅ

★★★ **ប៉ុន្តែសូមប្រុងប្រយ័ត្ន** មុននឹងឱ្យឱសថបន្ថយកំដៅទារក ពិនិត្យផ្នែកមើលនៅក្នុងសៀវភៅណែនាំសំរាប់មណ្ឌលសុខភាព ត្រង់ផ្នែកឱសថបន្ថយកំដៅ។ នៅត្រង់ផ្នែកឱសថបន្ថយកំដៅទំព័រ៣១៧ មានអាស្ពីរីន។ សៀវភៅបញ្ជាក់ថាអាស្ពីរីន មិនសមស្របសំរាប់កុមារអាយុក្រោម១ឆ្នាំឡើយ។ កូននាងធីតាមានអាយុតិចជាងពីរខែ ដូចនេះអាស្ពីរីន មិនគួរនឹងផ្តល់ឱ្យទេ ។ ប៉ារ៉ាសេតាម៉ុល ( ទំព័រ ៣២៤) គឺហាមមិនឱ្យប្រើផងដែរសំរាប់កុមារអាយុក្រោម២ខែ ។ ដូចនេះឱសថបន្ថយកំដៅ គួរកុំផ្តល់ឱ្យកូននាងធីតា ។

៣. កុំគ្របដណ្តប់ ឬរុំទារក ព្រោះធ្វើឱ្យកំដៅកាន់តែកើនឡើង

៤. ជូតខ្លួនទារកដោយក្រណាត់សំពត់សើម

៥. ណែនាំឱ្យនាងធីតាផ្តល់ការបំបៅដោះកូនដូចធម្មតា

**ការធ្វើបង់សឺម៉ង់ទងផ្ចិតសំរាប់ទារក :**

រុំទងផ្ចិតទារក ដោយប្រើស្បៀស្តេរីល និងប៉ូលីវីដោន អ៊ីយូឌីន " មើលឯកសារសំអាង នៅក្នុងសៀវភៅណែនាំសំរាប់មណ្ឌលសុខភាពត្រង់ទំព័រ ២៧៣ " ។ កូនរបស់របស់ធីតា ពុំមែនជាទារកមានអាយុតិចជាង១សប្តាហ៍ឡើយ ដូចនេះ ទងផ្ចិតគួរពុំចាំបាច់រុំទេ ប៉ុន្តែត្រូវរក្សាឱ្យស្ងួត ។

## ជំហានទី៣ : ជ្រើសរើសខ្លឹមសារបង្រៀនសមស្រប

**១-រយៈពេល** : ១ម៉ោង ២៥នាទី

**២-សំភារៈ និង ការរៀបចំជាមុន**

| |
|---|
| **អ្នកនឹងត្រូវការ :** |
| សៀវភៅណែនាំសំរាប់មណ្ឌលសុខភាព ក្រដាសផ្ទាំងធំ /ក្រដាសផ្លា ប៊ិច សំរាប់សកម្មភាពក្រុមតូច |

| |
|---|
| **ការរៀបចំមេរៀនជាមុន :** |
| **គ្រូ:** មើលមេរៀននេះឡើងវិញ ដោយឡែក សេចក្តីសង្ខេបនៅខាងចុងនៃមេរៀននេះ ។ |
| **គ្រូជំនួយ:** |
| ១- មានក្រដាសផ្ទាំងធំដែលមាន **" ជំនឿ អាកប្បកិរិយា និងការរំពឹងទុក របស់នាងធីតា"** ដែលបានសរសេរទុកពីជំហានទី១រួចជាស្រេច |
| ២- រៀបចំក្រដាសផ្ទាំងធំ សំរាប់សកម្មភាពក្រុមតូច ដោយសរសេរផ្លាកភ្ជាប់លើក្រដាស់ទាំង៣សន្លឹក ដូចខាងក្រោមនេះ: |
| **" ផ្លាកទី១ : ជំនឿ "** |
| **" ផ្លាកទី២ : អាកប្បកិរិយា "** |
| **" ផ្លាកទី៣ : ការរំពឹងទុក "** |

**៣- សកម្មភាព :**

☞ គ្រូត្រូវរំលឹកឡើងវិញតាមរយៈ ផ្ទាំងក្រដាសធំនូវអ្វីដែលបានដឹងរួចហើយ អំពី ជំនឿ អាកប្បកិរិយា និងការរំពឹងទុក របស់នាងធីតាក្នុងជំហានទី១ ដែលត្រូវបានរក្សាទុក សំរាប់យកមកប្រើនៅក្នុងសកម្មភាពបន្ទាប់មកទៀត ( យើងមានរយៈពេល ១០នាទី សំរាប់ រំលឹកឡើងវិញនូវផ្នែកនេះ) ។

☞ គ្រូត្រូវរៀបចំសិក្ខាកាម សំរាប់ពិភាក្សាក្រុមតូច ។

☞ គ្រូជំនួយចែកក្រដាសផ្ទាំងធំ /ក្រដាសផ្លា ប៊ិច និង ហ្វឺត អោយក្រុមនិមួយៗ។

*សេចក្តីណែនាំនេះមានស្ទួននៅក្នុងសៀវភៅការងារសំរាប់សិក្ខាកាម*

**សកម្មភាព: ៧-៣-១ ពិភាក្សាក្រុមតូច**

បំណងនៃសកម្មភាពនេះ គឺត្រូវមើលលើក្រដាសផ្ទាំងធំអំពី ជំនឿ អាកប្បកិរិយា និងការរំពឹងទុក របស់នាងធីតា ដែលបានមកពីជំហានទី១ និងកំណត់វិធី ដើម្បីបញ្ចូលចំណុចទាំងនេះ ទៅក្នុងមេរៀនអប់រំសុខភាពដល់នាងធីតា។

**រយៈពេល** : ២០នាទី

**ការណែនាំ** : ក្រុមនិមួយៗត្រូវផ្តល់នូវសកម្មភាពផ្សេងៗពីគ្នា ពួកគេត្រូវយកចិត្តទុកដាក់លើសំណួរដែលបានផ្តល់អោយ និងបន្ទាប់មកជ្រើសរើសយក៣ចំណុចខាងលើនេះ ដើម្បីគិតពិចារណានៅក្នុងការធ្វើគំរោងមេរៀន សំរាប់អប់រំនាងធីតា ដែលបានជាប់ទាក់ទងទៅនឹងសំណួរដូចខាងក្រោមនេះ :

**ក្រុមទី១** : វាយតំលៃអំពី **ជំនឿ** របស់នាងធីតា

- តើអ្វីជាពតិមាន ដែលនាងប្រហែលជាយល់ស្រប តាមបុគ្គលិកមណ្ឌលសុខភាព?

**ក្រុមទី២** : វាយតំលៃអំពី **អាកប្បកិរិយា** របស់នាងធីតា

- តើអ្វីខ្លះ ដែលនាងប្រហែលជាត្រូវធ្វើ?
- តើអ្វីខ្លះ ដែលនាងប្រហែលជាមិនត្រូវធ្វើ?

**ក្រុមទី៣** : វាយតំលៃអំពី **ការរំពឹងទុក** របស់នាងធីតា នៅពេលដែលនាងទៅកាន់មណ្ឌលសុខភាព

- តើអ្វីខ្លះដែលជាតំរូវការសុខភាពផ្នែកអារម្មណ៍ របស់នាងធីតា?

**បង្ហាញលទ្ធផល និង ពិភាក្សា**

- តំណាងក្រុមនិមួយៗឡើងបង្ហាញលទ្ធផល ( ៥ នាទីក្នុងមួយក្រុម )
- ទុកពេលអោយសិក្ខាកាមឯទៀតៗសួរ ឬផ្តល់យោបល់ និងតំណាងក្រុមបកស្រាយ
- គ្រូសំរបសំរួលធ្វើការសំយោគចម្លើយសិក្ខាកាម

✍ **សង្ខេប : គ្រូត្រូវផ្តល់នូវសេចក្តីសង្ខេបខ្លីៗ**

- នាងធីតា **រំពឹងគិត** ថាបានទទួលឱសថ នៅពេលដែលនាងទៅកាន់មណ្ឌលសុខភាព។
- នាងធីតាងូតទឹកឱ្យកូន១ដងក្នុង១ថ្ងៃ ( **អាកប្បកិរិយា**របស់នាង) ។ តើត្រូវបង្រៀននាងយ៉ាងដូចម្តេចក្នុងការថែទាំទងផ្ចិត នៅពេលងូតទឹកឱ្យទារក ?
- នាងធីតា **ជឿ** អ្នកជិតខាងរបស់នាងដែលនិយាយថា **"ការប្រើកំទេចធូលី រោយលើទងផ្ចិតទារក ដើម្បីធ្វើអោយវាជ្រុះបានរហ័ស "** ទង្វើនេះអាចបង្កគ្រោះថ្នាក់ដល់ទារកនៅពេលក្រោយ ប៉ុន្តែ តើត្រូវបញ្ជាក់ហេតុផលអ្វីខ្លះ ទើបធ្វើឱ្យនាងគួរជឿបុគ្គលិក មណ្ឌលសុខភាពដែលផ្តល់នូវការណែនាំអោយនាង ផ្សេងមួយទៀត? ដូចជា :

  - នាងធីតាដឹងថា គ្រុនក្តៅមិនមែនជាការល្អសំរាប់កូននាងទេ ប៉ុន្តែ នាងមិនដឹងថា តើត្រូវធ្វើដូចម្តេចដើម្បី

ព្យាបាលគ្រុនក្តៅដល់កូននាង។ តើនាងបានស្អំទឹក ដើម្បីរក្សាអោយកូននាងត្រជាក់ ឬទេ?

- តើនាងធីតាដឹងថា វាមានសារៈសំខាន់ឬទេ ក្នុងការរក្សាការបំបៅដោះដល់កូននាង ទោះវាយំយ៉ាងខ្លាំងក៏ដោយ ?

☞ គ្រូត្រូវរៀបចំសិក្ខាកាម សំរាប់សកម្មភាពបន្ទាប់ទៀត។ ប្រើក្រុមតូចដដែល។

☺ គ្រូជំនួយត្រូវផ្តល់អោយក្រុមនីមួយៗ នូវក្រដាសផ្ទាំងធំ និង ហ្វឺត។

*សេចក្តីណែនាំនេះមាន ស្ទួននៅក្នុងសៀវភៅការងារសំរាប់សិក្ខាកាម*

**សកម្មភាព ៣-៣-២ ពិភាក្សាក្រុមតូច**

បំណងនៃសកម្មភាពនេះគឺ ណែនាំអោយសិក្ខាកាមប្រើពត៌មានដែលបានដឹងរួចហើយ ដើម្បីរៀបចំមេរៀនមួយសំរាប់បង្រៀននាងធីតា

**រយៈពេល :** ២០នាទី

**ការណែនាំ :** ក្រុមនិមួយៗត្រូវពិភាក្សាថា តើ **ខ្លឹមសារបង្រៀនសមស្រប** អ្វីខ្លះ ដែលគួរបង្រៀននាងធីតា ដើម្បីឱ្យឆ្លើយតប ទៅនឹងចំណុចទាំង៣ (ជំនឿ អាកប្បកិរិយា ការរំពឹងទុក) និង **សេចក្តីសង្ខេប** ខាងលើដែលបានផ្តល់ដោយគ្រូ ?

**បង្ហាញលទ្ធផល និង ពិភាក្សា**

- តំណាងក្រុមនិមួយៗឡើងបង្ហាញលទ្ធផល ( ៥ នាទីក្នុងមួយក្រុម )
- ទុកពេលអោយសិក្ខាកាមឯទៀតៗសួរ ឬផ្តល់យោបល់ និងតំណាងក្រុមបកស្រាយ
- គ្រូធ្វើការសំយោគចម្លើយសិក្ខាកាម

✌ **ចម្លើយចូលរួមរបស់គ្រូ :** ខ្លឹមសារដែលគួរបង្រៀននាងធីតា :

- នាងធីតាគួរទទួលបានការណែនាំ អំពី**ការព្យាបាលត្រឹមត្រូវ** សំរាប់គ្រុនក្តៅ។
- នាងធីតា **រំពឹងទុក** ថា បានទទួលនូវឱសថមួយចំនួនសំរាប់កូននាង។
- **ខ្លឹមសារសមស្រប** គួរពន្យល់ថា ហេតុអ្វីការផ្តល់ឱសថគឺផ្ទុយពីការរំពឹងទុករបស់នាង ហើយជំនួសមកវិញដោយការស្អំត្រជាក់។
- នាងធីតា គួរទទួលបានការណែនាំ អំពីការរក្សាទងផ្ចិតអោយស្ងួត (ធ្វើបង្ហាញពីរបៀបថែទាំផ្ចិត) ។បន្ទាប់មកបង្រៀនអំពីវិធានការបង្ការនៅពេលអនាគត។
- នាងធីតាគួរទទួលបានការណែនាំ លើការត្រួតពិនិត្យនែករកមើលសញ្ញានៃជម្ងឺ ប្រសិនបើសុខភាពកូននាងមិនទាន់បានប្រសើរឡើងតាមរយៈការព្យាបាលដែលអ្នកបានផ្តល់អោយនោះ និងបន្ទាប់មក តើត្រូវធ្វើអ្វីខ្លះទៀត ប្រសិនបើសញ្ញានៃជម្ងឺទាំងនោះកើតឡើង ។

✍ **សង្ខេប** : គ្រូត្រូវសង្ខេប**គោលការណ៍** ដូចមានក្នុងប្រអប់ខាងក្រោមអំពីខ្លឹមសារសមស្រប ដែលបានរៀនរួចហើយ សំរាប់អប់រំអតិថិជន។

*សេចក្តីណែនាំនេះមានស្ទួននៅក្នុងសៀវភៅការងារសំរាប់សិក្ខាកាម*

| |
|---|
| ដើម្បីផ្តល់នូវ **ខ្លឹមសារគ្លីនិកត្រឹមត្រូវ និងខ្លឹមសារបង្រៀនសមស្រប** សំរាប់ការអប់រំអតិថិជន អ្នកត្រូវចាប់ផ្តើមជាមួយ **តំរូវការសុខភាពផ្នែកអារម្មណ៍** របស់មនុស្សម្នាក់ ថាតើអ្វីខ្លះដែលមនុស្សនោះ**រំពឹងទុក** (ឬ ហេតុអ្វីក៏អតិថិជនមិនទៅមណ្ឌលសុខភាព?)។ |

## ជំហានទី៤ : ជ្រើសរើសវិធីសាស្ត្របង្រៀន

**១- រយៈពេល** : ៥០នាទី

**២-សំភារៈ និង ការរៀបចំជាមុន**

| |
|---|
| **អ្នកនឹងត្រូវការ** : ក្តារខៀន ឬក្រដាសផ្ទាំងធំ / ក្រដាសប្លា ប៊ិច ហ្វឺត |

**ការរៀបចំមេរៀនជាមុន :**

**គ្រូ** :រំឭកមេរៀននេះឡើងវិញត្រង់សេចក្តីសង្ខេបស្តីពី **វិធីមួយចំនួនក្នុងការអប់រំអតិថិជនតាមបែបចូលរួម** ដែលមាននៅខាងចុងនៃកំណត់ចំណាំមេរៀននេះ។

**គ្រូជំនួយ** : ត្រៀមជាស្រេច ដើម្បីសរសេរ :

- សំណួរ : តើអ្នកភូមិធ្លាប់រៀនសូត្រយ៉ាងដូចម្តេច?
- កត់ត្រារាល់គំនិតដែលបញ្ចេញដោយសិក្ខាកាមទាំងអស់នៅលើក្តារខៀន ឬក្រដាសផ្ទាំងធំ

**៣- សកម្មភាព :**

☞ គ្រូត្រូវរៀបចំសិក្ខាកាមសំរាប់ពិភាក្សាក្រុមធំ។

☞ គ្រូជំនួយកត់ត្រាចម្លើយចូលរួមរបស់សិក្ខាកាមលើក្តារខៀន ឬលើក្រដាសផ្ទាំងធំ។

*សេចក្តីណែនាំនេះមានស្ទួននៅក្នុងសៀវភៅការងារសំរាប់សិក្ខាកាម*

**សកម្មភាព ៣-៤-១ ពិភាក្សាក្រុមធំ**

បំណងនៃសកម្មភាពនេះ គឺឱ្យសិក្ខាកាមគិតអំពី របៀបដែលប្រជាជនធ្លាប់រៀនសូត្រនៅក្នុងភូមិ ។

**រយៈពេល** : ១០នាទី

**ការណែនាំ** : ពិភាក្សាពីរបៀបដែលជាទំលាប់ នៃការរៀនសូត្រនៅក្នុងភូមិ

**សំណួរ** : តើអ្នកភូមិធ្លាប់រៀនសូត្រយ៉ាងដូចម្តេចខ្លះ?

**ប្រសិនបើសិក្ខាកាមពិបាកយល់ ក្នុងពេលពិភាក្សា គ្រូអាចលើកឡើងនូវឧទាហរណ៍នៃសំណួរបំផុសគំនិតខ្លះៗ ដូចជា :**

- តើកុមាររៀនយ៉ាងដូចម្តេច ដើម្បីថែទាំប្អូនប្រុស ឬស្រីរបស់ពួកគេ?
- តើអ្នកបានរៀនជិះកង់-រៀនស្ទូងស្រូវ-រៀនចាប់កង្កែប-រៀនស្លចត្រី យ៉ាងដូចម្តេច?
- តើអ្នកធ្លាប់រៀនយ៉ាងដូចម្តេចខ្លះ ដើម្បីកុំអោយលង់ទឹក?
- តើរឿងនិទានអ្វីខ្លះ ដែលអ្នកចូលចិត្ត ហេតុអ្វី?
- តើអ្នកបានរៀនយ៉ាងដូចម្តេច ដើម្បី បង្កាត់ភ្លើង ដាំទឹក ? តើអុសអ្វីខ្លះដែលអ្នកត្រូវប្រើ?

**ប្រមូលពត៌មានត្រឡប់ និង ពិភាក្សា :**

- ទុកពេលអោយសិក្ខាកាមសួរ ឬផ្តល់យោបល់ និងបកស្រាយ
- គ្រូធ្វើការសំរបសំរួលចម្លើយសិក្ខាកាម និងបង្ហាញចម្លើយចូលរួម

☝ **ចម្លើយចូលរួម:** គ្រូត្រូវអានសេចក្តីសង្ខេប ស្តីពី វិធីមួយចំនួនក្នុងការអប់រំអតិថិជនតាមបែបចូលរួម ដូចមាននៅក្នុងប្រអប់ខាងក្រោម និងពន្យល់ទៅសិក្ខាកាមថា នេះជារបៀបរបបមួយត្រូវបានគេយកមកប្រើប្រាស់នៅក្នុងការរៀនសូត្ររបស់ប្រជាជននៅតាមសហគមន៍ ។

**វិធីមួយចំនួនក្នុងការអប់រំអតិថិជនតាមបែបចូលរួម**

- អង្គុយនៅទីកន្លែងដែលមានកំពស់ស្មើគ្នា ឱ្យដូចនឹងអ្នកទទួលការអប់រំ ។
- ប្រើពាក្យសំដីទន់ភ្លន់ ដើម្បីស្វាគមន៍ និងការពិភាក្សា ។
- ប្រើប្រាស់បទពិសោធន៍ និងគំនិតរបស់អ្នកទទួលការអប់រំ ធ្វើជាគ្រឹះសំរាប់ធ្វើការអប់រំ ។
- ប្រើប្រាស់ពាក្យសំដីដែលធ្វើឱ្យអ្នកទទួលការអប់រំ ងាយយល់ ។
- សាកសួរនូវសំណួរណា ដែលជួយដល់អ្នកទទួលការអប់រំងាយដោះស្រាយបញ្ហាបាន ។
- ណែនាំអ្នកទទួលការអប់រំ ដើម្បីធ្វើអោយប្រាកដថា គាត់យល់បានត្រឹមត្រូវអំពីពតិមានសុខភាព ។
- ពិនិត្យមើលជាញឹកញាប់ នូវការយល់ដឹងរបស់គាត់ ដែលទទួលបានពីការអប់រំ ។

☞ គ្រូសំរបសំរួលត្រូវបែងចែកសិក្ខាកាមជា៣ក្រុម ដើម្បី ពិភាក្សាក្រុមតូច

*សេចក្តីណែនាំនេះមានស្ទួននៅក្នុងសៀវភៅការងារសំរាប់សិក្ខាកាម*

**សកម្មភាព ៣-៤-២ ពិភាក្សាក្រុមតូច**

បំណងនៃសកម្មភាពនេះ គឺ ឱ្យសិក្ខាកាមប្រើប្រាស់ពត៌មានដែលប្រមូលបានពីមុនមក ដើម្បី **រៀបចំធ្វើជាមេរៀន** មួយសំរាប់អប់រំ ដូចករណីនាងធីតា។

**រយៈពេល :** ២០ នាទី

**ភារៈកិច្ច :** ផ្អែកលើគំនិតទាំងឡាយដែលបានពិភាក្សា និងសរសេរនៅលើក្រដាស់ផ្ទាំងធំកន្លងមក តើមានវិធីបង្រៀនអ្វីខ្លះ ដែលល្អប្រសើរ សំរាប់យកទៅបង្រៀននាងធីតា :

ក- តើទងផ្ចិតដែលមានការក្លាយរោគ មានលក្ខណៈយ៉ាងដូចម្តេច ? (របៀបសំគាល់ទងផ្ចិតមានការក្លាយរោគ)

ខ- តើត្រូវថែទាំទងផ្ចិតយ៉ាងដូចម្តេច?

គ-តើរបៀបស្លំត្រជាក់ ត្រូវធ្វើដូចម្តេចខ្លះ?(របៀបស្លំត្រជាក់)

**ការណែនាំ :** បែងចែកសិក្ខាកាមជា៣ក្រុម ដើម្បីរៀបចំធ្វើគំរោងមេរៀនមួយដោយខ្លួនឯង

- ក្រុម១ : ពិភាក្សាសំណួរ ក
- ក្រុម២ : ពិភាក្សាសំណួរ ខ
- ក្រុម៣ : ពិភាក្សាសំណួរ គ
- ក្រុមនិមួយៗ ត្រូវមានអ្នកសំរបសំរួល១នាក់ អ្នកកត់ត្រា១នាក់ និងអ្នកឡើងបង្ហាញចម្លើយ១នាក់។

**បង្ហាញលទ្ធផល និង ពិភាក្សា**

- តំណាងក្រុមនិមួយៗឡើងបង្ហាញលទ្ធផល (៥នាទីក្នុងមួយក្រុម )
- ទុកពេលអោយសិក្ខាកាមឯទៀតៗសួរ ឬផ្តល់យោបល់ និងតំណាងក្រុមបកស្រាយ
- គ្រូធ្វើការសំរបសំរួលចម្លើយសិក្ខាកាម និងចែករំលែកនូវចំណេះដឹងផ្ទាល់ខ្លួន។

# ជំហានទី៥: ជ្រើសរើសសំភារៈជំនួយ

**១~ រយៈពេល:** ១ម៉ោង

**២~ សំភារៈ និង ការរៀបចំជាមុន:**

**ការរៀបចំមេរៀនជាមុន :**

**គ្រូ :** អានខ្លឹមសារនៃមេរៀនត្រង់ **កំណត់សំគាល់** ( **ការអប់រំសុខភាពកាន់តែប្រសើរឡើង ប្រសិនបើ** ) ដែល ស្ថិតនៅក្នុងប្រអប់ ផ្នែកខាងក្រោយបង្អស់នៃជំហានទី៥នេះ ។

**គ្រូជំនួយ :** ត្រៀមជាស្រេច ដើម្បី ចម្លងនូវកំណត់សំគាល់ដាក់លើក្តារខៀន ឬក្រដាសផ្ទាំងធំ ។

**អ្នកនិងត្រូវការ :**

- ក្តារខៀន និង ក្រដាសផ្ទាំងធំ
- រូបភាពសន្លឹកបត់ ( របៀបស្អំត្រជាក់)
- រូបភាពផ្ទាំងធំ ( របៀបស្អំត្រជាក់)
- រូបភាពផ្ទាំងធំ ( របៀបថែទាំផ្ចិត)
- សំភារៈសំរាប់ថែទាំផ្ចិត
- សំភារៈសំរាប់ស្អំត្រជាក់

**៣-សកម្មភាព :**

☞ គ្រូត្រូវរៀបចំសិក្ខាកាមសំរាប់ការពិភាក្សាតាមចិត្ត

*សេចក្តីណែនាំនេះមានស្ទួននៅក្នុងសៀវភៅការងារសំរាប់សិក្ខាកាម*

**សកម្មភាព ៣-៥-១ ពិភាក្សាតាមចិត្ត**

បំណងនៃសកម្មភាពនេះ គឺអោយសិក្ខាកាមរៀបរាប់នូវសកម្មភាពបន្ទាប់ទៀត ដោយជាដំបូងត្រូវ គិតពីសំភារៈជំនួយសំរាប់បង្រៀន ដែលគេប្រើជាញឹកញាប់នៅក្នុងភូមិ ។

**រយៈពេល** : ៥ នាទី

**ការណែនាំ :** មើលឡើងវិញនូវ **វិធីមួយចំនួនក្នុងការអប់រំអតិថិជនតាមបែបចូលរួម** ដែលបានយកទៅបង្រៀនប្រជាជននៅក្នុងភូមិ មាននៅក្នុងប្រអប់នៃជំហានទី៤ រួចគិតថា :

- តើសំភារៈជំនួយបង្រៀនអ្វីខ្លះដែលត្រូវយកទៅប្រើនៅក្នុងភូមិ?
- តើសំភារៈជំនួយបង្រៀនអ្វីខ្លះ ដែលគួរផ្តល់អោយបុគ្គលិកមណ្ឌលសុខភាព?

☞ គ្រូត្រូវរៀបចំសិក្ខាកាមសំរាប់ល្បែងសំដែងតួ

**ដាក់តាំងបង្ហាញរូបភាព** M 7.P.06 **អោយសិក្ខាកាមមើល**

**រូបភាព**

*សេចក្តីណែនាំនេះមានស្ថិតនៅក្នុងសៀវភៅការងារសំរាប់សិក្ខាកាម*

**សកម្មភាព ៣-៥-២** **ល្បែងសំដែងតួ**

សកម្មភាពនេះមានគោលបំណង អោយសិក្ខាកាមចេះប្រើសំភារៈជំនួយសំរាប់បង្រៀនដែលបានពិភាក្សារួចហើយ ។ តើវិធីបង្រៀន និងសំភារៈជំនួយសំរាប់បង្រៀនអ្វីខ្លះ សមស្របសំរាប់ការអប់រំអតិថិជន?

**រយៈពេល** : ១០នាទីសំរាប់ក្រុមនិមួយៗ

**ការណែនាំ** : បែងចែកសិក្ខាកាមជា២ក្រុម ។ ក្រុមនិមួយៗត្រូវជ្រើសរើសអ្នកស្ម័គ្រចិត្តចំនួន៣នាក់ សំរាប់សំដែងតួ ។

- សិក្ខាកាមទី១ សំដែងតួជា បុគ្គលិកមណ្ឌលសុខភាព
- សិក្ខាកាមទី២ សំដែងតួជា នាងធីតានាំកូនកំពុងក្តៅខ្លួនទៅមណ្ឌលសុខភាព
- សិក្ខាកាមទី៣ សំដែងតួជាប្តីរបស់នាងធីតា

ក្រុមនិមួយៗត្រូវឡើងសំដែងអំពី :

- **របៀបថែទាំទងផ្ចិត** ( ក្រុមទី១ )
- **របៀបស្អំគ្រជាក់** ( ក្រុមទី២ )

នៅពេលដែលក្រុមនិមួយៗកំពុងសំដែង សិក្ខាកាមដ៏ទៃទៀតត្រូវសង្កេតមើល និងកត់ត្រា :

- ខ្លឹមសារសំខាន់ៗនៃការអប់រំសុខភាព
- ជំនាញទំនាក់ទំនង ដែលបានប្រើ ដោយបុគ្គលិកមណ្ឌលសុខភាព
- អាកប្បកិរិយារបស់បុគ្គលិកមណ្ឌលសុខភាពចំពោះនាងធីតា
- ប្រើប្រាស់វិធីសាស្រ្តសមស្របឬទេ?
- ប្រើប្រាស់សំភារៈជំនួយសំរាប់អប់រំ និងធ្វើបង្ហាញគ្រប់គ្រាន់ និងសមស្របឬទេ?

☞ គ្រូត្រូវពន្យល់អំពីភារកិច្ចដល់អ្នកសំដែងតួ

☞ គ្រូជំនួយ : ផ្តល់សំភារៈជំនួយសំរាប់បង្រៀន រូបភាពផ្ទាំងធំ ដល់ក្រុមនិមួយៗ

☞ នៅចុងបញ្ចប់នៃល្បែងសំដែងតួទាំង២ក្រុម គ្រូត្រូវផ្តល់ពេលប្រហែល៥នាទី ដើម្បីអោយសិក្ខាកាមពិភាក្សា ដោយផ្តោតលើចំណុចទាំង២ខាងក្រោម :

- ចំណុចបង្រៀនដែលល្អ
- ចំណុចដែលគួរកែលំអ

✍ **កំណត់សំគាល់ :** គ្រូត្រូវសង្ខេបមេរៀននេះ លើចំណុចសំខាន់ៗឡើងវិញ ។

*សេចក្តីណែនាំនេះមានស្ទួននៅក្នុងសៀវភៅការងារសំរាប់សិក្ខាកាម*

**ការអប់រំសុខភាពកាន់តែប្រសើរឡើង ប្រសិនបើ :**

- ប្រើភាសាសាមញ្ញ ងាយយល់ ។
- សង្កត់លើចំណុចនានា ដែលមានសារៈសំខាន់ជាងគេបំផុត ។
- អ្នកអប់រំ (បុគ្គលិកមណ្ឌលសុខភាព)ប្រើប្រាស់វិធីសាស្ត្របង្រៀន ដែលធ្វើឱ្យអ្នកទទួលការអប់រំសប្បាយរីករាយ ។
- ប្រើសំភារៈជំនួយក្នុងការអប់រំ សមស្រប ធ្វើអោយងាយចងចាំ ។

## ជំហានទី៦: ស្វែងរកព័ត៌មានត្រឡប់ និង ខាយតំលៃការអប់រំ

**១- រយៈពេល :** ៤៥ នាទី

**២- សំភារៈ និង ការរៀបចំជាមុន**

**អ្នកនឹងត្រូវការ:** ក្តារខៀន ក្រដាសផ្ទាំងធំ /ក្រដាសថ្លា និង ហ្វឹត

**ការរៀបចំមេរៀនជាមុន:**

**គ្រូ** : រំលឹកមេរៀននេះឡើងវិញ ដោយឡែកសេចក្តីសង្ខេបនៅផ្នែកខាងចុង នៃកំណត់ចំណាំមេរៀននេះ ។

## ៣- សកម្មភាព:

☞ **គ្រូត្រូវអានសេចក្តីថ្លែងបញ្ជាក់នេះ :** បំណងនៃ **ការស្វែងរកពត៌មានត្រឡប់** គឺដើម្បីធ្វើការវិនិច្ឆ័យ (ឬ**វាយតំលៃ**) ពីកំរិតនៃការយល់ដឹងរបស់អ្នកទទួលមេរៀនអប់រំសុខភាព ។ ដូច្នេះ ដើម្បីទទួលបានទូវពតិមានត្រឡប់ពីការការអប់រំសុខភាព គេត្រូវ : **សង្កេត ស្តាប់ សួរ**

☞ គ្រូត្រូវរៀបចំសិក្ខាកាម សំរាប់ពិភាក្សាក្រុមតូច។

☺ គ្រូជំនួយត្រូវផ្តល់ដល់ក្រុមនិមួយៗ នូវក្រដាសផ្ទាំងធំ និង ប៊ិច។

*សេចក្តីណែនាំនេះមានស្ទួននៅក្នុងសៀវភៅការងារសិក្ខាកាម*

**សកម្មភាព ៣-៦-១** **ពិភាក្សាក្រុមតូច**

បំណងនៃសកម្មភាពនេះគឺណែនាំសិក្ខាកាមឱ្យប្រើប្រាស់បទពិសោធន៍ក្នុងជីវិតពួកគេ នៅពេលរៀនសូត្រ។

**រយៈពេល :** ១០នាទី

**ការណែនាំ :** បំបែកសិក្ខាកាមជា៣ក្រុម :

- ក្រុម១ : ពិភាក្សាសំណួរទី១
- ក្រុម២ : ពិភាក្សាសំណួរទី២
- ក្រុម៣ : ពិភាក្សាសំណួរទី៣
- ក្រុមនិមួយៗ ត្រូវជ្រើសរើសអ្នកសំរបសំរួល១នាក់ អ្នកកត់ត្រា១នាក់ និងអ្នកឡើងបង្ហាញចម្លើយ១នាក់

**សំណួរទី១:** តើអ្នក **សង្កេត** មើលទៅអ្នកទទួលការអប់រំយ៉ាងដូចម្តេច ដើម្បីសំគាល់ថាពួកគេយល់ ឬមិនយល់ ?

**សំណួរទី២:** តើអ្នក **ស្តាប់** យ៉ាងដូចម្តេច ដើម្បីវិនិច្ឆ័យថាពួកគេយល់ ឬមិនយល់ ?

**សំណួរទី៣:** តើអ្នក **សួរ** ទៅអ្នកទទួលការអប់រំយ៉ាងដូចម្តេច ដើម្បីអោយពួកគេបញ្ចេញការយល់ដឹង ?

**បង្ហាញលទ្ធផល និង ពិភាក្សា** (រយៈពេល: ៥នាទីក្នុង១ក្រុម)

- តំណាងក្រុមនិមួយៗឡើងមកបង្ហាញលទ្ធផល
- ទុកពេលអោយសិក្ខាកាមសួរ ឬផ្តល់យោបល់ និងបកស្រាយ
- គ្រូធ្វើការសំរបសំរួលចម្លើយសិក្ខាកាម និងបង្ហាញចម្លើយចូលរួម

☝ **ចម្លើយចូលរួម :** គ្រូត្រូវអាន ចំណុចសង្ខេប ឬចម្លើយចូលរួមដូចខាងក្រោមនេះ

វាមានសារៈសំខាន់ណាស់ក្នុងការស្វែងរកពតិមានត្រឡប់នៅពេលកំពុងអប់រំអតិថិជន។ វិធីសាស្ត្រដែលប្រើមាន :

**សង្កេត :**

- ពីសភាពសំដែងចេញនៅលើផ្ទៃមុខ នៃអ្នកដែលទទួលការអប់រំសុខភាព តើពួកគេមានអាថិកំបាំង ដូចជា ឈឺក្បាល-រីករាយ-ជឿជាក់-បារម្ភ ឬទេ?
- ថាតើពួកគេ បង្ហាញនូវការយល់របស់ពួកគេ ទៅបុគ្គលិកមណ្ឌលសុខភាពវិញយ៉ាងដូចម្តេច ?
- តើពួកគេជឿជាក់ ឬទេ ?
- តើពួកគេមានធ្វើអ្វីខុស ឬទេ ?

**ស្តាប់ :**

- នូវអ្វីដែលអ្នកទទួលការអប់រំ បាននិយាយ
- នូវអ្វីដែលមនុស្សដទៃៗទៀតនៅជុំវិញ បាននិយាយ

**សួរ :**

- អ្នកទទួលការអប់រំដោយប្រើ "សំណួរបើក" ដើម្បីបញ្ជាក់អំពីការយល់ដឹងរបស់ពួកគេ ឧ. ហេតុអ្វី?

**រូបភាពគុបតែងដែលបង្ហាញពីការស្វែងរកពត៌មានត្រឡប់តាមរយៈ សង្កេត ស្តាប់ និងសួរ ។**

**រូបភាពស្តីពី សង្កេត ស្តាប់ និង សួរ**

# ជំហានទី៧: កត់ត្រាសកម្មភាព និង លទ្ធផល

**១-រយៈពេល:** ៣៥នាទី

## ២- សំភារ: និង ការរៀបចំជាមុន

| | |
|---|---|
| **អ្នកនឹងត្រូវការ:** | ក្តារខៀន ក្រដាសផ្ទាំងធំ /ក្រដាសប្លា ប៊ិច និង ហ្វឺត |

**ការរៀបចំមេរៀនជាមុន:**

**គ្រូ** : ១- រំលឹកមេរៀននេះឡើងវិញ : ត្រង់សេចក្តីសង្ខេបស្តីពី *បញ្ជីកត់ត្រាពិនិត្យពិគ្រោះជម្ងឺក្រៅ* ដែលនៅផ្នែកខាងចុងនៃមេរៀននេះ។

២- ធ្វើការវិនិច្ឆ័យអំពីពេលវេលា : ដើម្បីដាក់បញ្ចូលសកម្មភាពអនុវត្តបន្ថែម តាមសភាពការណ៍អំណោយផល ប្រសិនបើពេលវេលាអនុញ្ញាត។

**គ្រូជំនួយ :**

១- គូរនៅលើក្រដាសផ្ទាំងធំនូវ **បញ្ជីកត់ត្រាពិនិត្យពិគ្រោះជម្ងឺក្រៅ** ដែលដកស្រង់ចេញពីសៀវភៅណែនាំ សំរាប់មណ្ឌលសុខភាព ទំព័រ៤១។

២- សំរាប់សកម្មភាពបន្ថែមតាមសភាពការណ៍អំណោយផល :

- សរសេរប្រធានបទនៃល្បែងសំដែងតួ នៅលើក្រដាស់តូចៗ រួចបត់ដាក់លើតុ។
- តំណាងក្រុមនិមួយៗ ដែលត្រូវអនុវត្តល្បែងសំដែងតួ ត្រូវជ្រើសរើសយកក្រដាសដែលបត់នោះមួយសន្លឹក។ ក្រដាសបត់នោះមានប្រធានបទសំរាប់ក្រុមទាំងនោះ។

## ៣- សកម្មភាព

☞ **គ្រូត្រូវអានសេចក្តីថ្លែងបញ្ជាក់នេះ :**

រៀងរាល់ពេលផ្តល់សេវា បុគ្គលិកមណ្ឌលសុខភាពត្រូវកត់ត្រាចូលបញ្ជីតាមផ្នែកនិមួយៗ នៅឯមណ្ឌលសុខភាព។

☞ **ការណែនាំ :** គ្រូដឹកនាំសិក្ខាកាមអនុវត្តរបៀបកត់ត្រាចូលបញ្ជីពិនិត្យពិគ្រោះជម្ងឺក្រៅនៅមណ្ឌលសុខភាព (១៥នាទី)

- គ្រូស្នើសិក្ខាកាមបំពេញក្នុងបញ្ជីពិនិត្យពិគ្រោះជម្ងឺក្រៅ ដោយផ្អែកលើឧទាហរណ៍នៃការព្យាបាលកូននាងធីតា ដែលត្រូវមកទទួលសេវានៅមណ្ឌលសុខភាព។
- ពិភាក្សាអំពីអ្វីខ្លះ ដែលសិក្ខាកាមបានសរសេរនៅក្នុងការចុះបញ្ជី
- សំរេចថា តើអ្វីខ្លះជាពត៌មាន មានប្រយោជន៍ជាងគេ ជាប់ទាក់ទងនឹងការចុះបញ្ជី។

**ចំលើយចូលរួម:** គ្រូត្រូវអានទូវចំណុចចូលរួម និងកែលំអរលើការអនុវត្តន៍ចុះបញ្ជីរបស់សិក្ខាកាម ដូចខាងក្រោម

**ឧទាហរណ៍: គំរូបញ្ជីកត់ត្រាពិនិត្យពិគ្រោះជម្ងឺក្រៅ**

- ខ្ទង់ទី១ : លេខរៀង
- ខ្ទង់ទី២ : លេខបញ្ជី
- ខ្ទង់ទី៣ : ករណីថ្មី
- ខ្ទង់ទី៤ : ករណីចាស់
- ខ្ទង់ទី៥ : ឈ្មោះ
- ខ្ទង់ទី៦ : អាយុ
- ខ្ទង់ទី៧ : ភេទ
- ខ្ទង់ទី៨ : អាស័យដ្ឋានបច្ចុប្បន្ន
- ខ្ទង់ទី៩ : តំបន់ទទួលខុសត្រូវ
- ខ្ទង់ទី១០ : បញ្ជូនមកពី
- ខ្ទង់ទី១១ : រោគសញ្ញា
- ខ្ទង់ទី១២ : បញ្ហាសុខភាព
- ខ្ទង់ទី១៣ : ការព្យាបាល
- ខ្ទង់ទី១៤ : បញ្ជូនទៅមន្ទីរពេទ្យ
- ខ្ទង់ទី១៥ : តំលៃបង់
- ខ្ទង់ទី១៦: សង្កេត

*សំគាល់ : បញ្ជីកត់ត្រាខាងលើនេះ គឺជាគំរូបញ្ជីចាស់ ។ បើសិនគ្រូសំរបសំរួលមានគំរូបញ្ជីថ្មីដែលដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅតាមមណ្ឌលសុខភាពនាពេលបច្ចុប្បន្ន ហើយអាចយកមកប្រើប្រាស់បានក្នុងការអនុវត្តន៍នាឱកាសនេះ រឹតតែល្អប្រសើរ ។*

☞ **សកម្មភាពអនុវត្តជំនាញសិក្ខាកាម តាមសភាពការណ៍អំណោយផល :**

- បំបែកសិក្ខាកាមទាំងអស់ទៅជាចំនួនក្រុមតូចៗតាមតំរូវការ ដោយក្នុង១ក្រុមៗ ត្រូវមានសមាជិក៥នាក់ ។
- មានសិក្ខាកាមស្ម័គ្រចិត្ត២នាក់ ជាអង្កេតការណ៍ ដោយប្រើ *បញ្ជីត្រួតពិនិត្យសមត្ថភាព* នៃទំរង់ដែលមាន៧ ជំហានរបស់ដំណើរការនៃការអប់រំសុខភាព
- សិក្ខាកាម៣នាក់នៅក្នុងក្រុមនិមួយៗ ត្រូវជ្រើសរើសប្រធានបទម្នាក់មួយៗសំរាប់សំដែងតួ
- ក្រុមតូចៗនិមួយៗត្រូវរៀបចំធ្វើបង្ហាញតាមទំរង់ដែលមាន៧ជំហានរបស់ដំណើរការនៃការអប់រំសុខភាព។
- ប្រធានបទនៃល្បែងសំដែងតួ មាន :

  ១- បង្រៀនអំពីការប្រើឱសថព្យាបាលគ្រុនក្តៅ

  ២- បង្រៀនម្តាយ តើត្រូវព្យាបាលកូននាង ដែលមានជំងឺរាកមធ្យមយ៉ាងដូចម្តេច?

  ៣- បង្រៀននរណាម្នាក់ដែលបានត្រូវធ្វើរោគវិនិច្ឆ័យថា មានជម្ងឺកាមរោគឬក៏ HIV វិជ្ជមាន និង របៀបប្រើស្រោមលឹង្គយ៉ាងដូចម្តេច?

  ៤- បង្រៀននរណាម្នាក់ដែលត្រូវបានធ្វើរោគវិនិច្ឆ័យថា មានជំងឺរបេង និងតំរូវអោយលេបថ្នាំរបេងរបស់គាត់

  ៥- បង្រៀនថាតើត្រូវធ្វើយ៉ាងដូចម្តេចដើម្បី រក្សាជំងឺបៅកុំអោយមានការចម្លងរោគ

  ៦- បង្រៀនពីសារៈសំខាន់នៃការផឹកទឹកឆ្អិន នៅពេលដែលការផ្គត់ផ្គង់ទឹក មានការចម្លងរោគ

  ៧- បង្រៀនម្តាយដែលកូនរបស់គាត់មានជម្ងឺផ្លូវដង្ហើមស្រួចស្រាវ ថាតើត្រូវកត់សំគាល់រោគសញ្ញានៃជម្ងឺយ៉ាងដូចម្តេច ប្រសិនបើកូនគាត់កាន់តែឈឺធ្ងន់ឡើងៗ

# មេរៀនទី២ : ការប្រើប្រាស់សំភារៈសំរាប់ការអប់រំសុខភាព

**១- រយៈពេល** : ៣ម៉ោង ២៥នាទី

**២- វត្ថុបំណងសិក្សា** : នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមទាំងអស់ នឹងអាចៈ

- កំណត់លក្ខណៈចំបងនៃរូបភាពផ្ទាំងធំ រូបភាពសន្លឹកបត់ និងសៀវភៅសន្លឹកផ្ទាត់
- ជ្រើសរើសសំភារៈអប់រំសុខភាពសមស្របសំរាប់ ការអប់រំសុខភាព និង ការលើកកំពស់សុខភាព
- កំណត់របៀបប្រើប្រាស់រូបភាពផ្ទាំងធំ រូបភាពសន្លឹកបត់ សៀវភៅសន្លឹកផ្ទាត់
- អនុវត្តការប្រើប្រាស់បានត្រឹមត្រូវនូវ រូបភាពផ្ទាំងធំ រូបភាពសន្លឹកបត់ សៀវភៅសន្លឹកផ្ទាត់

**តើមេរៀននេះជាប់ទាក់ទងយ៉ាងដូចម្តេចទៅនឹងការងាររបស់បុគ្គលិកមណ្ឌលសុខភាព?**

មេរៀននេះនឹងជួយដល់បុគ្គលិកមណ្ឌលសុខភាពអោយជ្រើសរើស និងប្រើប្រាស់រូបភាពផ្ទាំងធំ រូបភាពសន្លឹកបត់ សៀវភៅសន្លឹកផ្ទាត់ បានត្រឹមត្រូវសំរាប់ការអប់រំសុខភាព និងការលើកកំពស់សុខភាព។

**៣-សំភារៈ និងការរៀបចំជាមុន**

**អ្នកនឹងត្រូវការ** : ជំរើសនៃ

- រូបភាពផ្ទាំងធំ
- រូបភាពសន្លឹកបត់
- សៀវភៅសន្លឹកផ្ទាត់
- ក្រដាសផ្ទាំងធំ និងប៊ិច សំរាប់សកម្មភាពក្រុមតូច

**ការរៀបចំមេរៀនជាមុន**

**គ្រូ** : អានមេរៀននេះឡើងវិញ

**គ្រូជំនួយ** :

១. រៀបចំផ្លាកក្រដាសចំនួន៣ សំរាប់សរសេរសំគាល់ :

- រូបភាពផ្ទាំងធំ
- រូបភាពសន្លឹកបត់
- សៀវភៅសន្លឹកផ្ទាត់

បត់ក្រដាសធ្វើជាផ្លាក ត្រូវធ្វើយ៉ាងណាឱ្យផ្លាកនោះអាចឈរនៅនឹងតែឯងបាន ហើយងាយស្រួលមើលឃើញផង។

២. សរសេរនៅលើក្រដាសផ្ទាំងធំនូវ និយមន័យទាំងនេះ :

- **រូបភាពផ្ទាំងធំ** : "ផ្ទាំងក្រដាសធំមួយសន្លឹកដែលមាន ពាក្យ រូបភាព ឬនិមិត្តសញ្ញាទាំងឡាយ ដែលផ្តល់ជាសារមួយ "។
- **រូបភាពសន្លឹកបត់** : "ផ្ទាំងក្រដាសបត់មួយសន្លឹក ដែលមានរូបភាព និងសារ សំរាប់ចែកអោយប្រជាជនមើល និងអាន " ។
- **សៀវភៅសន្លឹកផ្ទាត់** : "ផ្ទាំងរូបភាព និងសារមួយចំនួន ដែលមានទំហំប៉ុនគ្នា ចងភ្ជាប់ជាមួយគ្នា ប្រើសំរាប់ធ្វើការបង្ហាញ មួយសន្លឹកម្តង១ បន្តបន្ទាប់គ្នា ដើម្បីធ្វើជាជំនួយដល់ការនិយាយពន្យល់ "

៣. សរសេរសេចក្តីសង្ខេបនៃ" **អ្វីដែលត្រូវធ្វើ និងអ្វីដែលមិនត្រូវធ្វើ** " សំរាប់សំភារៈអប់រំសុខភាពនិមួយ១នៅលើក្រដាសផ្ទាំងធំ ដែលមាននៅក្នុងប្រអប់ ទំព័រ៧៤។

**៣ -សកម្មភាព:**

## វត្ថុបំណងទី១: កំណត់លក្ខណៈចំបងនៃរូបភាពផ្ទាំងធំ រូបភាពសន្លឹកបត់ និងសៀវភៅសន្លឹកផ្ទាត់ ។

☞ **គ្រូត្រូវចាប់ផ្តើមសួរសិក្ខាកាម :** តើសំភារៈសំរាប់អប់រំសុខភាពមានអ្វីខ្លះ?

☺ **គ្រូជំនួយត្រូវបង្ហាញប្រភេទសំភារៈ**

- រូបភាពផ្ទាំងធំ
- រូបភាពសន្លឹកបត់
- សៀវភៅសន្លឹកផ្ទាត់

☺ **គ្រូជំនួយត្រូវដាក់ផ្លាក នៅលើតុ៣ផ្សេងៗពីគ្នា ឬ នៅលើកំរាលឥដ្ឋ ដោយបំបែកផ្លាកនោះឱ្យឃ្លាតចេញពីគ្នា**

- ផ្លាកទី១ : រូបភាពផ្ទាំងធំ
- ផ្លាកទី២ : រូបភាពសន្លឹកបត់
- ផ្លាកទី៣ : សៀវភៅសន្លឹកផ្ទាត់

**រូបភាពតុបតែង ស្ដីពី របៀបធ្វើផ្លាក**

**រូបភាពបង្ហាញពីរបៀបធ្វើផ្លាក**

**ពិភាក្សាក្រុមធំ ( រយៈពេល២៥ នាទី)**

**សំណួរ : ដូចម្តេចដែលហៅថា រូបភាពផ្ទាំងធំ?**

**ចំលើយ:** គឺជាផ្ទាំងក្រដាសធំមួយសន្លឹកដែលមាន ពាក្យ រូបភាព ឬនិមិត្តសញ្ញាទាំងឡាយ ដែលផ្តល់ជាសារមួយ ។

**សំណួរ : ដូចម្តេចដែលហៅថា រូបភាពសន្លឹកបត់?**

**ចំលើយ :** គឺជាផ្ទាំងក្រដាសបត់មួយសន្លឹក ដែលមានរូបភាព និងសារ សំរាប់ចែកអោយប្រជាជនមើល និងអាន ។

**សំណួរ : ដូចម្តេចដែលហៅថាសៀវភៅសន្លឹកផ្ទាត់?**

**ចំលើយ :** គឺជា ផ្ទាំងរូបភាព និងសារមួយចំនួន ដែលមានទំហំប៉ុនគ្នា ចងភ្ជាប់ជាមួយគ្នា ប្រើ សំរាប់ធ្វើការបង្ហាញមួយសន្លឹកម្តងៗ បន្តបន្ទាប់គ្នា ដើម្បីធ្វើជាជំនួយដល់ការនិយាយពន្យល់ ។

## វត្ថុបំណងទី២: ជ្រើសរើសសំភារៈអប់រំសុខភាពសមស្របសំរាប់ ការអប់រំសុខភាព និងការលើកកំពស់សុខភាព

☞ គ្រូត្រូវលើកបង្ហាញ **បញ្ជីត្រួតពិនិត្យសមត្ថភាព** ដែលនឹងត្រូវយកមកប្រើប្រាស់ ដើម្បីបង្រៀន អំពី ការប្រើប្រាស់សំភារៈសំរាប់អប់រំសុខភាព។ មេរៀននេះនឹងបង្រៀនពីចំណុចទី១ ដល់ទី២ ក្នុងបញ្ជីត្រួតពិនិត្យសមត្ថភាព ក្នុងប្រអប់ខាងក្រោម។

*សេចក្ដីណែនាំនេះមានស្ទួននៅក្នុងសៀវភៅការងារសំរាប់សិក្ខាកាម*

| **បញ្ជីត្រួតពិនិត្យសមត្ថភាព : ការជ្រើសរើស និង ការប្រើប្រាស់សំភារៈសំរាប់អប់រំសុខភាព** |
|---|
| ១- កំណត់ថា តើសំភារៈមួយណា ឬការរួមបញ្ចូលនៃសំភារៈណាខ្លះ ដើម្បីប្រើប្រាស់អោយស៊ីសង្វាក់ជាមួយស្ថានភាព |
| ២- លទ្ធភាពដើម្បីរៀបចំតាំងបង្ហាញសំភារៈ ឱ្យបានត្រឹមត្រូវ (ទីកន្លែង-របៀបដាក់តាំង) |
| ៣- វាស់វែងកំរិតនៃការយល់ដឹងរបស់អតិថិជន លើចំណុចសំខាន់ៗនៃសារសុខភាពនិមួយៗ។ |
| ៤- លទ្ធភាព ដើម្បីពន្យល់ច្បាស់លាស់ អំពីខ្លឹមសារសំខាន់ៗនៃសំភារៈទាំងនោះ |
| ៥- ជំរុញលើកទឹកចិត្ត អតិថិជនអោយចូលរួមក្នុងការប្រើសំភារៈទាំងនោះ |
| ៦- វាយតំលៃការយល់ដឹងរបស់អតិថិជន |
| ៧- ធ្វើផ្ទួនៗឡើងវិញ នូវចំណុចសំខាន់ៗទាំងឡាយដែលបានរៀនសូត្រ |

☞ គ្រូត្រូវធ្វើបង្ហាញទៅសិក្ខាកាម ពីការរៀបចំតាំងបង្ហាញ រូបភាពផ្ទាំងធំ រូបភាពសន្លឹកបត់ និង សៀវភៅសន្លឹកផ្ទាត់

- **រូបភាពផ្ទាំងធំ** គួរបិទ ឬព្យួរ នៅលើជញ្ជាំង ក្នុងកំពស់សមស្រប។ ដូចនេះមនុស្សជាច្រើនអាចមើលវាឃើញ។
- **សៀវភៅសន្លឹកផ្ទាត់** អាចត្រូវដាក់នៅលើតុ ឬកៅអី ដោយមានកន្លែងមួយសំរាប់ឱ្យគ្រូឈរនៅពីក្រោយ ហើយអាចអានអត្ថបទដែលនៅលើផ្នែកខាងក្រោយ ក្នុងពេលដែលអ្នកស្ដាប់ទាំងឡាយអាចមើលឃើញ រូបភាពនៅផ្នែកខាងមុខនៃសៀវភៅសន្លឹកផ្ទាត់។
- **រូបភាពសន្លឹកបត់** ត្រូវចែកទៅអោយអតិថិជន និងនិយាយពន្យល់ដោយអង្គុយកៅអីពីរក្បែរគ្នា។

ការពន្យល់ទៅសិក្ខាកាមត្រូវបញ្ចូលនូវការប្រើប្រាស់សមស្របនៃ រូបភាពផ្ទាំងធំ រូបភាពសន្លឹកបត់ សៀវភៅសន្លឹកផ្ទាត់

☞ គ្រូត្រូវរៀបចំសិក្ខាកាម សំរាប់សកម្មភាពពិភាក្សាក្រុមតូច

☞ គ្រូជំនួយ ផ្តល់ឱ្យក្រុមនិមួយៗ នូវក្រដាស់ផ្ទាំងធំ និងហ្វឺត

*សេចក្តីណែនាំនេះមានស្នួននៅក្នុងសៀវភៅការងារសំរាប់សិក្ខាកាម*

**សកម្មភាព ៤-២-១ ពិភាក្សាក្រុមតូច**

បំណងនៃសកម្មភាពនេះគឺឱ្យសិក្ខាកាមចែករំលែកចំណេះដឹងពីគ្នាទៅវិញទៅមក នូវអ្វីដែលពួកគេបានដឹងពីមុនរួចហើយ អំពី រូបភាពផ្ទាំងធំ រូបភាពសន្លឹកបត់ និងសៀវភៅសន្លឹកផ្ទាត់។

**រយៈពេល :** ២០នាទី

**ការណែនាំ :** ក្រុមនិមួយៗយកកញ្ចប់ ដែលជាប្រភេទនិមួយៗ នៃសំភារៈសំរាប់ការអប់រំសុខភាព។ ឧទាហរណ៏ៈ

- ក្រុមទី១ : យករូបភាពផ្ទាំងធំទាំងអស់
- ក្រុមទី២ : យករូបភាពសន្លឹកបត់ទាំងអស់ និង
- ក្រុមទី៣ : យកសៀវភៅសន្លឹកផ្ទាត់ទាំងអស់

សិក្ខាកាមទាំ៣ក្រុម ត្រូវរៀបចំតាំងបង្ហាញ នូវរូបភាពទាំងនោះ ដោយផ្អែកតាមការធ្វើបង្ហាញរបស់គ្រូពីលើកមុន។ បន្ទាប់មកក្រុមនិមួយៗ ត្រូវពិភាក្សាសំណួរ ដោយឡែកៗរបស់ពួកគេ :

**ក្រុមទី១:** - តើរូបភាពផ្ទាំងធំត្រូវអោយទៅអ្នកណាខ្លះ? តើនៅក្នុងស្ថានភាពណាខ្លះ ដែលរូបភាពផ្ទាំងធំត្រូវបានយកមកប្រើ និង មិនត្រូវបានយកមកប្រើ?(សង្កត់ទៅលើស្ថានភាពមិនមែនខ្លឹមសារទេ)

- តើគេប្រើរូបភាពផ្ទាំងធំក្នុងគោលបំណងអ្វីខ្លះ?

**ក្រុមទី២:** - តើរូបភាពសន្លឹកបត់ត្រូវអោយទៅអ្នកណាខ្លះ? តើនៅក្នុងស្ថានភាពណាខ្លះ ដែលរូបភាពសន្លឹកបត់ ត្រូវបានយកមកប្រើ និងមិនត្រូវបានយកមកប្រើ?(សង្កត់ទៅលើស្ថានភាពមិនមែនខ្លឹមសារទេ)

- តើគេប្រើរូបភាពសន្លឹកបត់ក្នុងគោលបំណងអ្វីខ្លះ?

**ក្រុមទី៣:** - តើសៀវភៅសន្លឹកផ្ទាត់ត្រូវអោយទៅអ្នកណាខ្លះ? តើនៅក្នុងស្ថានភាពណាខ្លះ ដែលសៀវភៅសន្លឹកផ្ទាត់ត្រូវបាន យកមកប្រើ និង មិនត្រូវបានយកមកប្រើ?(សង្កត់ទៅលើស្ថានភាពមិនមែនខ្លឹមសារទេ)

- តើគេប្រើសៀវភៅសន្លឹកផ្ទាត់ ក្នុងគោលបំណងអ្វីខ្លះ?

**បង្ហាញលទ្ធផល និង ពិភាក្សា**

- តំណាងក្រុមនិមួយៗឡើងមកបង្ហាញលទ្ធផល (៥នាទីក្នុង១ក្រុម)
- ទុកពេលអោយសិក្ខាកាមឯទៀតៗសួរ ឬផ្តល់យោបល់ និងតំណាងក្រុមបកស្រាយ
- ផ្តល់ចំឡើយចូលរួមរបស់គ្រូ

✍**ចំលើយចូលរួម :** គ្រូត្រូវអានសេចក្តីសង្ខេបនៃបញ្ជីដែលបានសរសេរទុកជាមុននៅលើក្រដាស់ផ្ទាំងធំ

ត្រង់ទំព័រ៧៤ និងតារាងទំព័រ៧៥ ដូចខាងក្រោម ។

**១- រូបភាពផ្ទាំងធំ :**

**កិច្ចការដែលត្រូវធ្វើ :**

- ដាក់ រូបភាពផ្ទាំងធំនៅត្រង់កន្លែងណាដែលមានមនុស្សជាច្រើនឆ្លងកាត់ នៅក្នុងភូមិ សាលារៀន មណ្ឌលសុខភាព គ្លីនិក ឯកជន ការិយាល័យ ភោជនីយដ្ឋាន ។ល ។
- សុំការអនុញ្ញាតពីដំបូងសិន មុននឹងដាក់តាំងបង្ហាញ នូវរូបភាពផ្ទាំងធំ
- ស្នើអោយអ្នកចូលរួមអាន និង មើលរូបភាពស្តីពីការអប់រំសុខភាព

**កិច្ចការដែលមិនត្រូវធ្វើ :**

- កាន់ រូបភាពផ្ទាំងធំដោយខ្លួនឯង ហើយចាប់ផ្តើមពន្យល់លំអិត
- បិទតាំងរូបភាពផ្ទាំងធំច្រើនសន្លឹក នៅត្រង់កន្លែងតែមួយ

**២- រូបភាពសន្លឹកបត់ :**

**កិច្ចការដែលត្រូវធ្វើ :**

- ប្រើរូបភាពសន្លឹកបត់ ដើម្បីពង្រឹងបន្ថែមការយល់ដឹងនៅក្នុងភូមិ
- ពន្យល់ខ្លឹមសារលំអិតលើរូបភាព និងចែកអោយប្រជាជនយកទៅផ្ទះ
- ប្រើនៅក្នុងពេលពិភាក្សាក្រុមតូច

**កិច្ចការដែលមិនត្រូវធ្វើ :**

- ព្យួររូបភាពសន្លឹកបត់
- ចែកចាយទៅអោយសហគមន៍ ដោយមិនបានពន្យល់
- បង្ហាញអ្នកស្តាប់ ដែលមានចំនួនច្រើន

**៣- សៀវភៅសន្លឹកផ្ទាត់ :**

**កិច្ចការដែលត្រូវធ្វើ :**

- ប្រើដើម្បីជួយដល់វគ្គអប់រំសុខភាពមួយ
- អង្គុយនៅពីខាងក្រោយសៀវភៅសន្លឹកផ្ទាត់ហើយអានអត្ថបទដែលមាននៅផ្នែកខាងក្រោយ ដោយពន្យល់រូបភាព ដែលអ្នកស្តាប់អាចមើលឃើញ ។
- ប្រើសំរាប់ ការប្រជុំតូច
- ត្រូវប្រាកដថា គ្រប់ៗគ្នាអាចមើលឃើញរូបភាពច្បាស់

**កិច្ចការដែលមិនត្រូវធ្វើ :** ដាក់តាំងដូច រូបភាពផ្ទាំងធំ

| | **រូបភាពផ្ទាំងធំ** | **រូបភាពសន្លឹកបត់** | **សៀវភៅសន្លឹកផ្ទាត់** |
|---|---|---|---|
| **ផ្តល់ឱ្យនរណា** | - គ្រូបង្រៀន<br>- ប្រធានភូមិ-ឃុំ<br>- ឆ្មបបុរាណ<br>- ក្រុមទ្រទ្រង់សុខភាពភូមិ<br>- អាចារ្យវត្ត<br>- ម្ចាស់ភោជនីយដ្ឋាន<br>- ម្ចាស់គ្លីនិកឯកជន | - ប្រជាជន<br>- អ្នកជម្ងឺ | - ឆ្មបបុរាណ<br>- ក្រុមទ្រទ្រង់សុខភាពភូមិ<br>- បុគ្គលិកមណ្ឌលសុខភាពដែលទទួលបន្ទុកអប់រំសុខភាព |
| **ដាក់តាំងបង្ហាញនៅកន្លែងណា** | - ក្នុងភូមិ<br>- សាលារៀន<br>- ការិយាល័យ<br>- គ្លីនីកឯកជន<br>- មណ្ឌលសុខភាព<br>- ភោជនីយដ្ឋាន<br>- វត្តអារាម | - មិនត្រូវដាក់តាំងទេ | - មិនត្រូវដាក់តាំងទេ |
| **នៅពេលណា** | - មានរោគត្បាតនៃជម្ងឺ<br>- មានការអនុញ្ញាត្តពីអាជ្ញាធរដែនដី និងម្ចាស់ទីកន្លែង<br>- យុទ្ធនាការ | -ប្រជាជនមកមណ្ឌលសុខភាព<br>- ចុះទៅអប់រំតាមសហគមន៍ | - ប្រជាជនមកមណ្ឌលសុខភាព<br>- ចុះទៅអប់រំតាមសហគមន៍ |
| **គោលបំណង** | - ផ្សព្វផ្សាយជាចំហរនូវពត៌មានស្តីពីការអប់រំសុខភាព ។ | - ពង្រឹងបន្ថែមការចងចាំលើពត៌មាន ក្រោយពីបានពន្យល់ | -ជួយអ្នកអប់រំសុខភាពក្នុងការងារអប់រំនៅម.សនិងសហគមន៍ |

## វត្ថុបំណងទី៣ : កំណត់របៀបប្រើប្រាស់ រូបភាពផ្ទាំងធំ រូបភាពសន្លឹកបត់ និងសៀវភៅសន្លឹកផ្ទាត់

☞ គ្រូត្រូវលើកបង្ហាញសារជាថ្មីម្តងទៀតនូវ **បញ្ជីត្រួតពិនិត្យសមត្ថភាព** ដែលបានរៀនរួចហើយនៅក្នុងវត្ថុបំណងទី២ ។ បញ្ជីនេះនឹងត្រូវយកមកប្រើជាបន្តទៀត ដើម្បី បង្រៀនពីការប្រើប្រាស់សំភារៈសំរាប់អប់រំសុខភាព ចាប់ពី ចំណុចទី **៣, ៤, ៥, ៦ ដល់ ទី៧** ។

**បញ្ជីត្រួតពិនិត្យសមត្ថភាព : ការជ្រើសរើស និង ការប្រើប្រាស់សំភារៈសំរាប់អប់រំសុខភាព**

១- កំណត់ថា តើសំភារៈមួយណា ឬការរួមបញ្ចូលនៃសំភារៈណាខ្លះ ដើម្បីប្រើប្រាស់អោយស៊ីសង្វាក់ជាមួយស្ថានភាព

២- លទ្ធភាពដើម្បីរៀបចំតាំងបង្ហាញសំភារៈ ឱ្យបានត្រឹមត្រូវ (ទីកន្លែង-របៀបដាក់តាំង)

៣- វាស់វែងកំរិតនៃការយល់ដឹងរបស់អតិថិជន លើចំណុចសំខាន់ៗនៃសារសុខភាពនិមួយៗ ។

៤- លទ្ធភាព ដើម្បីពន្យល់ច្បាស់លាស់ អំពីខ្លឹមសារសំខាន់ៗនៃសំភារៈទាំងនោះ

៥- ជំរុញលើកទឹកចិត្ត អតិថិជនអោយចូលរួមក្នុងការប្រើសំភារៈទាំងនោះ

៦- វាយតំលៃការយល់ដឹងរបស់អតិថិជន

៧- ធ្វើផ្ទួនៗឡើងវិញ នូវចំណុចសំខាន់ៗទាំងឡាយដែលបានរៀនសូត្រ

☞ គ្រូត្រូវរៀបចំតាំងបង្ហាញ រូបភាពផ្ទាំងធំ១សន្លឹក នៅលើជញ្ជាំង និងចំពីមុខសិក្ខាកាម

☞ គ្រូត្រូវរៀបចំសកម្មភាពសំរាប់ពិភាក្សាក្រុមធំ ដោយដាក់តាំងបង្ហាញរូបភាពផ្ទាំងធំនៅពីមុខសិក្ខាកាម ។

*សេចក្តីណែនាំនេះមានស្ទួននៅក្នុងសៀវភៅការងារសំរាប់សិក្ខាកាម*

**សកម្មភាព ៤-៣-១ ពិភាក្សាក្រុមធំ**

បំណងនៃសកម្មភាពនេះ គឺអោយសិក្ខាកាមចែករំលែកចំណេះដឹងអំពីអ្វី ដែលពួកគេបានដឹងនូវរបៀបនៃការប្រើប្រាស់រូបភាពផ្ទាំងធំ ។

**រយៈពេល** : ៥ នាទី

**ការណែនាំ** : គ្រូសួរទៅសិក្ខាកាម :

សំណួរ : តើរូបភាពផ្ទាំងធំនេះ ប្រើប្រាស់យ៉ាងដូចម្តេច?

**ប្រមូលពត៌មានត្រឡប់ និង ពិភាក្សា** (រយៈពេល ៥នាទី)

☞ គ្រូសួរទៅសិក្ខាកាមដើម្បីទទួលបាននូវពត៌មានត្រឡប់ ។

☞ គ្រូជំនួយកត់ត្រាចម្លើយចូលរួមរបស់សិក្ខាកាម

☞ គ្រូធ្វើការសំរបសំរួលចម្លើយចូលរួមរបស់សិក្ខាកាម រួចបង្ហាញរបៀបប្រើប្រាស់រូបភាពផ្ទាំងធំ ដែលមានក្នុងប្រអប់ខាងក្រោម ។

**របៀបប្រើប្រាស់រូបភាពផ្ទាំងធំ :**

- មិនត្រូវឈរនៅចំពីមុខ ផ្ទាំងរូបភាព ជាហេតុធ្វើអោយប្រជាជនមិនអាចមើលឃើញ
- មិនត្រូវកាន់វាដោយខ្លួនឯង នៅពេលដែលអ្នកនិយាយពន្យល់ អំពី ផ្ទាំងរូបភាពនោះ
- ទុកពេលអោយអ្នកទទួលការអប់រំ គិត
- បន្ទាប់មកសួរទៅអ្នកទទួលការអប់រំពីអ្វីខ្លះដែលពួកគេបានឃើញ និងតើរូបភាពនេះមានន័យអ្វីខ្លះ?
- កែតំរូវរាល់ការភាន់ច្រឡំ និងអ្វីដែលមិនទាន់យល់ច្បាស់
- សង្ខេបឡើងវិញ ឬរំលឹកឡើងវិញ



☞ គ្រូត្រូវរៀបចំសកម្មភាពសំរាប់ពិភាក្សាសំណួរបំផុសគំនិត ដោយចែករូបភាពសន្លឹកបត់ឱ្យសិក្ខាកាមមើល។

*សេចក្តីណែនាំនេះមានស្ទួននៅក្នុងសៀវភៅការងារសំរាប់សិក្ខាកាម*

**សកម្មភាព ៤-៣-២** **សំណួរបំផុសគំនិត**

បំណងនៃសកម្មភាពនេះ គឺណែនាំសិក្ខាកាមឱ្យចែករំលែកចំណេះដឹងអំពីអ្វីដែលពួកគេបានដឹងពីមុន នូវរបៀបនៃការប្រើប្រាស់រូបភាពសន្លឹកបត់ ។

**រយៈពេល** : ១៥នាទី

**ការណែនាំ** : គ្រូសួរទៅសិក្ខាកាម ។ សំណួរ : តើរូបភាពសន្លឹកបត់នេះ ប្រើប្រាស់យ៉ាងដូចម្តេច ?

**ប្រមូលពត៏មានត្រឡប់ និង ពិភាក្សា** (រយៈពេល ៥នាទី)

☞ គ្រូសួរទៅសិក្ខាកាមដើម្បីទទួលបាននូវពត៌មានត្រឡប់ ។

☞ គ្រូជំនួយកត់ត្រាចម្លើយចូលរួមរបស់សិក្ខាកាម

☞ គ្រូធ្វើការសំរបសំរួលចម្លើយចូលរួមរបស់សិក្ខាកាម រួចបង្ហាញរបៀបប្រើប្រាស់រូបភាពសន្លឹកបត់ ។

**របៀបប្រើប្រាស់រូបភាពសន្លឹកបត់ :**

- បង្ហាញរូបភាព ពេលកំពុងអប់រំ
- ទុកពេលអោយអ្នកទទួលការអប់រំគិត
- បន្ទាប់មកសួរអ្នកទទួលការអប់រំនូវអ្វីដែលពួកគេបានឃើញ និងថា តើរូបភាពទាំងនោះមានន័យដូចម្តេច?
- កែតំរូវនូវអ្វី ដែលមិនទាន់យល់ច្បាស់



☞ គ្រូត្រូវរៀបចំសកម្មភាពសំរាប់ពិភាក្សាសំណួរបំផុសគំនិត ដោយដាក់តាំងបង្ហាញសៀវភៅសន្លឹកផ្ទាត់ឱ្យសិក្ខាកាមមើល។ *សេចក្តីណែនាំនេះមានស្ទួននៅក្នុងសៀវភៅការងារសំរាប់សិក្ខាកាម*

**សកម្មភាព ៤-៣-៣ សំណួរបំផុសគំនិត**

បំណងនៃសកម្មភាពនេះ គឺណែនាំសិក្ខាកាមឱ្យចែករំលែកចំណេះដឹងអំពីអ្វីដែលពួកគេបានដឹងរួចហើយ នូវរបៀបនៃការប្រើប្រាស់សៀវភៅសន្លឹកផ្ទាត់។

**រយៈពេល** : ១៥នាទី

**ការណែនាំ** : គ្រូសួរទៅសិក្ខាកាម :

សំណួរ : តើសៀវភៅសន្លឹកផ្ទាត់ ប្រើប្រាស់យ៉ាងដូចម្តេច?

**ប្រមូលពត៌មានត្រឡប់ និង ពិភាក្សា** (រយៈពេល ៥នាទី)

☞ គ្រូសួរទៅសិក្ខាកាមដើម្បីទទួលបាននូវពតិមានត្រឡប់។

☞ គ្រូជំនួយកត់ត្រាចម្លើយចូលរួមរបស់សិក្ខាកាម

☞ គ្រូធ្វើការសំរបសំរួលចម្លើយចូលរួមរបស់សិក្ខាកាម រួចបង្ហាញរបៀបប្រើប្រាស់សៀវភៅសន្លឹកផ្ទាត់ ដែលមានក្នុងប្រអប់ខាងក្រោម។

**របៀបប្រើប្រាស់សៀវភៅសន្លឹកផ្ទាត់**

- អ្នកអប់រំត្រូវអង្គុយពីខាងក្រោយសៀវភៅសន្លឹកផ្ទាត់ ឬអង្គុយក្បែរសៀវភៅសន្លឹកផ្ទាត់ដែលដាក់លើតុ ឬលើកៅអី។
- ត្រូវអានពតិមាន ដែលបានសរសេរនៅផ្នែកខាងក្រោយនៃសៀវភៅសន្លឹកផ្ទាតអោយអ្នកចូលរួមស្តាប់។
- រូបភាពនិមួយៗត្រូវពន្យល់ទាំងអស់អត្ថន័យសិន មុននឹងបើកសន្លឹករូបភាពបន្ទាប់ទៀត
- រៀបរាប់មេរៀនជាជំហានៗ ឱ្យស្របទៅតាមសៀវភៅសន្លឹកផ្ទាត់
- ទុកពេលអោយអ្នកទទួលការអប់រំគិត ក្រោយពេលអ្នកបានផ្តល់មេរៀននោះ
- បន្ទាប់មកសួរអ្នកទទួលការអប់រំ ពីអ្វីខ្លះដែលពួកគេមើលឃើញ និងតើរូបភាពទាំងនោះមានន័យអ្វីខ្លះ?
- កែតំរូវរាល់អ្វី ដែលមិនទាន់យល់ច្បាស់



✍ **សង្ខេប :**

☞ គ្រូរំឮកមេរៀនឡើងវិញ ដោយត្រូវអានត្រង់ផ្នែកទី៦ មេរៀនទី២ ជំហានទី៦ ស្តីពី **សង្កេត ស្តាប់ សួរ** ដូចមានក្នុងប្រអប់ខាងក្រោម។

*សេចក្តីណែនាំនេះមានស្ទួននៅក្នុងសៀវភៅការងារសំរាប់សិក្ខាកាម*

វាមានសារៈសំខាន់ណាស់ក្នុងការស្វែងរកពតិមានត្រឡប់នៅពេលកំពុងអប់រំអតិថិជន។ វិធីសាស្ត្រដែលប្រើមាន :

**សង្កេត :**

- ពីសភាពសំដែងចេញនៅលើផ្ទៃមុខ នៃអ្នកដែលទទួលការអប់រំសុខភាព តើពួកគេមានអាថិកំបាំង ដូចជា ឈឺក្បាល-រីករាយ-ជឿជាក់-បារម្ភ ឬទេ?
- ថាតើពួកគេ បង្ហាញនូវការយល់របស់ពួកគេ ទៅបុគ្គលិកមណ្ឌលសុខភាពវិញយ៉ាងដូចម្តេច ?
- តើពួកគេជឿជាក់ ឬទេ ?
- តើពួកគេមានធ្វើអ្វីខុស ឬទេ ?

**ស្តាប់ :**

- នូវអ្វីដែលអ្នកទទួលការអប់រំ បាននិយាយ
- នូវអ្វីដែលមនុស្សដទៃៗទៀតនៅជុំវិញ បាននិយាយ

**សួរ :**

- អ្នកទទួលការអប់រំដោយប្រើ "សំណួរបើក" ដើម្បីបញ្ជាក់អំពីការយល់ដឹងរបស់ពួកគេ ឧ. ហេតុអ្វី?

☞ តាមរយៈ " **សង្កេត ស្តាប់ សួរ** " គ្រូស្នើអោយសិក្ខាកាមទាំងអស់ផ្តល់ជាឧទាហរណ៍នៃបច្ចេកទេសវាយតំលៃ លើការអនុវត្តន៏ការប្រើសំភារៈសំរាប់អប់រំសុខភាព ។

**វត្ថុបំណងទី៤ : អនុវត្តការប្រើប្រាស់បានត្រឹមត្រូវនូវរូបភាពផ្ទាំងធំ រូបភាពសន្លឹកបត់ សៀវភៅសន្លឹកផ្ទាត់**

☞ គ្រូត្រូវលើកបង្ហាញសារជាថ្មីម្តងទៀតនូវ **បញ្ជីត្រួតពិនិត្យសមត្ថភាព** ដែលនឹងត្រូវបានយកមកប្រើ ដើម្បីវាយតំលៃការប្រើប្រាស់សំភារៈសំរាប់អប់រំសុខភាព ។

**បញ្ជីត្រួតពិនិត្យសមត្ថភាព : ការជ្រើសរើស និង ការប្រើប្រាស់សំភារៈសំរាប់អប់រំសុខភាព**

១- កំណត់ថា តើសំភារៈមួយណា ឬការរួមបញ្ចូលនៃសំភារៈណាខ្លះ ដើម្បីប្រើប្រាស់អោយស៊ីសង្វាក់ជាមួយស្ថានភាព

២- លទ្ធភាពដើម្បីរៀបចំតាំងបង្ហាញសំភារៈ ឱ្យបានត្រឹមត្រូវ ( ទីកន្លែង-របៀបដាក់តាំង)

៣- វាស់វែងកំរិតនៃការយល់ដឹងរបស់អតិថិជន លើចំណុចសំខាន់ៗនៃសារសុខភាពនិមួយៗ ។

៤- លទ្ធភាព ដើម្បីពន្យល់ច្បាស់លាស់ អំពីខ្លឹមសារសំខាន់ៗនៃសំភារៈទាំងនោះ

៥- ជំរុញលើកទឹកចិត្ត អតិថិជនអោយចូលរួមក្នុងការប្រើសំភារៈទាំងនោះ

៦- វាយតំលៃការយល់ដឹងរបស់អតិថិជន

៧- ធ្វើផ្លូនៗឡើងវិញ នូវចំណុចសំខាន់ៗទាំងឡាយដែលបានរៀនសូត្រ

☞ គ្រូត្រូវរៀបចំសិក្ខាកាមជា៣ក្រុម ដើម្បីធ្វើការសំដែងតួ ក្រុមនិមួយៗមានភារកិច្ចដូចតទៅ :

- ក្រុមទី១ : អប់រំដោយប្រើរូបភាពសន្លឹកបត់
- ក្រុមទី២ : អប់រំដោយប្រើសៀវភៅសន្លឹកផ្ទាត់
- ក្រុមទី៣ : អប់រំដោយប្រើរូបភាពផ្ទាំងធំ

*សេចក្តីណែនាំនេះមានស្ទួននៅក្នុងសៀវភៅការងារសំរាប់សិក្ខាកាម*

**សកម្មភាព ៤-៤-១** **ក្រុមទី ១**

បំណងនៃសកម្មភាពនេះ គឺអោយសិក្ខាកាមធ្វើបង្ហាញការប្រើប្រាស់រូបភាពសន្លឹកបត់បានត្រឹមត្រូវ សំរាប់ការអប់រំសុខភាព ដោយផ្អែកតាមបញ្ជីត្រួតពិនិត្យសមត្ថភាព ។

**រយៈពេល** : ៣០នាទី

**ការណែនាំ** : សិក្ខាកាមក្នុងក្រុមទី១ត្រូវដើរតួសំដែង សំរាប់ធ្វើបង្ហាញការប្រើប្រាស់រូបភាពសន្លឹកបត់

- សិក្ខាកាមទី១ : អ្នកអប់រំសុខភាព
- សិក្ខាកាមទី២ : អ្នកទទួលការអប់រំ
- សិក្ខាកាមទី៣-៤-៥: អ្នកអង្កេតមើល និងប្រើប្រាស់ *បញ្ជីត្រួតពិនិត្យសមត្ថភាព* សំរាប់ផ្តល់ពតិមានត្រឡប់ ។

**សកម្មភាព ៤-៤-២** **ក្រុមទី ២**

បំណងនៃសកម្មភាពនេះ គឺសំរាប់អោយសិក្ខាកាមធ្វើបង្ហាញការប្រើប្រាស់សៀវភៅសន្លឹកផ្ទាត់បានត្រឹមត្រូវ សំរាប់ ការអប់រំសុខភាព ដោយផ្អែកតាមបញ្ជីត្រួតពិនិត្យសមត្ថភាព។

**រយៈពេល :** ៣០នាទី

**ការណែនាំ :** សិក្ខាកាមក្រុមទី២ ត្រូវដើរតួ សំរាប់ធ្វើបង្ហាញការប្រើប្រាស់សៀវភៅសន្លឹកផ្ទាត់

- សិក្ខាកាមទី១ : អ្នកអប់រំសុខភាព
- សិក្ខាកាមទី២ : អ្នកទទួលការអប់រំ
- សិក្ខាកាមទី៣-៤-៥ : អ្នកអង្កេតមើល និងប្រើប្រាស់ *បញ្ជីត្រួតពិនិត្យសមត្ថភាព* សំរាប់ផ្តល់ពតិមានត្រឡប់។

**សកម្មភាព ៤-៤-៣** **ក្រុមទី៣**

បំណងនៃសកម្មភាពនេះ គឺសំរាប់អោយសិក្ខាកាមធ្វើបង្ហាញការប្រើប្រាស់រូបភាពផ្ទាំងធំបានត្រឹមត្រូវ សំរាប់ ការអប់រំសុខភាពដោយផ្អែកតាមបញ្ជីត្រួតពិនិត្យសមត្ថភាព។

**រយៈពេល :** ៥នាទី

**ការណែនាំ :** សិក្ខាកាមក្រុមទី៣ ត្រូវដើរតួធ្វើបង្ហាញការប្រើប្រាស់រូបភាពផ្ទាំងធំ

- សិក្ខាកាមទី១ : អ្នកអប់រំសុខភាព
- សិក្ខាកាមទី២ : អ្នកទទួលការអប់រំ
- សិក្ខាកាមទី៣-៤-៥ : អ្នកអង្កេតមើល និងប្រើប្រាស់ *បញ្ជីត្រួតពិនិត្យសមត្ថភាព* សំរាប់ផ្តល់ពតិមានត្រឡប់។

☞ ក្រោយពីក្រុមទាំង៣ ធ្វើការសំដែងតួចប់ គ្រូដឹកនាំការពិភាក្សាដោយរកអោយឃើញនូវចំណុចល្អ ចំណុចខ្វះខាត និង ចំណុចគួរកែលំអរ តាមរយៈ ការសង្កេតរបស់សិក្ខាកាម។

# ផ្នែកទី៣ : ដំណើរការនៃការលើកកំពស់សុខភាព

**១- ទិដ្ឋភាពរួម :** ចំណុចយកចិត្តទុកដាក់នៃផ្នែកនេះ គឺនៅលើការធ្វើផែនការដើម្បីគូសបញ្ជាក់ថា ការលើកកំពស់សុខភាព គឺជាការប្រឹងប្រែងរួមសហការគ្នា។

**២- រយៈពេល :** ៣០នាទី

**៣- វត្ថុបំណងនៃការសិក្សា :** នៅចុងបញ្ចប់នៃមេរៀន សិក្ខាកាមទាំងអស់នឹងអាចៈ

- ពិពណ៌នាអំពីវដ្ដ និងបែបបទនៃការធ្វើផែនការ
- ពិភាក្សា និងអនុវត្តបែបបទនៃការធ្វើផែនការ

## តើផ្នែកនេះជាប់ទាក់ទងយ៉ាងដូចម្ដេចទៅនឹងការងារបុគ្គលិកមណ្ឌលសុខភាព?

ផ្នែកនេះនឹងរៀបចំបុគ្គលិកមណ្ឌលសុខភាពអោយធ្វើការដោយសហការជាមួយ ស្រុកប្រតិបត្តិ បុគ្គលិកសុខាភិបាលថ្នាក់ខេត្ត ថ្នាក់ជាតិ អង្គការដៃគូ ផ្នែកពាក់ព័ន្ធ និងសហគមន៍ ដែលនៅនឹងកន្លែងរបស់ពួកគេ ដើម្បីផ្ដល់នូវការលើកកំពស់សុខភាព។

**៤- សំភារៈ និង ការរៀបចំជាមុន**

**អ្នកនឹងត្រូវការ :** ក្រដាសថ្លា សៀវភៅសន្លឹកផ្ទាត់ ក្រដាសផ្ទាំងធំ

**ការរៀបចំមេរៀនជាមុន**

**គ្រូ :** អានមេរៀននេះ ជាពិសេសជំហាននិមួយៗនៃការធ្វើផែនការ

**គ្រូជំនួយ :** សរសេរចម្លងជំហានទាំង៦នៃបែបបទធ្វើផែនការនៅលើក្រដាសផ្ទាំងធំ។ ផ្ទាំងក្រដាសនេះនឹងយកមកប្រើសំរាប់អោយគ្រូសំរបសំរួលពន្យល់ នៅពេលកំពុងបង្រៀន។

**ជំហានទាំង៦ : បែបបទនៃការធ្វើផែនការ**

១- ពិនិត្យលទ្ធផលប្រចាំឆ្នាំ

២- កំណត់គោលដៅ

៣- អភិវឌ្ឍសកម្មភាព

៤- គណនាថ្លៃចំណាយនៃផែនការសកម្មភាព និងរៀបចំថវិកា

៥- កែតំរូវផែនការប្រតិបត្តិ

៦- ត្រួតពិនិត្យ និងវាយតំលៃ

## ៥- សកម្មភាព

### វត្ថុបំណងទី១: ពិពណ៌នាអំពី វដ្ត និង បែបបទនៃការធ្វើផែនការ

☞ គ្រូត្រូវបង្ហាញវដ្តនៃការធ្វើផែនការ ដែលប្រើប្រាស់ជំហានទាំង៦នៃបែបបទធ្វើផែនការ ។

*សេចក្ដីណែនាំនេះមានស្ទួននៅក្នុងសៀវភៅការងារសំរាប់សិក្ខាកាម*

## វដ្តនៃការធ្វើផែនការ

**ជំហានទី១:** តើយើងកំពុងស្ថិតនៅទីណា?
= **ពិនិត្យលទ្ធផលប្រចាំឆ្នាំឡើងវិញ**
( កុម្ភៈ-មិនា )

**ជំហានទី២:** តើយើងចង់ទៅទីណា?
= **កំណត់គោលដៅ**
(កុម្ភៈ-មិនា)

**ជំហានទី៣:** តើយើងទៅទីនោះយ៉ាងដូចម្ដេច?
= **ការអភិវឌ្ឍន៍សកម្មភាព**
(មិនា-ឧសភា)

**ជំហានទី៤:** តើយើងត្រូវការថវិកាប៉ុន្មាន?
= **គណនាតំលៃចំណាយនៃផែនការសកម្មភាព និងរៀបចំថវិកា**
(មេសា-ឧសភា)

**ជំហានទី៥:** កែតំរូវអ្វីខ្លះដល់ផែនការ?
= **កែតំរូវផែនការប្រតិបត្តិប្រចាំឆ្នាំ និងថវិកា** (ធ្នូ)

**ជំហានទី៦:** ធ្វើដូចម្ដេចដើម្បីដឹងថាទៅដល់ទីនោះ?
= **ត្រួតពិនិត្យ និងវាយតំលៃ**
(នៅពេលអនុវត្ត និងក្រោយអនុវត្ត)

☞ គ្រូត្រូវលើកបង្ហាញអំពី **បែបបទនៃការធ្វើផែនការ** ដែលបានសរសេរចម្លងដាក់លើក្រដាសផ្ទាំងធំ ឬក្រដាសថ្លា។

☞ គ្រូត្រូវពន្យល់ថា បបបទនៃការធ្វើផែនការនេះ មានសារៈសំខាន់សំរាប់ដំណើរការនៃការលើកកំពស់សុខភាព ដែលនឹងត្រូវយកទៅប្រើប្រាស់នៅមណ្ឌលសុខភាព ...។

**បែបបទនៃការធ្វើផែនការ**

១- ពិនិត្យលទ្ធផលប្រចាំឆ្នាំ

២- កំណត់គោលដៅ

៣- អភិវឌ្ឍសកម្មភាព

៤- គណនាថ្លៃចំណាយនៃផែនការសកម្មភាព និងរៀបចំថវិកា

៥- កែតំរូវផែនការប្រតិបត្តិ

៦- ត្រួតពិនិត្យ និងវាយតំលៃ

☞ គ្រូគួរបង្រៀនសិក្ខាកាមជាជំហានៗ ដោយឆ្លងកាត់តាមជំហាននិមួយៗ នៃបែបបទធ្វើផែនការ

*សេចក្តីណែនាំនេះមាន ស្ថិតនៅក្នុងសៀវភៅការងារសិក្ខាកាម*

## ១. តារាងសង្ខេបបែបបទនៃការធ្វើផែនការសំរាប់ អភិវឌ្ឍផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មណ្ឌលសុខភាព

| ខែ | ១២កិច្ចការ | | អ្នកណាចូលរួម | លទ្ធផលរំពឹងទុក |
|---|---|---|---|---|
| | **ជំហានទី១ និង ទី២** | | | |
| កុម្ភៈ | ១ | **.ប្រជុំ**ពិនិត្យលទ្ធផលប្រចាំឆ្នាំនិង កំណត់គោលដៅនិងគោលដៅ ចំណុចរបស់មណ្ឌលសុខភាព | .ប្រធានម.ស និងបុគ្គលិក<br>.គណៈកម្មការគ្រប់គ្រងម.ស<br>.ដៃគូ | .សមិទ្ធផល ការជឿនលឿន និងឧបសគ្គ ត្រូវបានពិនិត្យ និងវាយតំលៃ<br>.បទពិសោធន៏ត្រូវបានដកស្រង់សំរាប់អនុវត្តបន្ត<br>.គោលដៅ-គោលដៅចំណុចរបស់ម.ស ត្រូវបានកំណត់សំរាប់ឆ្នាំបន្ត |
| កុម្ភៈ-មិនា | ២ | **.ចូលរួម**សិក្ខាសាលាពិនិត្យ លទ្ធផលប្រចាំឆ្នាំរបស់ស.ប និងកំណត់គោលដៅ-គោល ដៅចំណុចរបស់ស.ប | **.ប្រធានមណ្ឌលសុខភាព** | .គោលដៅ-គោលដៅចំណុចរបស់ម.ស ត្រូវបានដាក់បញ្ចូលក្នុងគោលដៅ និងគោលដៅចំណុចរបស់ស.ប |
| | ៣ | **.ចូលរួម**សិក្ខាសាលាដើម្បីសំរេច គោលដៅ និងគោលដៅចំណុច របស់ស.ប ដោយផ្អែកគោលដៅ និងគោលដៅចំណុចរបស់ខេត្ត | **.ប្រធានមណ្ឌលសុខភាព** | .ប្រធានម.ស ដឹងពីគោលដៅ និង គោលដៅចំណុច ស.ប<br>.ប្រធានមណ្ឌលសុខភាព ដឹងពី គោលដៅដែលត្រូវអនុវត្តដោយម.ស |
| **ជំហានទី៣ និង ទី៤** | | | | |
| មិនា-មេសា | ៤ | .ប្រជុំដើម្បីពិនិត្យឡើងវិញ កំណត់គោលដៅ-គោលដៅ ចំណុចរបស់ម.ស<br>.អភិវឌ្ឍសកម្មភាពនិងគណនាតំលៃ ចំណាយផែនការសកម្មភាពរបស់ម.ស | .ប្រធានម.ស និងបុគ្គលិក<br>.គណៈកម្មការគ្រប់គ្រងម.ស<br>.ដៃគូ | .គោលដៅ-គោលដៅចំណុចរបស់ម.ស (ដែលបានអភិវឌ្ឍជំហានទី១)ត្រូវបាន ពិនិត្យឡើងវិញនិងកែប្រែដោយផ្អែកលើ គោលដៅ និងគោលដៅរបស់ស.ប<br>.ផែនការសកម្មភាពរបស់ម.ស ត្រូវ បានអភិវឌ្ឍដោយមានសកម្មភាពលំអិត សំរាប់គោលដៅនិមួយៗ<br>.ផែនការសកម្មភាពត្រូវបានគណនាតំលៃ ចំណាយ សំរាប់រៀបចំថវិកាតាមខ្ទង់ចំណាយ |

| | | | | |
|---|---|---|---|---|
| មិនា-<br>មេសា | ៥ | .រៀបចំថវិកាតាមខ្ទង់ចំណាយ | .ប្រធានម.សនិងអ្នកបន្ទុក<br>.ថវិកាហិរញ្ញវត្ថុ និងដៃគូ | .ផែនការប្រតិបត្តប្រចាំឆ្នាំរបស់ម.ស ដែលមានផែនការសកម្មភាពលំអិត និងថវិកាត្រូវបានធ្វើរួច ។ **ផែនការប្រតិបត្តិប្រចាំឆ្នាំរបស់ម.ស ដាក់ជូន ស.ប ដើម្បីត្រួតពិនិត្យ** |
| ឧសភា | ៦ | .ប្រជុំដើម្បីពិនិត្យឡើងវិញផែនការប្រតិបត្តិប្រចាំឆ្នាំរបស់ម.ស បន្ទាប់ពីបានទទួលពត៌មានត្រឡប់ពីស.ប | .ប្រធានម.ស និងបុគ្គលិក<br>.គណៈកម្មការគ្រប់គ្រងម.ស<br>.ដៃគូ | .ផែនការប្រតិបត្តិប្រចាំឆ្នាំរបស់ម.សត្រូវបានកែប្រែហើយដាក់ជូនស.ប វិញ |
| ឧសភា | ៧ | **.ចូលរួម**ប្រជុំឡើងវិញផែនការប្រតិបត្តិ<br>ប្រចាំឆ្នាំរបស់ស.ប ដោយផ្អែកលើពត៌មានត្រឡប់ពីមន្ទីរសុខាភិបាល | **.ប្រធានមណ្ឌលសុខភាព** | .ប្រធានម.ស ចូលរួមពិនិត្យឡើងវិញផែនការប្រតិបត្តិប្រចាំឆ្នាំរបស់ស.ប<br>.ប្រធានម.ស បានដឹងអំពីការកែប្រែក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់ស.ប និងផលប៉ះហាល់ដល់ផែនការប្រតិបត្តិប្រចាំឆ្នាំរបស់ម.ស |
| **ជំហានទី៥** | | | | |
| ធ្នូ | ៨ | .ចូលរួមប្រជុំដើម្បីបញ្ចប់ផែនការប្រតិបត្តិប្រចាំឆ្នាំរបស់ស.ប | **.ប្រធានមណ្ឌលសុខភាព** | .ប្រធានមណ្ឌលសុខភាពបានដឹងអំពីការកែប្រែក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់ស.ប និងផលប៉ះពាល់ដល់ផែនការប្រតិបត្តិប្រចាំឆ្នាំរបស់ម.ស |
| | ៩ | .ប្រជុំដើម្បីបញ្ចប់ផែនការប្រតិបត្តិប្រចាំឆ្នាំរបស់ម.ស និងថវិកា | **.ប្រធានមណ្ឌលសុខភាព**<br>.ប្រធានផ្នែក-សេវា<br>.ដៃគូ | .ផែនការប្រតិបត្តិប្រចាំឆ្នាំរបស់ម.ស ត្រូវបានបញ្ចប់ដោយផ្អែកលើកញ្ចប់ថវិកា-ពត៌មានអំពីការអនុវត្តន៏ ផែនការប្រតិបត្តិប្រចាំឆ្នាំរបស់ម.ស ពត៌មានអំពីមូនិធិពីក្រៅ និងការកែប្រែក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់ស.ប<br>.ផែនការត្រីមាសទី១និងថវិកាត្រូវបានអភិវឌ្ឍ |

| **ជំហានទី៦** | | | | |
|---|---|---|---|---|
| រាល់ខែ ឆ្នាំ បន្ទាប់ | ១០ | .ប្រជុំប្រចាំខែ | .ប្រធានម.ស និងបុគ្គលិក | .ការជឿនលឿនក្នុងការអនុវត្តន៏ផែនការប្រចាំត្រីមាសរបស់ម.សត្រូវបានពិនិត្យ និងវាយតំលៃ |
| រាល់ត្រីមាស ឆ្នាំ បន្ទាប់ | ១១ | .ប្រជុំពិនិត្យលទ្ធផលម.សប្រចាំត្រីមាស | .ប្រធានម.ស និងបុគ្គលិក<br>.គណ:កម្មការគ្រប់គ្រងម.ស<br>.ដៃគូ និងប្រធានក.ទ.ទ.ភ | .ការជឿនលឿនក្នុងការសំរេចគោលដៅរបស់ម.សត្រូវបានពិនិត្យ និងវាយតំលៃ<br>.ដកស្រង់បទពិសោធន៏សំរាប់អនុវត្តបន្ត |
| រាល់ត្រីមាស | ១២ | **.ចូលរួម**ប្រជុំពិនិត្យលទ្ធផលប្រចាំត្រីមាសរបស់ស.ប | .ប្រធានម.ស | .ការជឿនលឿនក្នុងការសំរេចគោលដៅរបស់ស.បត្រូវបានពិនិត្យ និងវាយតំលៃ |
| ឆ្នាំបន្ទាប់ កុម្ភ: | ? | .ការវាយតំលៃ=សិក្ខាសាលាពិនិត្យ | .ដូចកិច្ចការទី២ | .ចាប់ផ្តើមវដ្តធ្វើផែនការបន្ត ជំហានទី១ |
| ឆ្នាំបន្ទាប់ | ? | លទ្ធផលប្រចាំឆ្នាំរបស់ម.ស និង<br>.កំណត់គោលដៅចំណុចសំរាប់ម.ស | | ឬ **ការពិនិត្យលទ្ធផលប្រចាំឆ្នាំរបស់ម.ស** |

# វត្ថុបំណងទី ២ : ពិភាក្សា និង អនុវត្តបែបបទនៃការធ្វើផែនការ

**១- រយៈពេល** : ២ម៉ោង និង៣៥នាទី

**តើផ្នែកនេះជាប់ទាក់ទងយ៉ាងដូចម្តេច ទៅនឹងការងារនៃបុគ្គលិកមណ្ឌលសុខភាព?**

បុគ្គលិកមណ្ឌលសុខភាព ប្រើប្រាស់បែបបទនៃការធ្វើផែនការដោយមានការណែនាំ

**២- សំភារៈ និងការរៀបចំជាមុន**

**អ្នកនឹងត្រូវការ** : ក្រដាសថ្លា សៀវភៅសន្លឹកផ្ទាត់ ឬអត្ថបទលើក្រដាសផ្ទាំងធំ

**ការរៀបចំមេរៀនជាមុន :**

**គ្រូ** : រំលឹកមេរៀនឡើងវិញត្រង់ **បែបបទនៃការធ្វើផែនការ**

**គ្រូជំនួយ** : ត្រូវ :

- ចម្លងជំហានទាំង៦នៃបែបបទធ្វើផែនការ ដាក់លើក្រដាសផ្ទាំងធំ ។ ក្រដាសផ្ទាំងធំនេះ នឹងត្រូវយកមកប្រើសំរាប់គ្រូសំរបសំរួលបំពេញ និងពន្យល់នៅពេលកំពុងបង្រៀន ។
- ចម្លងលទ្ធផលប្រចាំឆ្នាំ២០០៤ របស់មណ្ឌលសុខភាព **ក** ដែលមាននៅក្នុងតារាងជាឧទាហរណ៍ខាងក្រោម

**៣- សកម្មភាព**

## ជំហានទី១ : ការពិនិត្យលទ្ធផលប្រចាំឆ្នាំ

☞ ឥឡូវនេះគ្រូត្រូវធ្វើបង្ហាញនូវការប្រើប្រាស់ជំហានទាំង៦នៃបែបបទធ្វើផែនការ ដើម្បីរៀបចំធ្វើកម្មវិធីលើកកំពស់សុខភាព ជាគំរូមួយ ។

ឧទាហរណ៍ : មណ្ឌលសុខភាព **ក** អនុវត្តបានសំរេច គោលដៅ និង គោលដៅចំណុចនៃនៃការសកម្មភាពប្រចាំឆ្នាំ ដូចមានក្នុងតារាងខាងក្រោម ។

*សេចក្តីណែនាំនេះ មានស្ទួននៅក្នុងសៀវភៅការងារសំរាប់សិក្ខាកាម*

| ការពិនិត្យលទ្ធផលប្រចាំឆ្នាំ:ការសំរេចគោលដៅ និងគោលដៅចំណុច | | | | | | | |
|---|---|---|---|---|---|---|---|
| ឈ្មោះមណ្ឌលសុខភាព: **ក** | | | | | | ឆ្នាំ ២០០៤ | |
| ផ្នែកការងារសំខាន់ៗ: ការផ្តល់ថ្នាំបង្ការ | | | | | | | |
| គោលដៅ | អាំងឌីកាទ័រ | លទ្ធផល | | | គោលដៅ | ថវិកា | |
| | | ឆ្នាំកន្លងទៅ | | | ចំណុចឆ្នាំ | ថវិកា | ចំណាយ |
| | | ២០០២ | ២០០៣ | ២០០៤ | ២០០៤ | ឆ្នាំ២០០៤ | ឆ្នាំ២០០៤ |
| បង្កើនអត្រាគ្របដណ្តប់ការផ្តល់វ៉ាក់សាំង លើកុមារអាយុក្រោម១ឆ្នាំ តាមរយៈ ការចុះមូលដ្ឋាន | %កុមារអាយុក្រោម១ឆ្នាំទទួលវ៉ាក់សាំងគ្រប់ | ៥៥% | ៥៩% | ៦០% | ៧៥% | ២០ ០០០ ០០០ រៀល | ១៥ ០០០ ០០០ រៀល |
| | អត្រាបោះបង់វ៉ាក់សាំង | ២០% | ១៨% | ១៧% | < ១០% | | |
| | ចំនួនចុះមូលដ្ឋានតាមភូមិ | ៧ | ៨ | ៩ | > ១០ | | |

☞ គ្រូត្រូវរៀបចំសិក្ខាកាមសំរាប់ពិភាក្សាក្រុមតូច ។

*សេចក្តីណែនាំនេះមានស្ទួននៅក្នុងសៀវភៅការងារសំរាប់សិក្ខាកាម*

**សកម្មភាព ៣-១-១** **ពិភាក្សាក្រុមតូច**

បំណងនៃសកម្មភាពនេះគឺណែនាំសិក្ខាកាមឱ្យចូលរួមនៅក្នុងការរៀបចំពិនិត្យលទ្ធផលប្រចាំឆ្នាំដោយប្រើបទពិសោធន៏របស់ពួកគេ ជាគោលនៃការពិភាក្សា ។

**រយៈពេល** : ២៥នាទី

**ការណែនាំ** : គ្រូអោយសិក្ខាកាម **វិភាគស្ថានភាព** លើឧទាហរណ៏មណ្ឌលសុខភាព **ក** ខាងលើ ដោយឱ្យក្រុមនិមួយៗកំណត់ថា តើអ្វីខ្លះដែលបានអនុវត្តល្អ? ហេតុអ្វី? (ចំណុចខ្លាំង) តើអ្វីខ្លះដែលមិនបានអនុវត្តល្អ? ហេតុអ្វី? (ចំណុចខ្សោយ) យុទ្ធសាស្ត្រពង្រឹងជោគជ័យ និងរៀនសូត្រពីចំណុចខ្សោយ(សកម្មភាពអនុវត្តបន្ត) ។

**បង្ហាញលទ្ធផល និង ពិភាក្សា** (រយៈពេល: ៥នាទីក្នុង១ក្រុម)

- តំណាងក្រុមនិមួយៗឡើងមកបង្ហាញលទ្ធផល
- ទុកពេលអោយសិក្ខាកាមសួរ ឬផ្តល់យោបល់ និងបកស្រាយ
- គ្រូធ្វើការសំរបសំរួលចម្លើយសិក្ខាកាម និងបង្ហាញចម្លើយចូលរួម

**ចម្លើយចូលរួម :** គ្រូត្រូវអាន ចម្លើយចូលរួមដូចខាងក្រោមនេះ

| ការពិនិត្យប្រចាំឆ្នាំ : **ការវិភាគស្ថានភាព** | | |
|---|---|---|
| ឈ្មោះមណ្ឌលសុខភា : **ក** | | ឆ្នាំ២០០៤ |
| តើបានដកស្រង់បទពិសោធន៏អ្វីខ្លះ? | | យុទ្ធសាស្ត្រពង្រឹងជោគជ័យ និងរៀនសូត្រពីចំណុចខ្សោយ (សកម្មភាពអនុវត្តបន្ត) |
| តើអ្វីខ្លះដែលបានអនុវត្តល្អ? ហេតុអ្វី? (ចំណុចខ្លាំង) | តើអ្វីខ្លះដែលមិនបានអនុវត្តល្អ? ហេតុអ្វី? (ចំណុចខ្សោយ) | |
| %កុមារ<១ឆ្នាំបានទទួលវ៉ាក់សាំងសព្វ គ្រប់បានកើនឡើងជាលំដាប់ក្នុងរយៈពេលបីឆ្នាំកន្លងមក ណែកអត្រាបោះបង់ក៏បានចុះថយជាលំដាប់ ។ ការចំរើននេះបាទទួលដោយសារ<br>- ការចូលរួមរបស់សហគមន៍ដែលធ្វើឱ្យភូមិបានដឹងអំពីកម្មវិធី ចុះមូលដ្ឋាន<br>- បុគ្គលិកម.សមានជំនាញកាន់តែខ្ពស់ (អាប់សៃ មានចំនួនតិច)<br>- ធ្វើការអប់រំសុខភាពបានល្អប្រសើរដែលនាំឱ្យមាតា បិតាយល់ដឹងថាកុមារត្រូវទទួលវ៉ាក់សាំងគ្រប់ | %នៃកុមារទទួលវ៉ាក់សាំងសព្វគ្រប់ស្ថិតនៅក្រោមគោលដៅចំណុចប្រចាំឆ្នាំជាខ្លាំង<br>.អត្រាបោះបង់ស្ថិតនៅខ្ពស់<br>.ចំនួនចុះមូលដ្ឋានតាមភូមិតិចជាងចំនួនកំណត់ក្នុងផែនការ ។<br>.មានមូលហេតុសំខាន់ៗដូចខាងក្រោម:<br>-កង្វះថវិកានៅត្រីមាសទី១ដែលជារដូវក្តៅ<br>-អត្រាមធ្យមទាបនៅភូមិឆ្ងាយជាងគេពីមណ្ឌលសុខភាពធ្វើឱ្យអត្រាមធ្យម ទូទៅមានកំរិតទាប ។ មាន២៥%នៃ ភូមិស្ថិតនៅឆ្ងាយ ពីមណ្ឌលសុខភាព ហើយបុគ្គលិកចុះទៅភូមិទាំងនោះមិនទៀងទាត់<br>- អត្រាបោះបង់ខ្ពស់ដោយសារកង្វះពត៌មានអំពីកម្មវិធីវិធីចុះមូលដ្ឋាន កង្វះការយល់ដឹង អំពីតំរូវការផ្តល់វ៉ាក់សាំងឱ្យកុមារ(កង្វះការអប់រំសុខភាព)និងអាប់សៃដោយសារកង្វះជំនាញឬការអនុវត្តន៍មិនត្រឹមត្រូវ ។ | .សហគមន៍ចូលរួមតាមរយៈក្រុមទ្រ-ទ្រង់សុខភាពភូមិជាកត្តាសំខាន់ក្នុងការបង្កើនអត្រាគ្របដណ្តប់វ៉ាក់សាំងដល់កុមារ ។ តាមរយៈក្រុមទ្រទ្រង់សុខភាពភូមិ អ្នកភូមិបានដឹងអំពីកម្មវិធីចុះមូល ដ្ឋាននិងយល់ដឹងអំពីតំរូវការទទួលវ៉ាក់សាំងរបស់កុមារ<br>.ចាំបាច់ត្រូវមានគំនិតផ្តួចផ្តើមដើម្បីដោះស្រាយកង្វះមូលនិធិនៅត្រីមាសទី១ ។ NGOs ដែល ធ្វើការនៅ OD អាចជួយផ្តល់មូលនិធិ ឬខ្ចីមូលនិធិនៅត្រីមាសទី១ ។<br>.អត្រាគ្របដណ្តប់វ៉ាក់សាំងទាបនៅភូមិឆ្ងាយជាបញ្ហាសំខាន់ ត្រូវបង្កើនការចុះមូលដ្ឋាននៅភូមិទាំងនោះ ។<br>.ជំនាញបច្ចេកទេស និងការរំងាប់មេរោគនៅតែជាបញ្ហា ស្រុកប្រតិបត្តិ ត្រូវពិចារណាអំពីតំរូវការប.ប បន្ថែមជា១មន្ទីរសុខាភិបាល និង កម្មវិធី NIP |

## ជំហានទី២ : ការកំណត់គោលដៅ

☞ **ពិភាក្សាក្រុមតូច :** ផ្អែកតាមការវិភាគស្ថានភាពខាងលើនេះ គ្រូត្រូវរៀបចំសិក្ខាកាមពិភាក្សាក្រុមតូច ដោយតំរូវឱ្យសិក្ខាកាមកំណត់នូវ **គោលដៅ** និង**គោលដៅចំណុច** ដែលនឹងត្រូវយកមកបំពេញក្នុងតារាងខាងក្រោម ។

☺ គ្រូជំនួយត្រូវសរសេរចម្លងនូវតារាងសំរាប់បំពេញកិច្ចការ ដែលនៅក្នុងជំហានទី២នេះ ដាក់លើផ្ទាំងក្រដាសផ្ទាំងធំ១ សំរាប់ឱ្យ**សិក្ខាកាមសរសេរបំពេញនូវកិច្ចការរបស់ពួកគេ ។**

*សេចក្តីណែនាំនេះមានស្ទួននៅក្នុងសៀវភៅការងារសំរាប់សិក្ខាកាម*

| | | | |
|---|---|---|---|
| **កម្មវិធីផ្តល់ថ្នាំបង្ការ**<br>• ឧទាហរណ៍ : បង្កើនអត្រាគ្របដណ្តប់ការផ្តល់វ៉ាក់សាំងលើកុមារអាយុក្រោម១ឆ្នាំ ឱ្យបានពី៦០%ទៅ៧០% នៅដំណាច់ឆ្នាំ ២០០៥ ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសនៅតំបន់ដាច់ស្រយ៉ាល ។ | | | |
| **ផែនការសកម្មភាព: គោលដៅ និង គោលដៅចំណុច** | | | |
| **ឈ្មោះមណ្ឌលសុខភាព: ក** | | | **ឆ្នាំ:២០០៥** |
| **ផ្នែកការងារសំខាន់: កម្មវិធីផ្តល់ថ្នាំបង្ការ** | | | |
| **គោលដៅ** | **អាំងឌីកាទ័រ** | **គោលដៅចំណុចឆ្នាំ២០០៥** | **ថវិកាឆ្នាំ២០០៥** |
| | | | |
| | | | |
| | | | |
| | | | |
| | | | |

## ជំហានទី៣: អភិវឌ្ឍសកម្មភាព

☞ គ្រូត្រូវរៀបចំសិក្ខាកាមសំរាប់ពិភាក្សាក្រុមតូច ចំនួន៣ក្រុម ។

*សេចក្តីណែនាំនេះមានស្ទួននៅក្នុងសៀវភៅការងារសំរាប់សិក្ខាកាម*

**សកម្មភាព ៧-៧-១** **ពិភាក្សាក្រុមតូច**

បំណងនៃសកម្មភាពនេះគឺណែនាំសិក្ខាកាមទាំងអស់ឱ្យចូលរួមនៅក្នុងការរៀបចំអភិវឌ្ឍន៍ផែនការសកម្មភាពមួយ ដោយប្រើប្រាស់នូវបទពិសោធន៍រួមរបស់ពួកគេ។

**រយៈពេល** : ៤៥នាទី

**ការណែនាំ** : តាមរយៈ បែបបទធ្វើផែនការ ដែលបានរៀនសូត្ររួច ក្រុមនិមួយៗត្រូវរៀបចំធ្វើការអភិវឌ្ឍន៍ផែនការសកម្មភាព ដោយធ្វើយ៉ាងណាឱ្យសកម្មភាពនិមួយៗទាំងនោះ ត្រូវឆ្លើយតបទៅនឹងសំណួរ :

- បុគ្គលណាខ្លះចូលរួមទទួលខុសត្រូវ?
- ត្រីមាសណាដែលត្រូវអនុវត្ត?
- ធនធានអ្វីខ្លះដែលត្រូវការ? មានប្រភពមកពីណា?
- លទ្ធផលរំពឹងទុកដែលត្រូវទទួលបានយ៉ាងដូចម្តេច?
- ពិនិត្យតាមដានយ៉ាងដូចម្តេច?

☺ គ្រូជំនួយត្រូវចម្លងទុកជាស្រេចនូវតារាង១ដូចខាងក្រោមនេះដាក់លើក្រដាសផ្ទាំង និងត្រៀមសរសេរបញ្ចូលចម្លើយសិក្ខាកាមទាំង៣ក្រុមដាក់ក្នុងតារាងនោះ ដោយផ្អែកលើចម្លើយចូលរួមរបស់សិក្ខាកាម និង ឱ្យសិក្ខាកាមទាំងអស់សរសេរនៅក្នុងសៀវភៅការងាររបស់ពួកគេដែរ។

| **ផែនការសកម្មភាព** | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ឈ្មោះមណ្ឌលសុខភាព: **ក** | | | | | | | | | ឆ្នាំ: ២០០៥ | |
| ផ្នែកការងារសំខាន់ៗ: **កម្មវិធីផ្តល់ថ្នាំបង្ការ** | | | | | | | | | | |
| គោលដៅ: ................................................... | | | | | | | | | | |
| **សកម្មភាព** | **អ្នកទទួលខុសត្រូវ** | **ពេលណា** | | | | **ធនធាន** | | | **លទ្ធផល** | **មធ្យោបាយ** |
| | | | | | | រដ្ឋាភិបាល | NGOs / IOs | បង់ថ្លៃសេវា | **រំពឹងទុក** | **ផ្ទៀងផ្ទាត់** |
| | | | | | | | | | | |

**បង្ហាញលទ្ធផល និង ពិភាក្សា** (រយៈពេល: ៥នាទីក្នុង១ក្រុម)

- តំណាងក្រុមនិមួយៗឡើងមកបង្ហាញលទ្ធផល
- ទុកពេលអោយសិក្ខាកាមសួរ ឬផ្តល់យោបល់ និងបកស្រាយ
- គ្រូធ្វើការសំរបសំរួលចម្លើយសិក្ខាកាម

## ជំហានទី៤: គណនាតំលៃចំណាយនៃផែនការសកម្មភាព និង រៀបចំថវិកា

*សេចក្តីណែនាំនេះមានសួននៅក្នុងសៀវភៅការងារសំរាប់សិក្ខាកាម*

**សកម្មភាព ៣-៤-១** **ពិភាក្សាក្រុមតូច**

បំណងនៃសកម្មភាពនេះ គឺបន្តណែនាំសិក្ខាកាមទាំង៣ក្រុមដដែលខាងលើ អោយចូលរួមនៅក្នុងការគណនាតំលៃចំណាយនៃផែនការសកម្មភាព និងរៀបចំថវិកា ដោយប្រើបទពិសោធន៏រួមគ្នារបស់ពួកគេ។

**រយៈពេល :** ១៥នាទី

**ការណែនាំ :** ក្រុមនិមួយៗត្រូវគណនាតំលៃចំណាយនៃផែនការសកម្មភាព និងរៀបចំថវិកា ដោយត្រូវធ្វើយ៉ាងណាឱ្យឆ្លើយតបទៅនឹងសំណួរ : តើត្រូវការថវិកាប៉ុន្មាន សំរាប់សកម្មភាពទាំងនោះ?

**បង្ហាញលទ្ធផល និង ពិភាក្សា** (រយៈពេល: ៥នាទីក្នុង១ក្រុម)

- តំណាងក្រុមនិមួយៗឡើងមកបង្ហាញលទ្ធផល
- ទុកពេលអោយសិក្ខាកាមសួរ ឬផ្តល់យោបល់ និងបកស្រាយ
- គ្រូធ្វើការសំរបសំរួលចម្លើយសិក្ខាកាម និងបង្ហាញចម្លើយចូលរួម

☝ **ចម្លើយចូលរួម:** គ្រូត្រូវអាន ចម្លើយចូលរួមដូចខាងក្រោមនេះ

☺ គ្រូជំនួយត្រូវសរសេរបំពេញចម្លើយសិក្ខាកាមនៅលើក្រដាស់ផ្ទាំងធំ ដោយផ្អែកលើចំលើយរបស់សិក្ខាកាមទាំង៣ក្រុម និង អោយសិក្ខាកាមទាំងអស់សរសេរនៅក្នុងសៀវភៅការងាររបស់ពួកគេដែរ។ ( **គំរូតារាងខាងលើ** )

## ជំហានទី៥ : កែតំរូវផែនការប្រតិបត្តិ

☞ គ្រូត្រូវរៀបចំសិក្ខាកាមជា៣ក្រុម ដើម្បីពិភាក្សាក្រុមតូច ។

*សេចក្តីណែនាំនេះមានសួននៅក្នុងសៀវភៅការងារសំរាប់សិក្ខាកាម*

**សកម្មភាព ៣-៥-១ ពិភាក្សាក្រុមតូច**

បំណងនៃសកម្មភាពនេះគឺ ណែនាំសិក្ខាកាមឱ្យចូលរួមបន្តនៅក្នុង ការកែតំរូវផែនការប្រតិបត្តិប្រចាំឆ្នាំ ដោយផ្អែកលើលទ្ធផលនៃការប្រជុំនៅស្រុកប្រតិបត្តិរបស់ពួកគេជាគោល។ ដើម្បីបញ្ចប់ផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មណ្ឌលសុខភាព និងអភិវឌ្ឍផែនការប្រចាំត្រីមាសទី១នៅឆ្នាំបន្ទាប់ទៀត ប្រធានឬបុគ្គលិកមណ្ឌលសុខភាព តែងទទួលពិតមានថ្មីៗ នៅចុងឆ្នាំ អំពី :

- កញ្ចប់ថវិកា របស់មណ្ឌលសុខភាព
- ជំនួយមូលនិធិ ពីខាងក្រៅ
- ការអនុវត្តន៏ផែនការប្រចាំឆ្នាំរបស់មណ្ឌលសុខភាព
- ការកែប្រែផែនការប្រតិបត្តិប្រចាំឆ្នាំរបស់ស្រុកប្រតិបត្តិ ។ល។

**រយៈពេល :** ២៥នាទី

**ការណែនាំ :** ផ្អែកលើផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មណ្ឌលសុខភាពដែលបានពិភាក្សារួច សូមសិក្ខាកាមទាំង៣ក្រុម **រៀបចំផែនការសំរាប់ត្រីមាសទី១ នៅឆ្នាំបន្ទាប់ទៀត** នៅក្នុងតារាងដូចខាងក្រោម ។

| ផែនការប្រចាំត្រីមាស | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ឈ្មោះមណ្ឌលសុខភាពៈ | | | | | | | ឆ្នាំៈ | | ត្រីមាសៈ |
| ផ្នែកសំខាន់១ៈ | | | | | | | | | |
| គោលដៅៈ | | | | | | | | | |
| សកម្មភាព | អ្នកទទួលខុសត្រូវ | ពេលណា | | | ធនធាន | | | លទ្ធផលរំពឹងទុក | មធ្យោបាយផ្ទៀងផ្ទាត់ |
| | | ខែ ១ | ខែ ២ | ខែ ៣ | រដ្ឋាភិបាល | អ/ងអន្តរ អ/ងក្រៅ | បង់ថ្លៃសេវា | | |
| | | | | | | | | | |
| | | | | | | | | | |

☺ គ្រូជំនួយត្រូវសរសេរបំពេញចម្លើយសិក្ខាកាមនៅលើក្រដាស់ផ្ទាំងធំ ដោយផ្អែកលើចំលើយរបស់សិក្ខាកាមទាំង៣ក្រុម និង អោយសិក្ខាកាមទាំងអស់សរសេរនៅក្នុងសៀវភៅការងាររបស់ពួកគេដែរ។ ( **គំរូតារាងខាងលើ** )

**បង្ហាញលទ្ធផល និង ពិភាក្សា** (រយៈពេលៈ ៥នាទីក្នុង១ក្រុម)

- តំណាងក្រុមនិមួយៗឡើងមកបង្ហាញលទ្ធផល
- ទុកពេលអោយសិក្ខាកាមសួរ ឬផ្ដល់យោបល់ និងបកស្រាយ
- គ្រូធ្វើការសំរបសំរួលចម្លើយសិក្ខាកាម

## ជំហានទី៦ៈ ត្រួតពិនិត្យ និង វាយតំលៃ

☞ គ្រូដឹកនាំពន្យល់ជំហានទី៦ អំពី **ការត្រួតពិនិត្យ និង វាយតំលៃ** ដោយសួរសំណួរមួយចំនួន ដើម្បីឆ្លុះបញ្ចាំងទៅតារាងទាំង២ ស្ដីពី ការត្រួតពិនិត្យប្រចាំត្រីមាស ដូចខាងក្រោមៈ

១- តើយើងដឹងថា ទៅដល់ទីនោះយ៉ាងដូចម្ដេច?

២- តើមណ្ឌលសុខភាពបានអនុវត្តសកម្មភាព ដូចបានចែងក្នុងផែនការប្រចាំត្រីមាស ឬទេ?

៣- តើសកម្មភាពដែលបានអនុវត្តនោះ បានផ្ដល់លទ្ធផលដូចការរំពឹងទុកឬទេ?

៤- តើមានប្រភពធនធាន និងបានប្រើប្រាស់ធនធាន ប្រកបដោយប្រសិទ្ធភាពតាមផែនការថវិកាឬទេ?

<table>
<tr><th colspan="6">ការត្រួតពិនិត្យប្រចាំត្រីមាស</th></tr>
<tr><td colspan="3">ឈ្មោះមណ្ឌលសុខភាព: ..............................</td><td colspan="2">ឆ្នាំ: ........</td><td>ត្រីមាស: .........</td></tr>
<tr><td colspan="6">ផ្នែកសំខាន់ៗ: ........................................</td></tr>
<tr><td rowspan="2">គោលដៅ</td><td rowspan="2">អាំងឌីកាទ័រ</td><td colspan="2">គោលដៅចំណុច</td><td colspan="2">ថវិកា</td></tr>
<tr><td>លទ្ធផលរយៈពេលខែ</td><td>គោលដៅចំណុចប្រចាំឆ្នាំ</td><td>ចំណាយរយៈពេលខែ</td><td>ថវិកាប្រចាំឆ្នាំ</td></tr>
<tr><td></td><td></td><td></td><td></td><td></td><td></td></tr>
<tr><td></td><td></td><td></td><td></td><td></td><td></td></tr>
<tr><td></td><td></td><td></td><td></td><td></td><td></td></tr>
</table>

<table>
<tr><th colspan="4">ការត្រួតពិនិត្យប្រចាំត្រីមាស: ត្រួតពិនិត្យសកម្មភាព និង លទ្ធផលរំពឹងទុក</th></tr>
<tr><td colspan="2">ឈ្មោះមណ្ឌលសុខភាព: ..........................</td><td>ឆ្នាំ: ...............</td><td>ត្រីមាស: .............</td></tr>
<tr><td colspan="4">ផ្នែកសំខាន់ៗ: ............................................</td></tr>
<tr><td colspan="4">គោលដៅ: ..................................................</td></tr>
<tr><td>សកម្មភាព</td><td>លទ្ធផលរំពឹងទុក</td><td>លទ្ធផលជាក់ស្តែង</td><td>សកម្មភាពបន្ត</td></tr>
<tr><td></td><td></td><td></td><td></td></tr>
<tr><td></td><td></td><td></td><td></td></tr>
<tr><td></td><td></td><td></td><td></td></tr>
</table>

☞ **គ្រូបង្ហាញឧទាហរណ៍ បញ្ជីនៃប្រធានបទ សំរាប់ធ្វើផែនការសកម្មភាពលើកកំពស់សុខភាព**

**ឧ. បញ្ជីនៃប្រធានបទសំរាប់ ធ្វើផែនការសកម្មភាពលើកកំពស់សុខភាព :**

១- ធ្វើផែនការយុទ្ធនាការថ្នាក់ជាតិ ស្តីពី ជម្ងឺគ្រុនចាញ់

២- ធ្វើផែនការយុទ្ធនាការថ្នាក់ជាតិ ស្តីពីការពន្យារកំណើត

៣- ធ្វើផែនការសកម្មភាព ប្រឆាំងនឹងការផ្ទុះឡើងវិញនៃជម្ងឺអាសន្នរោគ ។

៤- ធ្វើផែនការសកម្មភាព ប្រឆាំងនឹងការផ្ទុះឡើងនៃជម្ងឺគ្រុនឈាម ។

៥- ធ្វើផែនការសកម្មភាព បង្ការកុំអោយមូសកើតឡើងមុនរដូវភ្លៀង ។

☞ **គ្រូស្នើសិក្ខាកាមម្នាក់ៗបង្ហាញ បញ្ជីនៃប្រធានបទ សំរាប់ធ្វើផែនការសកម្មភាពលើកកំពស់សុខភាព របស់ខ្លួនទៅកាន់ក្រុមធំ ។**

# ផ្នែកទី៤ : សេចក្តីសន្និដ្ឋាន និង ការរំឭកម៉ូឌុលឡើងវិញ

**១- ទិដ្ឋភាពរួម :** ចំណុចយកចិត្តទុកដាក់នៃផ្នែកនេះ គឺ ដើម្បីរំឭកម៉ូឌុលឡើងវិញ

**២- រយះពេល :** ១ម៉ោង និង ១៥នាទី បូកបន្ថែមសកម្មភាពតាមសភាពការណ៍អំណោយផលជាក់ស្តែង ។

**៣- វត្ថុបំណងនៃសិក្សា :** នៅចុងបញ្ចប់នៃផ្នែកនេះ សិក្ខាកាមទាំងអស់ នឹងអាច :

១- រៀបរាប់មធ្យោបាយដែលលោកអ្នកនឹងធ្វើ ដើម្បីជំរុញលើកទឹកចិត្ត ឱ្យមានការចូលរួម របស់សហគមន៍

២- និយាយឡើងវិញពីជំហានទាំង៧ នៃការអប់រំសុខភាព

៣- ពន្យល់ពីតួនាទីនៃបុគ្គលិកមណ្ឌលសុខភាព នៅក្នុងការលើកកំពស់សុខភាព

៤- ធ្វើបញ្ជីប្រភពធនធានដែលមានស្រាប់របស់បុគ្គលិកមណ្ឌលសុខភាព សំរាប់ធ្វើសកម្មភាពអប់រំសុខភាព និង លើកកំពស់សុខភាព ។

## តើផ្នែកនេះនឹងជួយបុគ្គលិកមណ្ឌលសុខភាព ឱ្យរំឭកឡើងវិញនូវចំណុចសំខាន់ៗ ដែលបានសិក្សាក្នុងម៉ូឌុលនេះ យ៉ាងដូចម្តេច?

ផ្នែកនេះនឹងរៀបចំបុគ្គលិកមណ្ឌលសុខភាពឱ្យចេះធ្វើការសហការជាមួយ ស្រុកប្រតិបត្តិ ថ្នាក់ខេត្ត ថ្នាក់ជាតិ អង្គការដៃគូ ផ្នែកពាក់ព័ន្ធ និងសហគមន៍ នៅនឹងកន្លែងរបស់ពួកគេ ដើម្បីធ្វើសកម្មភាព អប់រំសុខភាព និង លើកកំពស់សុខភាព ។ ផ្នែកនេះត្រូវបានបំបែកទៅជាបីមេរៀន ដោយមេរៀននិមួយៗសំដៅទៅរកវត្ថុបំណងមួយ

**៤- សំភារៈ និង ការរៀបចំជាមុន :**

| | |
|---|---|
| **អ្នកនឹងត្រូវការ :** | សៀវភៅណែនាំសំរាប់មណ្ឌលសុខភាព ក្រដាសផ្ទាំងធំ ប៊ិច សំរាប់សកម្មភាពក្រុមតូច |

**ការរៀបចំមេរៀនជាមុន :**

**គ្រូ :** អានមេរៀននេះឡើងវិញដោយឡែកភាគ២ នៃផ្នែកលើកកំពស់សុខភាព នៅក្នុង" សៀវភៅណែនាំសំរាប់មណ្ឌលសុខភាព " ។

**ការណែនា :**

- គ្រូអាចធ្វើសកម្មភាពជាច្រើន តាមលទ្ធភាព និងតំរូវការរបស់ខ្លួន ។
- ដោយឥឡូវនេះជិតដល់ទីបញ្ចប់នៃវគ្គសិក្សា គ្រូអាចធ្វើការផ្លាស់ប្តូរ ឬលុបចោលសកម្មភាពមួយចំនួន ដោយផ្អែកលើពេលវេលាដែលនៅសេសសល់ សំរាប់ខ្លួន។

**គ្រូជំនួយ :** ត្រូវជួយគ្រូក្នុងការកត់ត្រា ការពិភាក្សាក្រុមធំ

**៥- សកម្មភាព :**

## វត្ថុបំណងទី១ : រៀបរាប់មធ្យោបាយដែលលោកអ្នកនឹងធ្វើ ដើម្បីជំរុញលើកទឹកចិត្តឱ្យមានការចូលរួមរបស់សហគមន៍

☞ គ្រូត្រូវណែនាំសិក្ខាកាមឱ្យមើលត្រឡប់ទៅវត្ថុបំណងនៅក្នុងផ្នែកទី១ នៃសៀវភៅការងាររបស់ពួកគេ និងផ្នែកនិមួយៗ នៃសេចក្តីសង្ខេបនៃមេរៀននេះ។

*សេចក្តីណែនាំនេះមានស្ទួននៅក្នុងសៀវភៅការងារសំរាប់សិក្ខាកាម*

**សកម្មភាព ៥-១-១** **ពិភាក្សាតាមចិត្ត**

បំណងនៃសកម្មភាពនេះ គឺណែនាំអោយសិក្ខាកាមម្នាក់ រំឭកការងារដែលបានគ្របដណ្តប់នៅក្នុងផ្នែកទី១ ឡើងវិញ។

**រយៈពេល :** ៥នាទី

**ការណែនាំ :** សុំអោយសិក្ខាកាមម្នាក់ៗ ជជែកជាមួយដៃគូរបស់ពួកគេ អំពីមធ្យោបាយចំនួន៣ដែលពួកគេនឹងធ្វើ ដើម្បីជំរុញលើកទឹកចិត្ត ឱ្យមានការចូលរួមរបស់សហគមន៍ នៅពេលដែលពួកគេត្រឡប់ទៅធ្វើការវិញ។

**ប្រមូលពត៌មានត្រឡប់ និង ពិភាក្សា**

☞ គ្រូត្រូវសួរទៅសិក្ខាកាមច្រើននាក់ អំពីសកម្មភាពដែលពួកគេបានគិតថា នឹងយកទៅធ្វើ

## វត្ថុបំណងទី ២ : និយាយឡើងវិញពីជំហានទាំង៧ នៃការអប់រំសុខភាព

☞ គ្រូត្រូវរំឭកកទំរង់ដែលមាន៧ជំហាននៃការអប់រំអតិថិជនឡើងវិញ

☞ គ្រូត្រូវឱ្យសិក្ខាកាមម្នាក់ៗនៅក្នុងថ្នាក់ និយាយឡើងវិញពីជំហាននិមួយៗ នៃជំហានទាំ៧ និងកត់ត្រាចម្លើយ

☞ គ្រូត្រូវបង្ហាញអោយសិក្ខាកាមមើលនូវ ទំរង់ទាំង៧នៃការអប់រំអតិថិជន ដោយប្រើក្រដាសថ្លា ឬ ក្រដាសផ្ទាំងធំ ។

| **ទំរង់ទាំង៧ជំហាននៃការអប់រំអតិថិជន :** | |
|---|---|
| **ជំហានទី១** | **: កំណត់បញ្ហា** |
| **ជំហានទី២** | **: ជ្រើសរើសខ្លឹមសារគ្លីនិកត្រឹមត្រូវ** |
| **ជំហានទី៣** | **: ជ្រើសរើសខ្លឹមសារបង្រៀនសមស្រប** |
| **ជំហានទី៤** | **: ជ្រើសរើសវិធីសាស្ត្របង្រៀន** |
| **ជំហានទី៥** | **: ជ្រើសរើសសំភារៈជំនួយ** |
| **ជំហានទី៦** | **: ស្វែងរកពត៌មានត្រឡប់ និងវាយតំលៃការអប់រំ** |
| **ជំហានទី៧** | **: កត់ត្រាសកម្មភាព និងលទ្ធផល** |

☞ គ្រូត្រូវរៀបចំសិក្ខាកាមសំរាប់ពិភាក្សាក្រុមតូច ចំនួន៣ក្រុម ។ គ្រូជំនួយត្រូវចែកក្រដាសផ្ទាំងធំ និងប៊ិច អោយទៅក្រុមនិមួយៗ

*សេចក្តីណែនាំនេះមានស្ទួននៅក្នុងសៀវភៅការងារសំរាប់សិក្ខាកាម*

**សកម្មភាព ៥-២-១** **ពិភាក្សាក្រុមធំ**

បំណងនៃសកម្មភាពនេះ គឺណែនាំសិក្ខាកាមឱ្យ រំពឹងគិតទៅដល់ផ្នែកទី២ ដែលទាក់ទងនឹងការអនុវត្តន៍ សកម្មភាពអប់រំសុខភាព។

**រយៈពេល** : ២០នាទី

**ការណែនាំ** : ស្នើសិក្ខាកាមម្នាក់ៗលើកឡើងនូវអ្វីៗ ដែលពួកគេរំពឹងគិតថា :

១- តើអ្វីខ្លះអាចនឹងមានភាពលំបាកជាងគេបំផុត ហើយអាចនឹងជួបប្រទះ នៅក្នុងការអនុវត្តន៏ការអប់រំសុខភាព?

២- តើត្រូវជ្រើសរើសបញ្ហាដែលអ្នកគិតថា កើតឡើងញឹកញាប់ជាងគេនោះ យកមកដោះស្រាយយ៉ាងដូម្តេច?

**ប្រមូលពត៌មានត្រឡប់ និង ពិភាក្សា :**

- គ្រូត្រូវសួរទៅសិក្ខាកាមច្រើននាក់ អំពី សកម្មភាពរបស់ពួកគេ

- ទុកពេលអោយសិក្ខាកាមឆ្លើយ ឬផ្ដល់យោបល់ និងបកស្រាយ
- គ្រូធ្វើការសំរបសំរួលចម្លើយសិក្ខាកាម

## វត្ថុបំណងទី៣: ពន្យល់ពីតួនាទីនៃបុគ្គលិកមណ្ឌលសុខភាព នៅក្នុងការលើកកំពស់សុខភាព

☞ **សកម្មភាពតាមសភាពការណ៍អំណោយផល : (ពិភាក្សាក្រុមធំ)**

គ្រូត្រូវជួយសំរួលការពិភាក្សាក្រុមធំមួយ តាមរយៈសំណួរ : **តើអ្វីខ្លះជាតួនាទីនៃបុគ្គលិកមណ្ឌលសុខភាពក្នុងការលើកកំពស់សុខភាព ?**

នៅភាគទី៣( ទំព័រ៣០៣) នៃសៀវភៅណែនាំសំរាប់មណ្ឌលសុខភាពមានផ្នែកមួយមានចំណងជើងថា "**ការលើកកំពស់សុខភាព**" ។ នៅក្នុងផ្នែកនេះមានពីរជំពូក " **អនាម័យ និងអាហារូបត្ថម្ភ** " ។ គ្រូត្រូវស្នើទៅសិក្ខាកាមទាំងអស់ ឱ្យអនុវត្តនូវភារកិច្ចរបស់ពួកគេ តាមរយៈសំណួរ : **តើត្រូវធ្វើការអប់រំ អំពី *អនាម័យ និងការផ្ដល់អាហារូបត្ថម្ភ* យ៉ាងដូចម្ដេចដើម្បីឱ្យសុខភាពកាន់ តែល្អប្រសើរឡើង?**

**ប្រមូលពត៌មានត្រឡប់ និង ពិភាក្សា**

- គ្រូត្រូវសួរទៅសិក្ខាកាមច្រើននាក់ ឆ្លើយតប
- ទុកពេលអោយសិក្ខាកាមឆ្លើយ ឬផ្ដល់យោបល់ និងបកស្រាយ
- គ្រូធ្វើការសំរបសំរួលចម្លើយសិក្ខាកាម

## វត្ថុបំណងទី៤: ធ្វើបញ្ជីប្រភពធនធានដែលមានស្រាប់របស់បុគ្គលិកមណ្ឌលសុខភាព សំរាប់ធ្វើសកម្មភាពអប់រំសុខភាព និងលើកកំពស់សុខភាព ។

☞ គ្រូត្រូវរៀបចំសំរាប់សកម្មភាពក្រុមតូច ចំនួន២ក្រុម ។

*សេចក្ដីណែនាំនេះមានស្ថិតនៅក្នុងសៀវភៅការងារសំរាប់សិក្ខាកាម*

**សកម្មភាព ៥-៤-១** **ពិភាក្សាក្រុមតូច**

បំណងនៃសកម្មភាពចុងក្រោយនេះ គឺណែនាំសិក្ខាកាមឱ្យគិត និងដោះស្រាយ ទៅនឹងសំណួរ ដែលថា :

១- តើអ្វីខ្លះ ដែលជាប្រភពធនធាន ដែលមានស្រាប់ នៅនឹងទីកន្លែងរបស់លោកអ្នក? និង

២- តើលោកអ្នក អាចយកវាមកប្រើប្រាស់បានយ៉ាងដូចម្តេច?

**រយៈពេល** : ១៥នាទី

**ការណែនាំ** : សូមសិក្ខាកាមទាំង២ក្រុម ដោះស្រាយសំណួរទាំង២ខាងលើ ដោយផ្សារភ្ជាប់ទៅនឹងឧទាហរណ៍ខាងក្រោមនេះ :

- សិក្ខាកាមពាក់កណ្តាលនៃក្រុម : គួរចាត់ទុកថាជាធនធាន " **មនុស្ស** " និង
- សិក្ខាកាមពាក់កណ្តាលទៀត : គួរចាត់ទុកថាមានធនធាន " **សំភារៈ និងហិរញ្ញវត្ថុ** " ដែលអាចប្រើ សំរាប់ការអប់រំសុខភាព និងការលើកកំពស់សុខភាព។

**បង្ហាញលទ្ធផល និង ពិភាក្សា** (រយៈពេល: ៥នាទីក្នុង១ក្រុម)

- តំណាងក្រុមនិមួយៗឡើងមកបង្ហាញលទ្ធផល
- ទុកពេលអោយសិក្ខាកាមសួរ ឬផ្តល់យោបល់ និងបកស្រាយ
- គ្រូធ្វើការសំរបសំរួលចម្លើយសិក្ខាកាម

✍ **សង្ខេប :**

☞ គ្រូសរសេរលើក្រដាសផ្ទាំងធំ ដែលជាសេចក្តីសង្ខេបចំណុចសំខាន់ៗនៃមេរៀនដែលបានរៀនសូត្រហើយ យកទៅបិទនៅលើជញ្ជាំង ហើយគ្រូគួរជំរុញលើកទឹកចិត្តសិក្ខាកាមឱ្យអានននូវពត៌មានទាំងនោះ សំរាប់ជាប្រយោជន៏ដល់ខ្លួនពួក។

☞ គ្រូត្រូវអាន និងគូសបញ្ជាក់ ចំណុចសំខាន់ៗដែលជាគន្លឹះ នៅក្នុងសេចក្តីសង្ខេបត្រូវលើកឡើងទាំងនោះ ដើម្បី រំឭកឱ្យសិក្ខាកាមងាយចងចាំ។

ᯣ✶ᯤ

☞ គ្រូផ្តល់ក្រដាសនៃ **សំណួរសាកល្បងក្រោយពេលសិក្សា** ឱ្យសិក្ខាកាមបំពេញដោយខ្លួនឯង ដោយមិនឱ្យជជែកគ្នា។

☞ ពេលសិក្ខាកាមបំពេញសំណួរសាកល្បងចប់ គ្រូត្រូវប្រមូលសំណួរសាកល្បងយកទៅកែ និងសរសេរជាបាយការណ៍លទ្ធផលចូលក្នុងតារាង ។

☞ គ្រូត្រូវពន្យល់ឡើងវិញ នូវចំណុចណាដែលសិក្ខាកាមធ្វើខុសច្រើន ដើម្បីជៀសវាងការយល់ច្រឡំនៅពេលបញ្ចប់វគ្គ។

# សកម្មភាពបន្ថែម សំរាប់សិក្ខាកាមណាដែលមានបំណងសិក្សាថែមទៀត

រឿងនិទានខាងក្រោមនេះបានត្រូវយកចេញពីរឿងមួយក្នុងសៀវភៅ : **ការជួយដល់បុគ្គលិកសុខាភិបាល ដើម្បីសិក្សា** សរសេរដោយ ដាវីដវ៉រនឺ និងបីលបិវអឺ (ឯកសារសំអាងទាំងអស់មាននៅផ្នែកខាងមុខនៃសៀវភៅណែនាំគ្រូនេះ)។ រឿងនិទានអាចយកទៅប្រើ ដើម្បីបង្រៀនកុមារអោយចេះព្យាបាលជំងឺរាក ហើយនេះជាឧទាហរណ៍មួយនៃ**ការចូលរួម**របស់កុមារជាបុគ្គលិកសុខាភិបាល។ អ្នកនឹងកត់ចំណាំនៅក្នុងរឿងនិទាននេះ ចំពោះគ្រូម្នាក់ពន្យល់ដល់កុមារម្នាក់ៗនៅក្នុងសាលារៀន តើត្រូវព្យាបាលជំងឺរាកយ៉ាងដូចម្តេច។ បុគ្គលិកមណ្ឌលសុខភាពត្រូវជំរុញលើកទឹកចិត្តតាមឧទាហរណ៍នេះ។ អ្នកប្រហែលជាមានលទ្ធផល ដើម្បីគិតឡើងនូវវិធីផ្សេងៗទៀត ដើម្បីអោយកុមារចូលរួមជាបុគ្គលិកសុខាភិបាល ។ សៀវភៅ "ការជួយដល់បុគ្គលិកសុខាភិបាល ដើម្បីសិក្សា" នេះមានគំនិតជាច្រើន ដែលអាចយកតំរាប់តាមសំរាប់ប្រើប្រាស់ផ្ទាល់ខ្លួន។

*សេចក្តីណែនាំនេះមានស្នូននៅក្នុងសៀវភៅការងារសំរាប់សិក្ខាកាម*

## បូណា និង នារី : រឿងនិទានរបស់កុមារ រំលេចដោយរូបភាពរបស់ប្រទេសឥណ្ឌូនេស៊ី

**បូណា** បានរត់ត្រឡប់ពីសាលាមកផ្ទះវិញយ៉ាងលឿន ដូចថ្ងៃដែលប្អូនស្រីរបស់វា (នារី) បានកើត ។ គ្រាន់តែបានឃើញប្អូនវានៅក្នុងទីធ្លាភ្លាម ភ្នែករបស់វាមានពន្លឺឡើង។ទោះជាបូណាមានអាយុ៨ឆ្នាំហើយក៏ដោយ ក៏វាចូលចិត្តលេងជាមួយប្អូនស្រីតូចរបស់វាណាស់ដែរ។

**នារី** មានអាយុទើបតែ១ឆ្នាំកន្លះ។ នាងទះដៃដោយរីករាយ នៅពេលណាដែលបូណា ធ្វើមុខក្រមាច់ក្រមើមដាក់នាង ឬស្រែកកកែកករ នៅពេលដែលវាបានរាប់ម្រាមជើងរបស់នាង។ បូណា បានជួយដល់នាងអោយរៀនដើរតាមជំហានដំបូង ដោយលើកនាងយ៉ាងទន់ភ្លន់ នៅពេលដែលនាងដួល។

តើថ្ងៃនេះមានអ្វីខ្លះខុសប្លែក? ជាធម្មតានារី ដើរតេះតះតំរង់មករក បូណា ដោយបោះដៃនាងទាំងពីរ ។ តែឥឡូវនេះនាងបានត្រឹមអង្គុយនៅលើកម្រាល និងសំឡឹងជាប់មករកបូណា ដោយកែវភ្នែកធុញទ្រាន់។ បូណា លើកនាងពរ ដាក់លើចង្កេះយ៉ាងលឿន។ បូណា កត់សំគាល់ថា នាងពិតជាមិនបានងូតទឹកដូចធម្មតាទេ មុនពេលវាត្រឡប់មកផ្ទះវិញពីព្រោះ នាងមានក្លិនមិនល្អចេញពីខ្លួន។

យាយរបស់វា បាននិយាយរាក់ទាក់ ដោយសំឡេងហេវហត់ ។ ដោយមានការព្រួយបារម្ភ បូណាសួរយាយថា "តើនារីឈឺឬ? ហេតុអ្វីក៏នាងធ្វើដូចនេះ?" យាយវាឆ្លើយមកវិញ " វាជុះសុទ្ធតែទឹកច្រើនដងណាស់ ថ្ងៃនេះ ហើយវា

ទៅជារញ៉ុំរញ៉ូវ ពិបាកណាស់ បូណាឯងមិនត្រូវអោយចំណី ឬអោយវាផឹកអ្វីទេ ដូចនេះរាកនឹងឈប់ ហើយវានឹងធូរស្រាលឡើងវិញ។

**បូណា**គិតមួយសន្ទុះ និងបន្ទាប់មកវា (ដកដង្ហើមចូលពេញក្នុងទ្រូង) តាំងចិត្តក្លាហានស្រែកឡើង "យាយ ប៉ុន្តែគ្រូខ្ញុំប្រាប់ថា លាមកសុទ្ធតែទឹកអាចគ្រោះថ្នាក់ណាស់។ ប្រសិនបើខ្លួនរបស់យើងបាត់បង់ទឹកវាដូចជារុក្ខជាតិគ្មានទឹកដែរ។ ដំបូងវាខ្សោយទៅៗ និងបន្ទាប់មកវាស្លាប់! ដូច្នេះយើងត្រូវតែអោយនារីផឹកទឹកអោយបានគ្រប់គ្រាន់ នោះនាងនឹងមិនខ្សោយរបៀបនេះទៀតទេ" ។

យាយអាចដឹងថាបូណាបានជឿជាក់ប៉ុណ្ណាពីអ្វីដែលវាបាននិយាយ ហើយគាត់ក៏មានអំនួតណាស់ដែរ ដែលថា ចៅរបស់គាត់ មានសំណាងបានទៅសាលារៀន ដើម្បីរៀនពីអ្វីថ្មីៗ។ ប៉ុន្តែរហូតមកដល់ពេលនេះនៅមិនទាន់មាននរណាម្នាក់បានអោយចំណីអាហារ ឬទឹកផឹក ចំពោះកុមារម្នាក់ដែលមានលាមកសុទ្ធតែទឹកនោះទេ នេះបើតាមដែលគាត់ចាំ ។ នៅពេលដែលបូណាសម្លឹងមករកគាត់ដោយកែវភ្នែកអង្វរ និងរង់ចាំចម្លើយពីគាត់ គាត់បានគិតដល់កូនសម្លាញ់ចិត្តរបស់គាត់ ដែលបានស្លាប់ទៅ ក្រោយពេលជុះលាមកសុទ្ធតែទឹកតែពីរថ្ងៃប៉ុណ្ណោះ និងធ្លាប់កើតមានអ្វីខ្លះចំពោះក្មេងតូច **សុជាតិ** ដែលនៅផ្ទះជាប់គ្នាបានស្លាប់ទៅដោយរបៀបដូចគ្នានេះ។ យាយបានដកដង្ហើមធំ និង និយាយទន់ភ្លន់ទៅកាន់បូណា **"មើលចៅ គ្រូឯងប្រហែលនិយាយត្រឹមត្រូវ យើងគួរសាកល្បងរបៀបថ្មីម្តង តើអ្នកគ្រូឯងនិយាយអ្វីខ្លះ? ដែលយើងត្រូវធ្វើ?"** ។

បូណា សំឡឹងទៅយាយវាដោយក្តីគោរពជាថ្មីទៀត បូណា ហុចនារីឱ្យយាយពរ ហើយសុំឱ្យគាត់មកតាមវា។ បូណាដាក់ទឹកមួយចំនួនយ៉ាងលឿន ដើម្បីដាំអោយពុះ ហើយបន្ទាប់មករង់ចាំអោយទឹកត្រជាក់ ។ បូណានិយាយប្រាប់យាយវាពីគ្រឿងផ្សំងាយៗដែលជួយនារីបាន។ យាយវាពិបាកនឹងជឿ ដែលថាស្ករកិនមួយស្លាបព្រាបង្អែម(តែ) និង អំបិលមួយចិប ដាក់ទៅក្នុងទឹកឆ្អិនមួយកែវ អាចជារបស់ត្រឹមត្រូវដែលត្រូវអោយនារីផឹក ប៉ុន្តែគាត់បានសំរេចចិត្ត ហើយថា ទុកអោយបូណាសាកល្បងសិន។

គ្រាន់តែទឹកត្រជាក់ល្មមអាចឱ្យនារីផឹកបាន បូណាចាប់ផ្តើមដាក់ស្ករមួយស្លាបព្រាបង្អែម និងអំបិលមួយចឹប។ វាបានភ្លក់មើល ហើយអោយទឹកនោះទៅនារីផឹក។ នាងស្រេកយ៉ាងខ្លាំង នាងផឹកទាល់តែអស់មួយកែវ! បូណា បានរៀបចំអោយនាងមួយកែវទៀត ដោយដាក់ចំនួនត្រឹមត្រូវនូវស្ករនិងអំបិលជាថ្មីម្តងទៀត។ យាយបានសំឡឹងមើលដោយភ្ញាក់ផ្អើល នៅពេលដែល នារីបានផឹកទឹកអស់ពីកែវទីពីរទៀត។

ភ្លាមនោះនារីបានក្អួត ហើយយាយបានសំឡឹងមើល ក្នុងសភាពដូចជាបន្ទោសអោយបូណា ។ បូណា " អ្នកគ្រូខ្ញុំនិយាយថា មិនត្រូវបារម្ភទេ ប្រសិនបើកុមារក្អួតនៅពេលផ្តើមផឹកទឹកដំបូង យើងសាកល្បងម្តងទៀត"។ បូណាលាយទឹកកែវទី៣ សំរាប់អោយនារី ប៉ុន្តែម្តងនេះ វាសុំអោយនារីផឹកយឺតៗ។ នៅពេលដែលទឹកកែវទី៣នោះបានត្រូវផឹកអស់ នារីបានទះដៃរបស់នាង និងចាប់ផ្តើមពត់ពេនខ្លួន សាកល្បងចុះចេញពីដៃយាយ ភ្នែករបស់នាងរេតាមបូណា ពីព្រោះបូណាដកយកនំមួយចេញមក។ ចុងក្រោយបង្អស់នារីសំរូតចុះចេញពីដៃយាយ ហើយដើរសំដៅទៅបូណា ដោយដៃឈោង

ទៅចាប់យកនំ។ ភ្លាមនោះនារីរាកម្តងទៀត ធ្វើឱ្យយាយកាន់តែមិនទុកចិត្ត។ បូណានិយាយ "កុំបារម្ភយាយ នាងធូរស្រាល ច្រើនហើយ មើលមើហ៍ តើនាងវះវរវាមយ៉ាងម៉េចដើម្បីយកនំ នាងនៅស្រេកនៅឡើយ! នាងកំពុង សាកល្បងចាប់យកកែវទឹក"។

បូណាបានជួយអោយនារីផឹកទឹកអស់មួយកែវផ្សេងទៀត។ នៅពេលដែលម្តាយវាត្រឡប់មកពីផ្សារដល់ផ្ទះវិញ "នារីយ៉ាងម៉េចហើយ" ម្តាយនារីបានសួរទៅយាយដោយកង្វល់។ នារីបានដើរទៅរកសំលេងម្តាយ ភ្នែករបស់វាមានពន្លឺភ្លឺថ្លាដោយការទទួលស្គាល់។ ម្តាយបូណានិយាយថា " ហេតុអ្វីក៏នាងឆាប់ធូរស្រាលលឿនយ៉ាងនេះ ខ្ញុំយល់ហើយ ខ្ញុំបានធូរស្រាលក្នុងចិត្តហើយ។ កុំអោយនាងញ៉ាំ ឬផឹកទឹកអោយសោះ ពិតជាបានជួយនាង"។

"អូ ! ទេ យាយ និយាយឡើងដោយញញឹមទៅរកបូណា " យើងបានសាកល្បងវិធីថ្មី ហើយមើលមើហ៍ នារីផ្លាស់ប្តូរយ៉ាងដូចម្តេចតាំងពីព្រឹកមក ?"។ បូណាឯងប្រាប់ម្តាយឯងទៅ តើឯងបានអោយអ្វីខ្លះទៅនារី បូណាបាន រៀបរាប់ប្រាប់ម្តាយ។ បូណានិយាយបន្ថែមថា ខ្ញុំនឹងនៅរង់ចាំ រហូតដល់ម៉ែមកថែរក្សានារីវិញ។ បន្ទាប់មកម្តាយសប្បាយរីករាយ។

នៅថ្ងៃបន្ទាប់ បូណាទៅសាលាតាំងពីព្រលឹម វាបានប្រាប់គ្រូវាដោយអឹមអៀនថាវាបានសាកល្បងលាយគ្រឿងផ្សំដែលអ្នកគ្រូបានបង្រៀនវានៅក្នុងថ្នាក់ដើម្បីប្រើក្នុងករណីនរណាម្នាក់នៅក្នុងគ្រួសារ មានលាមកសុទ្ធតែទឹក។ អ្នកគ្រូរបស់វាសប្បាយចិត្តណាស់ ដែលវានៅចាំបាន ដោយប្រើស្ករមួយស្លាប់ព្រាបង្អែម អំបិលមួយចិប ក្នុងទឹកឆ្អិនមួយកែវ ។ អ្នកគ្រូកាន់តែសប្បាយចិត្តទៀតដោយដឹងថា ថ្វីត្បិតតែនៅថ្ងៃនោះ នារីនៅមានលាមកសុទ្ធតែទឹកពីរដងទៀត តែថ្ងៃនេះមិនមានរាកទៀតទេ។

ត្រូវធ្វើអោយប្រាកដថា នារីរក្សាការផឹកនិងញ៉ាំចំណីអាហារបន្ថែមទៀត ដូចនេះនាងនឹងរឹងមាំដូចពីមុនវិញ អ្នកគ្រូរំលឹកបូណា" ឯងពិតជារៀនបានល្អមែន" បូណារំភើបក្នុងចិត្ត។ នៅពេលឈប់រៀនថ្ងៃនេះ វារត់ត្រឡប់មកផ្ទះវិញដោយមានចិត្តរីករាយ និងឃើញនារីកំពុងលេង បោះដៃមករកបូណា ហើយភ្នែកនាងមានពន្លឺ កំពុងរង់ចាំល្បែងថ្មីមួយទៀត។

# វិធីសាស្ត្របង្រៀនតាមបែបចូលរួម

## សំណួរបំផុសគំនិត :

បំណងនៃសំនួរបំផុសគំនិតគឺ ឱ្យសិក្ខាកាមនិយាយចេញនូវគំនិតរបស់ពួកគេទៅកាន់គ្រូយ៉ាងលឿន។ គ្រូជំនួយកត់ត្រាគំនិតទាំងនោះលើក្តាខៀន។ វាមានសារៈសំខាន់ណាស់ ដែលត្រូវមានសិក្ខាកាមនិយាយចេញមកនូវគំនិតយ៉ាងលឿន ព្រោះអ្វីដែលសិក្ខាកាមម្នាក់អាចនិយាយ ផ្តល់អោយសិក្ខាកាមផ្សេងទៀតក្នុងថ្នាក់នូវគំនិតសំរាប់និយាយចេញមក ។ ជួនកាលគ្រូអាចសួរសំណួរខ្លះៗ ប្រសិនបើសិក្ខាកាមទាំងអស់មានសភាពស្ងប់ស្ងាត់។ **គ្រូគួរកុំធ្វើការវិនិច្ឆ័យលើគំនិតខុស ឬត្រូវ របស់សិក្ខាកាម**។ បន្ទាប់មកសិក្ខាកាមជាមួយ គ្រូជំនួយ អាចជ្រើសរើសគំនិតដែលល្អជាងគេ។

## ពិភាក្សាតាមចិត្ត :

រយៈពេលច្រើនបំផុត២ ទៅ ៥នាទី។ សិក្ខាកាមទាំងអស់ជជែកគ្នាឮរងំ។ បន្ទាប់មក អ្នកដឹងថា អ្នកបានទទួលលទ្ធផល! វាជាឱកាសមួយសំរាប់ការពិភាក្សាខ្លីៗ រវាងសិក្ខាកាម២-៣នាក់។ ជាញឹកញយ គេយកមកប្រើសំរាប់ប្រធានបទ ឬពេលវេលាត្រូវការជជែកពិភាក្សា នៅពេលនោះសិក្ខាកាមចាប់ផ្តើមនិយាយគ្នាដោយឯកឯង។ គ្រូអាចនិយាយយ៉ាងលឿន ដើម្បីអោយក្រុមធំមានរបៀប និងត្រូវសួរនូវសំណួរខ្លះៗ ពីការជជែករបស់ពួកគេ។

## ល្បែង :

មានល្បែងជាច្រើនដែលសមស្រប សំរាប់ប្រើនៅក្នុងវគ្គបណ្តុះបណ្តាល

### ១- ល្បែងកសាងទំនុកចិត្ត

មានប្រយោជន៍ ក្នុងការយកមកប្រើមុនធ្វើសកម្មភាពទាំងឡាយ ។ ឧទាហរណ៍ដូចជាល្បែងសំដែងតួ។

- មនុស្សម្នាក់ៗរើសយកដៃគូមួយ
- ម្នាក់ឈរពីក្រោយម្នាក់ទៀត ទាំងពីរនាក់បែរមុខទៅទិសដូចគ្នា និងមានគំលាតប្រវែងពាក់កណ្តាលខ្លួនឃ្លាតពីគ្នា
- អ្នកនៅខាងមុខ ដួលមកក្រោយ ទៅក្នុងដៃអ្នកនៅខាងក្រោយ។ ពួកគេមានទុកចិត្តថា មនុស្សនៅខាងក្រោយនឹងទ្រពួកគេ។ ល្បែងនេះអាចបានធ្វើផ្ទួនឡើងវិញ ដោយដៃគូ ដូរកន្លែងគ្នា។

### ២- ល្បែងសហការ :

មានប្រយោជន៍ដើម្បីបង្ហាញពីតំលៃនៃកិច្ចសហការ

- គួរលេងនៅក្រោយអាហារសំរន់ពេលព្រឹក ឬក្រោយអាហារថ្ងៃត្រង់

- សិក្ខាកាមជ្រើសរើសដៃគូម្នាក់
- ពួកគេឈរក្បែរគ្នា
- ដៃឆ្វេងនៃសិក្ខាកាមម្នាក់ ត្រូវបានចងដោយប្រើខ្សែ ទៅនឹងដៃស្តាំសិក្ខាកាមម្នាក់ទៀត
- ដៃម្ខាងទៀតដែលនៅទំនេរ ត្រូវដាក់ទៅខាងក្រោយខ្នងរបស់ពួកគេ
- ទាំងពីរនាក់ឥឡូវនេះត្រូវផឹកទឹកតែ ជាលទ្ធផលគឺមនុស្សទាំងពីរនាក់មិនអាចផឹកទឹកតែបានក្នុងពេលដូចគ្នា មនុស្សទី១ អាចផឹក និងបរិភោគ បានដោយមានកិច្ចសហការពីមនុស្សម្នាក់ទៀត។ បន្ទាប់មក គឺដល់វេន មនុស្ស ម្នាក់ទៀត ផឹក ឬបរិភោគ វិញម្តង។

## ល្បែងសំដែងតួ :

រយៈពេលប្រហែល២០នាទី (២-៣នាទីរៀបចំភារៈកិច្ច ៣-៥នាទីសំរាប់សំដែងតួ ៥នាទីសំរាប់បកស្រាយខ្លីៗ)។ សមាជិកនៃក្រុមត្រូវស្គាល់ និងទុកចិត្តគ្នាទៅវិញទៅមក។

១- ជ្រើសយកប្រធានបទមួយ។ ជ្រើសរើសអ្នកស្ម័គ្រចិត្ត ២-៣ នាក់ ជាអ្នកសំដែង អ្នកដែលនៅសល់ក្នុងក្រុម ជាអ្នកសង្កេតមើល ។

២- ផ្តល់នូវគោលការណ៍ណែនាំខ្លីៗ ដល់អ្នកសំដែងតួ ហើយទុកពេលអោយពួកគេរៀបចំ

៣- នៅពេលដែលអ្នកសំដែងកំពុងរៀបចំ គ្រូណែនាំដល់អ្នកសង្កេត ដូចជា :

+ ហាមនិយាយ ឧទាហរណ៍ ពេលសំឡឹងមើលចំអ្នកសំដែង
+ ផលវិបាកនៃការនិយាយប្រាប់

៤- គ្រូត្រូវដឹកនាំការពិភាក្សា។ សួរទៅអ្នកអង្កេតមើល អោយបកស្រាយពីការសង្កេតរបស់ពួកគេ។ ទុកពេល អោយអ្នកសំដែងគិតថា តើអារម្មណ៍របស់ពួកគេយ៉ាងដូចម្តេច?

## ពិភាក្សាក្រុមតូច :

**ជំហានទី១ :** ផ្តល់សេចក្តីណែនាំទៅក្រុម ដូចនេះពួកគេយល់បានពីភារៈកិច្ចទាំងនោះ

**ជំហានទី២ :** បំបែកក្រុមធំទៅជាក្រុមតូច ចំនួន៥-៨នាក់។ ជួនកាលក្រុមច្រើនជាងមួយអាចធ្វើភារៈកិច្ចដូចគ្នា។

**យុទ្ធវិធី :**

- សិក្ខាកាមទី១ រាប់១ សិក្ខាមបន្ទាប់រាប់២ សិក្ខាមបន្ទាប់រាប់៣ សិក្ខាមបន្ទាប់រាប់៤ សិក្ខាមបន្ទាប់រាប់៥ សិក្ខាមបន្ទាប់រាប់១ សិក្ខាមបន្ទាប់រាប់២ ។ល។ និង ។ល។ រហូតដល់មនុស្សនៅក្នុងថ្នាក់មានពី១ ដល់៥។ អ្នកដែលមានលេខ ១ទាំងអស់បង្កើត ជាក្រុមទី១ អ្នកលេខ២ បង្កើតជាក្រុមទី២ ។ល ។និង ។ល ។
- មនុស្សមកពីមណ្ឌលសុខភាព ជាមួយគ្នាបង្កើតជាក្រុមពិភាក្សាមួយ
- មនុស្សមានភាពជាក់ច្បាស់ដូចគ្នា បង្កើតជាក្រុមមួយ ឧទាហរណ៍ ឆ្មបបុរាណ អ្នកត្រួតពិនិត្យ ស្ត្រី បុរស

**ជំហានទី៣ :**

- គ្រូគួរផ្តល់ទីកន្លែងមួយ សំរាប់អោយក្រុមអាចប្រជុំរួម

**ជំហានទី៤ :**

- រំលឹកឡើងវិញ នូវភារៈកិច្ចទៅអោយក្រុម ។ អោយក្រដាសផ្ទាំងធំ ហ្វឺត ប៊ិចដល់ក្រុមនិមួយៗ

**ជំហានទី៥ :**

- គ្រូត្រូវចល័តនៅក្នុងថ្នាក់ ហើយសង្កេតមើលសិក្ខាកាមកំពុងធ្វើការ ។ ប្រសិនបើមានក្រុមណាមួយ មានការពិបាកយល់ពីភារៈកិច្ចនោះ អ្នកនឹងត្រូវការជជែកជាមួយពួកគេដើម្បី បញ្ជាក់អោយច្បាស់នូវការមិនយល់ច្បាស់ របស់ពួកគេ ។ អ្នកត្រូវពិនិត្យឆែកមើលក្រុមដទៃទៀតអាចធ្វើភារៈកិច្ចនោះបានឬទេ ។ ប្រសិនបើមនុស្សទាំង អស់មានបញ្ហា ប្រមូលពួកគេត្រឡប់មកវិញម្តងទៀត ហើយរំលឹកម្តងទៀត នូវសេចក្តីណែនាំ នៅក្នុងរបៀបមួយ ដែលថាគ្រប់ៗគ្នាបានយល់ពីភារៈកិច្ច ។ ជួនកាលអ្នកនឹងត្រូវផ្តល់អោយក្រុមនូវសំណួរបំផុសគំនិតមួយចំនួន ឬ គំនិតមួយចំនួនធ្វើអោយពួកគេចាប់ផ្តើមបាន ។

**ជំហានទី៦ :**

- គ្រូត្រូវអង្កេតមើលពេលវេលា និងផ្តល់នូវការរំលឹក១-៣នាទី មុនពេលក្រុមត្រូវបញ្ចប់ ការពិភាក្សារបស់ពួកគេ ។

**ជំហានទី៧ :**

- ប្រមូលផ្តុំ ក្រុមមកវិញ និងជួយសំរួលពិតមានត្រឡប់

**ជំហានទី៨ :**

- ប្រមូល ក្រដាសផ្ទាំងធំ ហ្វឺត និងប៊ិច

ឈ្មោះ : ............................................ មកពីមណ្ឌលសុខភាព:.............................................

ស្រុកប្រតិបត្តិ :.................................. ថ្ងៃទី :.........../............./...............

# សំណួរសាកល្បង

(រយៈពេល ៤0នាទី)

**ផ្នែកទី** I

១- ជ្រើសរើសពាក្យខាងក្រោម ហើយដាក់អោយត្រឹមត្រូវទៅនឹងប្រយោគខាងក្រោមដោយសរសេរតែអក្សរ ក-ខ។ ពាក្យមួយអាចប្រើបានតែម្តងគត់។

## និយមន័យនៃពាក្យ

ក- ការអប់រំសុខភាព ខ- ការលើកកំពស់សុខភាព

❶..................: មានន័យថា គឺជាការរួមបញ្ចូលគ្នានូវការអប់រំសុខភាព ដែលមានសកម្មភាពទាំងផ្នែកនយោបាយ ផ្នែកសេដ្ឋកិច្ច ផ្នែកអង្គការចាត់តាំង ក្នុងគោលបំណងសំរួលដល់ការធ្វើអោយមានបរិស្ថាន និងអំពើប្រព្រឹត្តិ ដែលបង្កើន ឬ ការពារសុខភាព។

❷..................: មានន័យថា គឺជាការផ្សព្វផ្សាយពិតមានទាំងឡាយ ដែលទាក់ទងទៅនឹងវិធានការបង្ការជំងឺ ហើយធ្វើអោយប្រជាជន ព្រមទទួលនូវទំលាប់ថ្មី ឬអំពើប្រព្រឹត្តិថ្មីដែលនាំមកនូវសុខភាព។

២-អានពាក្យទាំងនេះ ហើយសំរេចដាក់ទៅក្នុងប្រអប់ខាងក្រោមបានត្រឹមត្រូវដោយសរសេរតែអក្សរ ក-ខ-គ-ឃ-ង។ ពាក្យមួយអាចប្រើបានតែម្តងគត់។

## បែបបទនៃការធ្វើផែនការ សំរាប់ការលើកកំពស់សុខភាព

| | |
|---|---|
| ក- អភិវឌ្ឍសកម្មភាព | ❶ ................................................ |
| ខ- គោលដៅ និងគោលដៅចំណុច | ❷................................................ |
| គ- ពិនិត្យលទ្ធផលប្រចាំឆ្នាំ | ❸ ................................................ |
| ឃ- ត្រួតពិនិត្យតាមដាន និងវាយតំលៃ | ❹ ................................................ |
| ង- កែតំរូវផែនការប្រតិបត្តិ | ❺ ................................................ |
| ច- គណនាតំលៃចំណាយផែនការសកម្មភាព | ❻ ................................................ |

៣-អានពាក្យទាំងនេះ ហើយសំរេចដាក់ទៅក្នុងប្រអប់ខាងក្រោមអោយបានត្រឹមត្រូវ ដោយសរសេរតែអក្សរ ក-ខ-គ-ឃ-ង-ច-ឆ។ ពាក្យ មួយអាចប្រើបានតែម្តងគត់។

## ជំហានទាំង៧នៃការអប់រំអតិថិជន

| | |
|---|---|
| ក- ជ្រើសរើសខ្លឹមសារបង្រៀនសមស្រប | ① ................................................ |
| ខ- ជ្រើសរើសសំភារៈជំនួយ | ② ................................................ |
| គ- ជ្រើសរើសវិធីសាស្រ្តបង្រៀន | ③ ................................................ |
| ឃ- កំណត់បញ្ហា | ④ ................................................ |
| ង- កំណត់គ្រោសកម្មភាព និងលទ្ធផល | ⑤ ................................................ |
| ច- ស្វែងរកពតិតមានត្រឡប់ និងវាយតំលៃការអប់រំ | ⑥ ................................................ |
| ឆ- ជ្រើសរើសខ្លឹមសារគ្លីនិកត្រឹមត្រូវ | ⑦ ................................................ |

ពិន្ទុសរុបក្នុងផ្នែកទី I : .................. X ២ = [ ]

**ផ្នែកទី II :** សូមគូសរង្វង់ជុំវិញពាក្យ **ត្រូវ** បើសិនអ្នកយល់ថាប្រយោគត្រឹមត្រូវ ។ បើអ្នកយល់ថាប្រយោគមិនត្រឹមត្រូវ សូមគូសរង្វង់ជុំវិញពាក្យ **ខុស** ។

**ត្រូវ-ខុស** ១- ការទទួលជោគជ័យរបស់សហគមន៍ក្នុងការដំណើរការប្រព័ន្ធថែទាំសុខភាព គឺពឹងផ្អែកទាំងស្រុង តែលើបុគ្គលិកសុខាភិបាលប៉ុណ្ណោះ ។

**ត្រូវ-ខុស** ២- ប្រសិនបើប្រជាជននៅក្នុងសហគមន៍ចូលរួមយ៉ាងសកម្មក្នុងការសំរេចចិត្តអំពីបញ្ហាសុខភាព លទ្ធផល គឺហាក់ដូចជាមានការយល់ដឹងខ្ពស់អំពីសារៈសំខាន់នៃសុខភាពនៅក្នុងសហគមន៍។

**ត្រូវ-ខុស** ៣- ប្រសិនបើប្រជាជនយល់ដឹងដោយខ្លួនឯងពីរបៀបផ្លាស់ប្តូរការប្រព្រឹត្តិទៅលើគ្រោះថ្នាក់នៃសុខភាព ដោយមានការជួយណែនាំពីបុគ្គលិកសុខាភិបាល ដូច្នេះការផ្លាស់ប្តូរផ្សេងៗ គឺហាក់ដូចជាមាននិរន្តរភាព បន្ទាប់ពីជំនួយថវិកាផ្សេងៗត្រូវបានបញ្ចប់។

**ត្រូវ-ខុស** ៤- ជោគជ័យ១ បង្កើតឱ្យមានជោគជ័យ១ទៀត ពីព្រោះប្រជាជនមើលឃើញការចំណេញនៃការចូលរួមពួកគេ នឹងត្រៀមដើម្បីចូលរួមកាន់តែច្រើនឡើង។

**ត្រូវ-ខុស** ៥- ក្នុងគោលបំណងដើម្បីដាក់ឱ្យអនុវត្តការផ្លាស់ប្តូរការប្រព្រឹត្តមួយឱ្យបានយ៉ាងឆាប់រហ័ស ជួនកាលរដ្ឋាភិបាលប្រើការគប់គ្រង ដើម្បីផ្លាស់ប្តូរអាកប្បកិរិយា និងត្រួតពិនិត្យថាតើប្រភពធនធាន បានត្រូវប្រើយ៉ាងដូចម្តេចនោះ គឺវាមិនមែនជាកត្តាដែលរាំងស្ទះដល់ដៃគូរការងារទេ ។

**ត្រូវ-ខុស**៦- នៅពេលមនុស្ស ឬសហគមន៍កត់សំគាល់ និងស្វែងរកការព្យាបាល បញ្ហានេះត្រូវបានគេហៅថា តំរូវការសុខភាពពិតប្រាកដ។

**ត្រូវ-ខុស** ៧- នៅពេលដែលបញ្ហាសុខភាពត្រូវបានកត់សំគាល់ដោយបុគ្គលិកសុខាភិបាលថា វាគឺជាឫសគល់ ឬមូលហេតុពិតប្រាកដនៃជំងឺភាគច្រើន បញ្ហានេះគេហៅថា តំរូវការសុខភាពផ្នែកអារម្មណ៍។

**ត្រូវ-ខុស** ៨- តំរូវការសុខភាពពិតប្រាកដ ជាបញ្ហានៃជំងឺ ឬកង្វះខាតនៃសុខភាព ដែលជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរទៅលើសុខភាព អ្នកជំងឺ ក្រុមគ្រួសារ ឬសហគមន៍យ៉ាងយូរ។

**ត្រូវ-ខុស** ៩- ប្រភេទសកម្មភាព មនុស្សម្នាក់ទៅមនុស្សម្នាក់ គឺជាទំរង់ការនៃការប្រជុំ ដូចជា ជាមួយអ្នកដឹកនាំសហគមន៍ គ្រូបង្រៀន គណៈកម្មការគ្រប់គ្រងមណ្ឌលសុខភាព ក្រុមទ្រទ្រង់សុខភាពភូមិ ឆ្មបបូរាណ និងការប្រជុំមិនផ្លូវការនៅតាមទីប្រជុំជន។

**ត្រូវ-ខុស** ១០- ជំហានដំបូងបំផុតនៅក្នុងការផ្តល់ការអប់រំសុខភាព និងលើកកំពស់សុខភាព គឺត្រូវយល់ដឹងពីចំណុចគោល ដៅនៃសហគមន៍ទាំងនោះ។

**ត្រូវ-ខុស** ១១ - នរណាម្នាក់ក៏អាចធ្វើការផ្សព្វផ្សាយពតិមានថ្មីៗស្តីពីសុខភាព ហើយបុគ្គលិកសុខាភិបាលមានតួនាទីយ៉ាងតិចតួច ក្នុងការផ្តល់នូវការកែតំរូវទៅលើពតិមានសុខភាពទាំងនោះ។

**ត្រូវ-ខុស** ១២ - កិច្ចការដំបូងបំផុតក្នុងការអប់រំអតិថិជន គឺត្រូវជ្រើសរើសនូវអ្វីដែលត្រូវបង្រៀនអោយបានត្រឹមត្រូវ។

**ត្រូវ-ខុស** ១៣- ប្រសិទ្ធភាពនៃលទ្ធភាពរបស់អ្នក ក្នុងការផ្តល់ការថែទាំ ការព្យាបាលត្រឹមត្រូវ ការផ្តល់ថ្នាំត្រឹមត្រូវផ្តល់ការអប់រំត្រឹមត្រូវ និងការបញ្ជូនបានត្រឹមត្រូវ គឺត្រូវពឹងផ្អែកទៅលើជំនាញប្រាស្រ័យទាក់ទង។

**ត្រូវ-ខុស** ១៤- ការប្រាស្រ័យទាក់ទងដែលមានប្រសិទ្ធភាពនៅក្នុងការអប់រំសុខភាព គឺត្រូវស្វែងរកពតិមានត្រឡប់ពីអ្នកជម្ងឺ (អំពី យោបល់ កង្វល់ ជំនឿ ការប្រព្រឹត្តផ្សេងៗរបស់ពួកគេ) ហើយសំរេចចិត្តថាបញ្ហាមួយណាដែលមានឥទ្ធិពលមិនល្អ ចំពោះសុខភាព។

**ត្រូវ-ខុស** ១៥- ការអប់រំសុខភាពបានលទ្ធផលល្អ ប្រសើរបើកាលណា ភាសាដែលប្រើទៅនោះមានលក្ខណៈសាមញ្ញហើយ វិធីសាស្ត្របង្រៀនដែលប្រើទៅនោះ ធ្វើអោយប្រជាជនចូលចិត្ត។

**ត្រូវ-ខុស** ១៦- គោលបំណងនៃការស្វែងរកពតិមានត្រឡប់ គឺដើម្បីវិនិច្ឆ័យថា តើមនុស្សទាំងនោះយល់ដឹងត្រឹមត្រូវ អំពីបញ្ហាសុខភាពដែរ ឬទេ។

**ត្រូវ-ខុស** ១៧- សារៈសំខាន់នៅក្នុងការស្វែងរកពតិមានត្រឡប់ ពីការអប់រំអ្នកជម្ងឺ គឺគ្រាន់តែក្រឡេកមើលទៅលើទឹកមុខរបស់អ្នកដែលទទួលការអប់រំសុខភាពនោះប៉ុណ្ណោះ។

**ត្រូវ-ខុស** ១៨- ការកត់ត្រាគ្រប់ពេលវេលានូវរាល់អ្វីៗដែលបុគ្គលិកសុខាភិបាលបានធ្វើ ដូចជាផ្នែកនៃការព្យាបាលគួរតែត្រូវបញ្ចូលទៅក្នុងបញ្ជីពិនិត្យពិគ្រោះជម្ងឺក្រៅ របស់មណ្ឌលសុខភាព។

**ត្រូវ-ខុស** ១៩- នៅក្នុងបញ្ជីពិនិត្យពិគ្រោះជម្ងឺក្រៅ យ៉ាងហោចណាស់គួរមានៈ ឈ្មោះអ្នកជំងឺ ការអប់រំដែលបានផ្តល់ឱ្យនិងសេចក្តីណែនាំអំពីការតាមដាន ករណីដែលត្រូវត្រឡប់មកវិញ។

**ត្រូវ-ខុស** ២០- រូបភាពផ្ទាំងធំ (Posters) គួរតែព្យួរកន្លែងណាដែលមនុស្សជាច្រើនដើរឆ្លងកាត់ ដូចជានៅក្នុងភូមិ សាលារៀន មណ្ឌលសុខភាព គ្លីនិកឯកជន ការិយាល័យ ។ល។

**ត្រូវ-ខុស** ២១- នៅពេលយើងអប់រំប្រជាជន ដោយចែករូបភាពសន្លឹកបត់ (Leaflet) រូបភាពសន្លឹកបត់ នោះមិនចាំបាច់ធ្វើការពន្យល់លំអិតទេ។

**ត្រូវ-ខុស** ២២- អ្នកអប់រំសុខភាព គួរអង្គុយនៅពីក្រោយសៀវភៅសន្លឹកផ្ទាត់ (Flip chart) ហើយអានអត្ថបទ នៅលើខ្នងសៀវភៅសន្លឹកផ្ទាត់ នោះដើម្បីពន្យល់រូបភាព ដែលអាចធ្វើអោយទស្សនិកជនអាចមើលរូបភាពឃើញច្បាស់។

**ត្រូវ-ខុស** ២៣- ការវាយតំលៃ គឺជាពតិមានដែលមានប្រយោជន៍ អាចត្រូវបានគេយកទៅប្រើនៅពេលធ្វើផែនការសកម្មភាពលើកក្រោយ ។

**ត្រូវ-ខុស** ២៤- ការសរសេរចូលពីដំបូងនូវផែនការមួយសំរាប់អប់រំសុខភាព និងលើកកំពស់សុខភាពមិនមែនជាកិច្ចការសំខាន់ របស់បុគ្គលិកមណ្ឌលសុខភាពទេ ។

**សូមអរគុណ**

ពិន្ទុក្នុងផ្នែកទី II : .................................. X ៣ = [ ]

**សរុបពិន្ទុទាំងអស់ : ផ្នែកទី I ........... + ផ្នែកទី II .............. =** [ ]

## ផ្នែកទី I តារាងចម្លើយសំណួរសាកល្បង មុននិងក្រោយពេលសិក្សា

| **១** | | | **២** | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ល.រ | ក | ខ | ល.រ | ក | ខ | គ | ឃ | ង | ច |
| ១ | | | ១ | | | | | | |
| ២ | | | ២ | | | | | | |
| | | | ៣ | | | | | | |
| | | | ៤ | | | | | | |
| | | | ៥ | | | | | | |
| | | | ៦ | | | | | | |

| **៣** | | | | | | | |
|---|---|---|---|---|---|---|---|
| ល.រ | ក | ខ | គ | ឃ | ង | ច | ឆ |
| ១ | | | | | | | |
| ២ | | | | | | | |
| ៣ | | | | | | | |
| ៤ | | | | | | | |
| ៥ | | | | | | | |
| ៦ | | | | | | | |
| ៧ | | | | | | | |

## ផ្នែកទី II

| ល.រ | **ត្រូវ** | **ខុស** | ល.រ | **ត្រូវ** | **ខុស** |
|---|---|---|---|---|---|
| ១ | | | ១៣ | | |
| ២ | | | ១៤ | | |
| ៣ | | | ១៥ | | |
| ៤ | | | ១៦ | | |
| ៥ | | | ១៧ | | |
| ៦ | | | ១៨ | | |
| ៧ | | | ១៩ | | |
| ៨ | | | ២០ | | |
| ៩ | | | ២១ | | |
| ១០ | | | ២២ | | |
| ១១ | | | ២៣ | | |
| ១២ | | | ២៤ | | |